# ធម្មបូជាវិសាខបុណ្ណមី

## សមថកម្មដ្ឋាន និង វិបស្សនាកម្មដ្ឋាន

(មគ្គផល សមាបត្តិ៨ និរោធសមាបត្តិ)




ពុទ្ធបូជា មហាតេជោ បូជាព្រះពុទ្ធនាំឲ្យមានតេជះ៚

ធម្មបូជា មហាបញ្ញោ បូជាព្រះធម៌នាំឲ្យមានបញ្ញា៚

សង្ឃបូជា មហាធនំ បូជាព្រះសង្ឃនាំឲ្យមានទ្រព្យធន៚

សីលេន សុគតឹ យន្តិ សត្វទាំងឡាយទៅកាន់ឋានសួគ៌បានក៏ព្រោះសីល។

សីលេន ភោគសម្បទា សត្វទាំងឡាយបរិបូណ៌ដោយភោគសម្បត្តិក៏ព្រោះសីល។

សីលេន និព្វុតឹ យន្តិ សត្វទាំងឡាយបានទៅកាន់ព្រះនិព្វានក៏ព្រោះសីល។

តស្មា សីលំ វិសោធយេ ព្រោះហេតុនោះបុគ្គលជាសប្បុរស គប្បីជម្រះនូវសីលឲ្យបរិសុទ្ធ កុំឲ្យសៅហ្មង។

**អត្តា ហិ អត្តនោ នាថោ ខ្លួនជាទីពឹងរបស់ខ្លួនឯង...!!!**

# វិសាខបុណ្ណមី

វិសាខបុណ្ណមី ជាថ្ងៃវិសេស យើងបានចាំចេះ ថ្ងៃព្រះភគវា ប្រាំពីរប្រការ ជ្រះថ្លាវន្ទា វិសាខបូជា ឫក្សពារសែនល្អ។

ទីមួយ គឺថ្ងៃ សុមេធបណ្ឌិត ពោធិសត្វពិត មានឫទ្ធិបវរ ចាប់ផ្ដើមទទួល ព្រះពុទ្ធព្យាករណ៍ លោកធាតុញាប់ញ័រ សាទរពេកក្រៃ។

ទីពីរ គឺថ្ងៃ ក្សត្រថ្លៃប្រសូតិ អស្ចារ្យរហូត សម្ដោធិព្រឹក្សព្រៃ កំណើតចុងក្រោយជាប់ដោយអត្ថន័យ ផុតចាកភពត្រៃ លែងភ័យលែងព្រួយ។

ទីបី គឺថ្ងៃ ព្រះស្រីមហាពោធិ៍ ដុះចេញលេចធ្លោរ ពោធិ៍ពិតមានត្រួយ ថ្ងៃព្រះប្រសូតិស្រូតដុះជាមួយ ជំនួយឲ្យចិត្ត បរិស័ទជ្រះថ្លា។

ទីបួន គឺថ្ងៃ ចមត្រៃត្រាស់ដឹង ថ្ងៃមានទីពឹង ពំនឹងលោកា ជាថ្ងៃព្រះពុទ្ធ បរិសុទ្ធអស្ចារ្យ ពួកជនជ្រះថ្លា ចិន្ដាល្អស្អាត។

ទីប្រាំ គឺថ្ងៃ អង្គថ្លៃនិព្វាន ថ្ងៃព្រះទ្រង់ញាណ មានពុទ្ធោវាទ បច្ឆិមវាចា ថាកុំប្រមាទវាទពិសិដ្ឋ ឋិតនៅជាគ្រូ។

ទីប្រាំមួយ គឺថ្ងៃ ប្រល័យព្រះធាតុ ចេតិយលោកនាថ នៅទៀតមិនយូរ ព្រះធាតុទាំងអស់ ហោះមកគល់ពោធិ៍ តេជោរំលាយ រំលត់ពុទ្ធសាសន៍។

ទីប្រាំពីរ គឺថ្ងៃ ជោគជ័យពុទ្ធា គ្រប់ព្រះភគវា ឈ្នះមារបានត្រាស់ នាំមកនូវសុខវិសេសខ្លាំងណាស់ គ្រប់អង្គទ្រង់ត្រាស់ ព្រះធម៌ទេសនា។

វិសាខបុណ្ណមី ថ្ងៃប្រពៃពិត យើងខ្ញុំមានចិត្ត នឹងធឹងជ្រះថ្លា វន្ទាសំពះ អង្គព្រះសាស្ដា សូត្រធម៌ថ្វាយផ្កា បូជាប្រទីប៕

# អារម្ភកថា

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស៚

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស៚

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស៚

ពុទ្ធំ សរណំ គច្ឆាមិ ធម្មំ សរណំ គច្ឆាមិ សង្ឃំ សរណំ គច្ឆាមិ៚

ខ្ញុំករុណាឈ្មោះ **ម៉ៅ ឡេង** កើតនៅថ្ងៃអាទិត្យ ទី ១៥ កើតពេញបូណ៌មី ខែមិគសិរ ឆ្នាំ រោង ១៩៧៦ មានឪពុកឈ្មោះ **ម៉ៅ យុន** និងម្តាយឈ្មោះ **លី ទាង**។ រៀបចំចងក្រងសៀវភៅ "**សមថកម្មដ្ឋាន និង វិបស្សនាកម្មដ្ឋាន**" នេះឡើងដោយអាស្រ័យការស្រាវជ្រាវសៀវភៅ៖ អភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ, បរមត្ថធម៌សង្ខេប, អភិធម្មត្ថសង្គហ, សមាធិនិទ្ទេស ភាគទី ៣, បឋមវិបស្សនា, មេរៀនអានាបានស្សតិ, កម្មដ្ឋាននិទ្ទេស, សមថកម្មដ្ឋាន និង វិបស្សនាកម្មដ្ឋាន, វិបស្សនាវិធី, ពោជ្ឈង្គកថា, ពោធិបក្ខិយធម៌, មាគ៌ាជីវិតនៃព្រះពោធិសត្វ, ពុទ្ធវង្សសង្ខេប, កប្បកថា, ព្រះត្រៃបិដក, ព្រះអដ្ឋកថា និងរួមផ្សំបទពិសោធន៍បដិបត្តិធម៌ផ្ទាល់ខ្លួន។ វត្ថុបំណងក្នុងការចងក្រងសៀវភៅនេះឡើង ដើម្បីបូជាវិសាខបុណ្ណមីថ្ងៃថ្លាវិសិដ្ឋ ដើម្បីរួមចំណែកទ្រទ្រង់ព្រះពុទ្ធសាសនា និងដើម្បីជាប្រយោជន៍ដល់បរិស័ទសិក្សាបដិបត្តិ។ អានិសង្សនៃធម្មទាននេះ សូមបានជាបច្ច័យនៃសព្វញ្ញុតញ្ញាណ និងឧទ្ទិសដល់ជីដូនជីតា មាតាបិតា ព្រះពោធិសត្វទាំងឡាយ ព្រះអរិយបុគ្គលទាំងឡាយ គុណគ្រូឧបាធ្យាយទាំងឡាយ តាបសតសីទាំងឡាយ ភរិយាបុត្តធីតា ញាតិមិត្ត ក្នុងសង្សារវដ្ត ព្រមទាំងសព្វសត្តក្នុងសែនកោដិចក្កវាឡបាននូវសេចក្តីសុខ បាននូវសេចក្តីចម្រើន បានជាប្រយោជន៍ បានជាបច្ច័យត្រាស់ដឹងនូវអរិយសច្ចដល់ព្រះនិព្វាន៚

សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ។

មាតិកាធម៌ ទំព័រ


*អធិប្បាយពាក្យ បរមត្ថ ........ ១
*សច្ច ២ យ៉ាង ........ ១
-បរមត្ថសច្ច ........ ១
-សម្មតិសច្ច ........ ១
*បញ្ញត្តិ ២ យ៉ាង ........ ២
-សទ្ទប្បញ្ញត្តិ ........ ២
-អត្ថប្បញ្ញត្តិ ........ ២
ក-បរមត្ថធម៌ ៤ យ៉ាង ........ ៣
ខ-បញ្ចក្ខន្ធ ឬខន្ធ ៥ ........ ៣
*រូបធម៌ នាមធម៌ ........ ៤
*សង្ខារ ........ ៤
គ-រូបបរមត្ថ ២៨ ........ ៥
ឃ-ចេតសិកបរមត្ថ ៥២ ........ ៧
~អញ្ញសមានាចេតសិក ១៣ ........ ៧
-សព្វចិត្តសាធារណចេតសិក ៧ ........ ៧
-បកិណ្ណកចេតសិក ៦ ........ ៧
~អកុសលចេតសិក ១៤ ........ ៨
~សោភណចេតសិក ២៥ ........ ៩
-សោភណសាធារណចេតសិក ១៩ ........ ១០
-វិរតិចេតសិក ៣ ........ ១១
-អប្បមញ្ញាចេតសិក ២ ........ ១១
-បញ្ញិន្ទ្រិយចេតសិក ១ ........ ១១
*ឧបេក្ខា ១០ យ៉ាង ........ ១២
ង-ចិត្តបរមត្ថ ៨៩-១២១ ដួង ........ ១៣
+កាមាវចរចិត្ត ៥៤ ដួង ........ ១៣
~អកុសលចិត្ត ១២ ដួង ........ ១៣

-លោភមូលចិត្ត ៨ ដួង ១៣
-ទោសមូលចិត្ត ២ ដួង ១៤
-មោហមូលចិត្ត ២ ដួង ១៤
*អកុសលធម៌ ៩ កង ១៥
*តណ្ហា និង ឧបាទាន ១៦
*សំយោជន ១០ ១៦
*អាសវៈ ៤ ១៧
*កិលេស ៣ យ៉ាង ១៧
~អហេតុកចិត្ត ១៨ ដួង ១៧
-អកុសលវិបាកចិត្ត ៧ ដួង ១៨
+អកុសលសន្តីរណចិត្ត ធ្វើកិច្ច ៥ យ៉ាង ១៩
-អហេតុកកុសលវិបាកចិត្ត ៨ ដួង ១៩
-អហេតុកកិរិយាចិត្ត ៣ ដួង ២១
~កាមាវចរសោភណចិត្ត ២៤ ដួង ២១
-មហាកុសលចិត្ត ៨ ដួង ២១
*ចេតនា ៣ យ៉ាង ២៣
*បុញ្ញកិរិយាវត្ថុ ១០ យ៉ាង ២៣
-មហាវិបាកចិត្ត ៨ ដួង ២៤
*មហាវិបាកចិត្តចែកសត្វឲ្យផ្សេងគ្នា ៧ កន្លែង ២៥
*កុសលកម្មឲ្យផលផ្សេងគ្នា ៧ យ៉ាង ២៦
-មហាកិរិយាចិត្ត ៨ ដួង ២៦
+រូបាវចរសោភណចិត្ត ១៥ ដួង ២៧
-រូបាវចរកុសលចិត្ត ៥ ដួង ២៧
-រូបាវចរវិបាកចិត្ត ៥ ដួង ២៨
-រូបាវចរកិរិយាចិត្ត ៥ ដួង ២៨
+អរូបាវចរសោភណចិត្ត ១២ ដួង ២៩
-អរូបាវចរកុសលចិត្ត ៤ ដួង ២៩

-អរូបាវចរវិបាកចិត្ត ៤ ដួង ........ ២៩
*ចុតិចិត្ត និង បដិសន្ធិចិត្ត ........ ៣០
-អរូបាវចរកិរិយាចិត្ត ៤ ដួង ........ ៣១
~លោកុត្តរសោភណចិត្ត ........ ៣១
+អាយតនៈ ១២ ........ ៣២
+អារម្មណ៍ ៦ ........ ៣៣
+ធាតុ ១៨ ........ ៣៣
*បញ្ចទ្វារវិថី ........ ៣៤
*វិសយប្បវត្តិ ៤ ........ ៣៥
*មនោទ្វារវិថី ........ ៣៦
*វិញ្ញត្តិគហណវិថី ........ ៣៧
-កាយវិញ្ញត្តិគហណវិថី ........ ៣៧
-វចីវិញ្ញត្តិគហណវិថី ........ ៣៨
*មរណាសន្នវិថី ........ ៣៨
*កិច្ចចតុក្ក (កិច្ចរបស់កម្ម មាន ៤) ........ ៣៩
*បាកចតុក្ក (ការឲ្យផលរបស់កម្ម មាន ៤) ........ ៤០
*កាលចតុក្ក (វេលាឲ្យផលរបស់កម្ម មាន ៤) ........ ៤០
*ឋានចតុក្ក (ឋានដែលឲ្យផលរបស់កម្ម មាន ៤) ........ ៤១
*និយតមិច្ឆាទិដ្ឋិ ៣ យ៉ាង ........ ៤១
*មរណ ៤ យ៉ាង ........ ៤២
*សុបិនវិថី ........ ៤២
*ហេតុឲ្យកើតបញ្ញា ៣ យ៉ាង ........ ៤៣
*ហេតុឲ្យកើតកុសលញាណសម្បយុត្ត ........ ៤៣
*ចក្ក(សម្បត្តិ) ៤ ជាហេតុធ្វើឲ្យកុសលកើតឡើង ........ ៤៤
*ហេតុឲ្យកើតអកុសលចិត្ត ១២ មាន ៤ យ៉ាង ........ ៤៤
*អកុសលកម្មបថ ១០ ........ ៤៤
*កុសលកម្មបថ ១០ ........ ៤៥

*សីសប្រាំ និងអង្គនៃសិក្ខាបទ ........ ៤៦
*បច្ចុយ ២៤ ........ ៤៨
ច-បដិច្ចសមុប្បាទ ........ ៥០
*អរិយសច្ច ៤ ........ ៥០
*ទោសរបស់កាមមានឧបមា ១០ យ៉ាង ........ ៥៣
ឆ-សមថកម្មដ្ឋាន ........ ៥៤
*អានាបានស្សតិ ១៦ វត្ថុ ........ ៥៥
*លក្ខណសម្គាល់នៃសុខវេទនាពុំមែនជាអង្គឈាន និងសុខជាអង្គឈាន ........ ៦២
*បហាន(ប្រហារកិលេស) ៥ យ៉ាង ........ ៦២
ជ-ឧបចារសមាធិ ........ ៦៣
*ពោធិបក្ខិយធម៌ ........ ៦៣
+សតិប្បដ្ឋាន ៤ ........ ៦៣
+អានិសង្សនៃការចម្រើនសតិប្បដ្ឋាន ........ ៦៧
+សម្មប្បធាន ៤ ........ ៦៨
+ឥទ្ធិបាទ ៤ ........ ៦៨
+ឥន្ទ្រិយ ៥ ........ ៦៨
+ពលៈ ៥ ........ ៦៩
+ពោជ្ឈង្គ ៧ ........ ៦៩
+អរិយអដ្ឋង្គិកមគ្គ ........ ៦៩
*អាហាររបស់វិជ្ជា និងវិមុត្តិ ........ ៦៩
*អាហាររបស់អវិជ្ជា ........ ៧០
*អាហាររបស់នីវរណធម៌ ........ ៧០
*នីវរណប្បហាន(ធម៌ជាគ្រឿងលះនីវរណ) ........ ៧១
*បីតិ ៥ យ៉ាង ........ ៧៣
-និមិត្តក្នុងសមាធិ ........ ៧៤
*ត្រៃលក្ខណធម៌ ........ ៧៤
ឈ-វិបស្សនាកម្មដ្ឋាន ........ ៧៥

*សោឡសញ្ញាណ ........ ៧៧
*វិសុទ្ធិទាំង ៧ ........ ៧៩
*អនុបស្សនា ៧ ........ ៨០
*ញាណ ៣ យ៉ាង ........ ៨១
*សោឡសកិច្ច ........ ៨១
*បរិញ្ញា ៣ យ៉ាង ........ ៨២
*លោកុត្តរអប្បនាវិថី ........ ៨២
*បច្ចវេក្ខណវិថី ........ ៨៣
*លោកិយបញ្ញា ........ ៨៣
*កម្មស្សកតាបញ្ញា ១០ យ៉ាង ........ ៨៤
*លោកុត្តរបញ្ញា ........ ៨៥
*លក្ខណផ្សេងគ្នានៃការដឹងដោយចិត្ត សតិ បញ្ញា ........ ៨៥
*ធម៌ជំនួយស្មារតី ........ ៨៥
*គន្ថធុរៈ និង វិបស្សនាធុរៈ ........ ៨៦
*ការកំណត់ដឹងដោយសតិ និងដោយទិដ្ឋិ ........ ៨៧
*ចេតនា និងអារម្មណ៍ជាធម៌ដែលត្រូវសម្លឹងមើល ........ ៨៨
*ការកំណត់ដឹងទុក្ខ ........ ៨៩
*ខណមានទុក្ខត្រូវពិចារណា ........ ៨៩
*បដិបទាប្រព្រឹត្តទៅលះឧបាទាន ........ ៩០
*បញ្ញាកាត់ផ្តាច់វដ្ត ........ ៩០
*កម្មមាន បុគ្គលអ្នកធ្វើកម្ម និងទទួលផលរបស់កម្មមិនមាន ........ ៩០
*វដ្តគាមិនីកុសល និង វិវដ្តគាមិនីកុសល ........ ៩១
*ចក្ខុ ២ ប្រភេទ ........ ៩២
ញ-អប្បនាសមាធិ ........ ៩៣
-រូបជ្ឈាន ........ ៩៣
*វសី ៥ ........ ៩៤
*អប្បនាវិថី ........ ៩៤

-អរូបជ្ឈាន ........................................................ ៩៥
*និរោធសមាបត្តិ ........................................................ ៩៧
*វិមោក្ខ ៣ យ៉ាង ........................................................ ៩៩
*វិមោក្ខ ៨ ប្រការ ........................................................ ១០០
*សមាបត្តិ ៣ យ៉ាង ........................................................ ១០១
*ការសន្សំឧបនិស្ស័យជាកន្សែសារពេជ្ជ ........................................................ ១០៣
*មាគ៌ាជីវិតនៃព្រះពោធិសត្វ ........................................................ ១០៥

*អធិប្បាយពាក្យ បរមត្ថ:

ពាក្យថា បរមត្ថ: បរម គឺប្រសើរ ខ្ពង់ខ្ពស់ មិនវិបរិត(ប្រែប្រួល), អត្ថ: ន័យ, សេចក្ដី។ បរមត្ថ: មានសេចក្ដីដ៏ប្រសើរ, សភាវដែលមានពិត។

សភាវ: ភាវ(អរូបធម៌)ដែលមាននៅក្នុងធម្មជាតិ; ធម្មជាតិដើម គឺបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ អាកាសធាតុ វិញ្ញាណធាតុ។

អរូបធម៌: ធម្មជាតិដែលមិនមានរូប។

ធម្មជាតិ: អ្វីៗដែលកើតមានដោយឯង ដូចជាទឹក ដី ភ្លើង ខ្យល់ រុក្ខា សត្វ។

ធាតុ: អរូបធម៌ដែលមិនអាចមើលឃើញដោយភ្នែក។

ធម៌=ធម្ម: ធម្មជាតិ; សភាវដែលទ្រទ្រង់សត្វលោកមានបុណ្យ និងបាប, ព្រះធម៌ គឺជាសភាវដែលទ្រទ្រង់សត្វលោកមិនឲ្យធ្លាក់ចុះទៅក្នុងអំពើអាក្រក់ ឬក៏ធ្លាក់ចុះទៅក្នុងអបាយភូមិ ព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធបានត្រាស់ដឹងសំដៅយកអរិយសច្ចធម៌ ៤ ដែលជាខ្លឹមសារទាំងស្រុងនៃព្រះពុទ្ធសាសនា។

សភាវធម៌: ធម្មជាតិដើមដែលបណ្ដុំជាសណ្ឋាន មានរូបកាយ(រូបធម៌) និងនាមកាយ(នាមធម៌ គឺធម្មជាតិមានតែឈ្មោះមិនមានរូប ដូចជាចិត្ត ចេតសិក និព្វាន)។

បរមត្ថធម៌: ធម៌មានសេចក្ដីជម្រៅដ៏ក្រៃលែង គឺព្រះអភិធម្ម; សភាវធម៌មានពិតដែលពុំមែនតួខ្លួន សត្វ បុគ្គល មាន ២ យ៉ាង:

១-សង្ខតធម៌/សង្ខារធម៌: សភាវធម៌ដែលមានបច្ច័យតាក់តែង គឺចិត្ត ចេតសិក រូប។

២-អសង្ខតធម៌/វិសង្ខារធម៌: សភាវធម៌ដែលមិនមានបច្ច័យតាក់តែង គឺនិព្វានធាតុ។

*សច្ច គឺសេចក្ដីពិត មាន ២ យ៉ាង:

១-បរមត្ថសច្ច: សភាវធម៌មានពិតតាមលំនាំរបស់ធម្មជាតិ។

២-សម្មតិសច្ច: សភាវធម៌មានដោយការសន្មតិ ដូចជា សប្បាយ ក្រៀមក្រំ ព្រៃឈើ ភ្នំ ចាន ឆ្នាំង មនុស្ស សត្វ។

*បញ្ញត្តិ ២ យ៉ាង:

បញ្ញត្តិ គឺការកំណត់សំឡេង និងអត្ថ(សេចក្តី)របស់ពាក្យសម្រាប់សម្គាល់ដឹង។

១-សទ្ទប្បញ្ញត្តិ: ការកំណត់សំឡេងរបស់ពាក្យសម្រាប់សម្គាល់ដឹង។ ឧទាហរណ៍: មនុស្សប្រុស និងមនុស្សស្រីនិយាយពាក្យ៖ "ស្រឡាញ់" ការសម្គាល់ដឹងសំឡេងរបស់ពាក្យ៖ "ស្រឡាញ់" គឺជាសទ្ទប្បញ្ញត្តិ ចំណែកការសម្គាល់ដឹងថា នេះជាសំឡេងរបស់មនុស្សប្រុស នេះជាសំឡេងរបស់មនុស្សស្រី ក៏ជាសទ្ទប្បញ្ញត្តិដែរ។ សទ្ទប្បញ្ញត្តិ គឺជាធម្មារម្មណ៍៕

២-អត្ថប្បញ្ញត្តិ: ការកំណត់អត្ថរបស់ពាក្យ និងកាយវិការសម្រាប់សម្គាល់ដឹង។ ឧទាហរណ៍: មនុស្សប្រុស និងមនុស្សស្រីនិយាយពាក្យ៖ "ស្រឡាញ់" ការដឹងអត្ថរបស់ពាក្យ៖ "ស្រឡាញ់" គឺដឹងន័យរបស់ពាក្យ ជាអត្ថប្បញ្ញត្តិ។ បើគេធ្វើដៃជារូបបេះដូង ការដឹងន័យរបស់សញ្ញាដែលបង្ហាញពីសេចក្តី៖ "ស្រឡាញ់" គឺដឹងន័យរបស់កាយវិការ ជាអត្ថប្បញ្ញត្តិ។ អត្ថប្បញ្ញត្តិ ជាធម្មារម្មណ៍៕

ម៉្យាងទៀត សណ្ឋាននៃពំនូកដី ឬថ្មខ្ពស់ត្រដែតផុតឡើងពីផ្ទៃដីដែលកំណត់ហៅថា៖ "ភ្នំ" គឺជាអត្ថប្បញ្ញត្តិ ចំណែកសំឡេងដែលហៅថា៖ "ភ្នំ" គឺជាសទ្ទប្បញ្ញត្តិ។

ការបញ្ញត្តិជាពាក្យពេចន៍សម្រាប់ដឹងន័យសេចក្តី ឬការបញ្ញត្តិជាឈ្មោះសម្រាប់ហៅ(ដូចជាមនុស្ស សត្វ ទឹក ដី ភ្លើង ខ្យល់ ដើមឈើ វត្ថុផ្សេងៗ) គឺត្រូវអាស្រ័យបរមត្ថ។

## ក-បរមត្ថធម៌ ៤ យ៉ាង:

១-និព្វានបរមត្ថ: នាមធម៌(ធាតុដឹង) តែជាសភាវធម៌ពុំដឹងអារម្មណ៍ ជាខន្ធវិមុត្តិ គឺផុតចាកខន្ធ មានពីរគឺ: សឧបាទិសេសនិព្វានធាតុ គឺនិព្វានរំលត់កិលេសនៅសល់ខន្ធ និងអនុបាទិសេសនិព្វានធាតុ គឺនិព្វានរំលត់ខន្ធ ជាវិសង្ខារធម៌។

២-រូបបរមត្ថ: រូបធម៌(ពុំមែនធាតុដឹង) ជាសភាវធម៌កើតរលត់ដែលមានអាយុ ១៧ ខណចិត្ត ហើយរមែងមានការបែកធ្លាយ ជាសង្ខារធម៌។

៣-ចិត្តបរមត្ថ: នាមធម៌(ធាតុដឹង) ជាសភាវធម៌ចម្បងក្នុងការដឹងអារម្មណ៍ដែលកើតរលត់តគ្នាយ៉ាងរហ័សមិនអាចរាប់ប្រមាណបាន ជាសង្ខារធម៌។

៤-ចេតសិកបរមត្ថ: នាមធម៌(ធាតុដឹង) ជាសភាវធម៌កើតរួមជាមួយនឹងចិត្ត រលត់ព្រមជាមួយនឹងចិត្ត ហើយដឹងអារម្មណ៍តែមួយជាមួយនឹងចិត្ត ជាសង្ខារធម៌។

## ខ-បញ្ចក្ខន្ធ ឬ ខន្ធ ៥:

ខន្ធ មានសេចក្តីថា ជាគំនរ ពួក កង ប្រជុំ។ សភាគធម៌ គឺធម៌ដែលមានចំណែកស្មើគ្នានោះៗ ដែលផ្សេងគ្នាដោយកាល មានអតីតកាល អនាគតកាល និងបច្ចុប្បន្នកាលជាដើម ឈ្មោះថា ខន្ធ ព្រោះអត្ថគឺ ជាគំនរក្នុងទីតែមួយជាមួយគ្នាដោយរុប្បនលក្ខណ(រូបមានការបែកធ្លាយជាលក្ខណ)។

១-រូបក្ខន្ធ(រូបបរមត្ថ ២៨): សភាវធម៌ដែលពុំដឹងអារម្មណ៍ រមែងមានការបែកធ្លាយ។

២-វេទនាខន្ធ(វេទនាចេតសិក): សភាវធម៌ដែលសោយនូវអារម្មណ៍ ជាសុខ ជាទុក្ខ ជាសោមនស្ស ជាទោមនស្ស ជាឧបេក្ខា វេទនាចេតសិកកើតរួមគ្រប់ខណចិត្ត។

៣-សញ្ញាខន្ធ(សញ្ញាចេតសិក): សភាវធម៌ដែលសម្គាល់ចងចាំនូវអារម្មណ៍ សញ្ញាចេតសិកកើតរួមគ្រប់ខណចិត្ត។

៤-សង្ខារក្ខន្ធ(ចេតសិក ៥០): សភាវធម៌ដែលតាក់តែងចិត្តជាកុសល ឬអកុសល។

៥-វិញ្ញាណក្ខន្ធ(ចិត្ត ៨៩-១២១ ដួង): សភាវធម៌ដែលដឹងនូវអារម្មណ៍។

*រូបធម៌ នាមធម៌ (ហៅថានាមរូប):

១-រូបធម៌ គឺជារូបខន្ធ។

២-នាមធម៌ គឺជាវេទនាខន្ធ + សញ្ញាខន្ធ + សង្ខារខន្ធ + វិញ្ញាណខន្ធ។

នាមធម៌នេះ ដែលខ្មែរហៅថា "ព្រលឹង" ឬលទ្ធិសាសនាដទៃហៅថា "អាត្ម័ន" ដោយសស្សតទិដ្ឋិ(ការយល់ឃើញថាខ្លួន និងលោកជាសភាវទៀង)។

*សង្ខារ: ប្រែថាជាសភាវធ្វើនូវសហជាត(កើតរួម)ធម៌ និងសម្បរាយផល(ផលក្នុងបរលោក) ធម៌ឲ្យជាគំនរសង្ខារ។

## -អភិសង្ខារ គឺជាកម្ម មាន ៣ គឺ:

១-បុញ្ញាភិសង្ខារ: បានដល់ចេតនា ១៣ គឺកាមាវចរកុសលចេតនា ៨ ប្រព្រឹត្តក្នុងបុញ្ញកិរិយាវត្ថុ ១០ និងរូបាវចរកុសលចេតនា ៥ ប្រព្រឹត្តទៅដោយអំណាចភាវនា។

២-អបុញ្ញាភិសង្ខារ: បានដល់អកុសលចេតនា ១២។

៣-អនេញ្ជាភិសង្ខារ: បានដល់អរូបាវចរកុសលចេតនា ៤ ប្រព្រឹត្តទៅដោយអំណាចភាវនា។

## គ-រូបបរមត្ថ ២៨ គឺ:

-អវិនិព្ភោគរូប ៨ គឺ: មហាភូតរូប ៤(បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ) និង ឧបាទាយរូប ៤(វណ្ណរូប គន្ធរូប រសរូប ឱជរូប=អាហាររូប គឺជីវជាតិ)។

-លក្ខណរូប ៤(ឧបចយរូប គឺរូបកើត សន្តតិរូប គឺរូបចម្រើន ជរតារូប គឺរូបទ្រុឌទ្រោម អនិច្ចតារូប គឺរូបរលត់)។

-បរិច្ឆេទរូប ១ គឺអាកាសធាតុ។ ទាំងឧបាទិន្នកសង្ខារ គឺសង្ខារដែលមានវិញ្ញាណអាស្រ័យនៅ និងអនុបាទិន្នកសង្ខារ គឺសង្ខារដែលមិនមានវិញ្ញាណអាស្រ័យនៅ សុទ្ធតែផ្សំផ្គុំឡើងដោយមហាភូតរូប៤ និងឧបាទាយរូប៤ រួមគ្នាជារូបមួយក្រុមតូចបំផុត ហៅថាមួយរូបកលាប គឺកោសិកាមួយគ្រាប់ ដែលមានអាយុស្មើនិង ១៧ ខណចិត្ត ពេលរូបកលាបកើតឡើងខណដំបូង ជាឧបចយរូប ខណរូបចម្រើនឡើង ជាសន្តតិរូប ខណរូបទ្រុឌទ្រោម ជាជរតារូប ខណរូបរលត់ ជាអនិច្ចតារូប ហៅថា លក្ខណរូប ឯបរិច្ឆេទរូបខ័ណ្ឌចន្លោះរវាងរូបកលាបនីមួយៗមិនឲ្យជាប់គ្នា និងមិនឲ្យបែកចេញពីគ្នា។

-បសាទរូប ៥(ចក្ខុបសាទរូប សោតបសាទរូប ឃានបសាទរូប ជិវ្ហាបសាទរូប កាយ-បសាទរូប)។

-ហទយរូប ១។

-ភាវរូប ២(ឥត្ថីភាវរូប គឺភាពជាស្រី បុរិសភាវរូប គឺភាពជាប្រុស)។

-ជីវិតិន្ទ្រិយរូប ១(រក្សារូបកើតរួមដែលមានកម្មជាសមុដ្ឋានគ្រប់កលាបឲ្យរស់នៅ)។

-វិការៈរូប ៣(រូបលហុតា គឺភាពស្រាលនៃរូប រូបមុទុតា គឺភាពទន់នៃរូប រូបកម្មញ្ញតា គឺភាពគួរដល់ការងារនៃរូប រូបរាងកាយធ្វើចលនាទៅមកដោយកិច្ចការងារផ្សេងៗ បានព្រោះអាស្រ័យរូប ៣ នេះ)។

-វិញ្ញត្តិរូប ២(កាយវិញ្ញត្តិរូប គឺអាការពិសេសដែលសម្តែង ដូចជាការព្រិចភ្នែក ញញឹម ឬកាយវិការ ឱនក្រាបជាដើម វចីវិញ្ញត្តិរូប គឺការកម្រើកប្រអប់មាត់បញ្ចេញសំឡេង ឬវាចា)។

-សទ្ទរូប ១(កើតអំពីចិត្តជាសមុដ្ឋាន ដូចជាសំឡេងមនុស្ស និងសំឡេងសត្វ កើតអំពីឧតុជាសមុដ្ឋាន ដូចជាសំឡេងផ្គរ និងសំឡេងម៉ាស៊ីន)។

+រូបសមុដ្ឋាន(បច្ច័យ)មាន ៤ គឺ:

១-កម្មជរូប: រូបកើតពីកម្មជាសមុដ្ឋាន គឺអវិនិព្ភោគរូប ៨ បសាទរូប ៥ ហទយរូប ១ ភាវរូប ២ ជីវិតិន្ទ្រិយ ១។

២-ចិត្តជរូប: រូបកើតពីចិត្តជាសមុដ្ឋាន គឺអវិនិព្ភោគរូប ៨ វិការរូប ៣ វិញ្ញត្តិរូប ២ សទ្ទរូប ១។

៣-ឧតុជរូប: រូបកើតពីឧតុ(ធាតុក្ដៅ ឬត្រជាក់)ជាសមុដ្ឋាន គឺអវិនិព្ភោគរូប ៨ វិការរូប ៣ សទ្ទរូប ១។

៤-អាហារជរូប: រូបកើតពីអាហារជាសមុដ្ឋាន គឺអវិនិព្ភោគរូប ៨ វិការរូប ៣។

+បរិច្ឆេទរូប: រូបកើតពីសមុដ្ឋានទាំង ៤ គឺ:

១-រូបកើតពីកម្មជាសមុដ្ឋាន: នៅពេលខ័ណ្ឌចន្លោះរវាងកលាបដែលកើតពីកម្មជាសមុដ្ឋាន។

២-រូបកើតពីចិត្តជាសមុដ្ឋាន: នៅពេលខ័ណ្ឌចន្លោះរវាងកលាបដែលកើតពីចិត្តជាសមុដ្ឋាន។

៣-រូបកើតពីឧតុជាសមុដ្ឋាន: នៅពេលខ័ណ្ឌចន្លោះរវាងកលាបដែលកើតពីឧតុជាសមុដ្ឋាន។

៤-រូបកើតពីអាហារជាសមុដ្ឋាន: នៅពេលខ័ណ្ឌចន្លោះរវាងកលាបដែលកើតពីអាហារជាសមុដ្ឋាន។

☺ក្នុងខណពេលតែមួយ រូបកលាបកើតរលត់មានលក្ខណ ៤ គឺផ្នែកខ្លះជាឧច្ចយរូប ផ្នែកខ្លះជាសន្តតិរូប ផ្នែកខ្លះជាជរតារូប ផ្នែកខ្លះជាអនិច្ចតារូប ញ័រពោលរាលពេញសព៌ាងកាយ។

### ឃ-ចេតសិកបរមត្ថ ៥២ គឺ:

អញ្ញសមានាចេតសិក ១៣ + អកុសលចេតសិក ១៤ + សោភណចេតសិក ២៥។

~**អញ្ញសមានាចេតសិក ១៣** គឺសព្វចិត្តសាធារណចេតសិក និងបកិណ្ណកចេតសិក។

#### -សព្វចិត្តសាធារណចេតសិក ៧ គឺ:

សព្វចិត្តសាធារណចេតសិក ប្រកបជាមួយនឹងចិត្តគ្រប់ដួង។

១-ផស្ស: សភាវធម៌ដែលធ្វើកិច្ចប៉ះខ្ទប់អារម្មណ៍តាមទ្វារទាំង ៦ ដែលជាបច្ច័យញុំាង ចិត្ត និងចេតសិកដទៃកើតឡើង។

២-វេទនា: សភាវធម៌ដែលធ្វើកិច្ចសោយរសនៃអារម្មណ៍។

៣-សញ្ញា: សភាវធម៌ដែលធ្វើកិច្ចសម្គាល់ចងចាំនូវអារម្មណ៍។

៤-ចេតនា: សភាវធម៌ដែលនឹកគិតតាំងចិត្តក្នុងកុសលធម៌ ឬអកុសលធម៌។

៥-ឯកគ្គតា: សភាវធម៌ដែលស្ងប់ស៊ប់ក្នុងអារម្មណ៍ និងធ្វើឲ្យសម្បយុត្តធម៌(ចេតសិកដែលកើតរួម)តាំងស្ងប់ស៊ប់ក្នុងអារម្មណ៍តែមួយ។

៦-ជីវិតិន្ទ្រិយ: សភាវធម៌ដែលរក្សាសហជាតចេតសិកឲ្យតាំងនៅ និងប្រព្រឹត្តទៅ។

៧-មនសិការ: សភាវធម៌ដែលរួបរួមសហជាតធម៌ធ្វើអារម្មណ៍ទុកក្នុងចិត្ត។

#### -បកិណ្ណកចេតសិក ៦ គឺ:

បកិណ្ណកចេតសិក បើប្រកបជាមួយកុសលចិត្តក៏ជាកុសលចេតសិក បើប្រកបជាមួយអកុសលចិត្តក៏ជាអកុសលចេតសិក។

១-វិតក្ក: សភាវធម៌ដែលត្រិះរិះដល់អារម្មណ៍ដែលផស្សចេតសិកប៉ះខ្ទប់។

២-វិចារ: សភាវធម៌ដែលត្រាច់ទៅពិចារណាអារម្មណ៍ដែលវិតក្កចេតសិកត្រិះរិះ។

៣-អធិមោក្ខ: សភាវធម៌ដែលបង្អោនចុះតាំងស៊ប់ក្នុងអារម្មណ៍។

៤-វីរិយ: សភាវធម៌ដែលបំពេញសេចក្តីព្យាយាម។

៥-បីតិ: សភាវធម៌ដែលញ៉ាំងចិត្តឆ្អែតនូវអារម្មណ៍ព្រឺព្រួចកាយ។

៦-ឆន្ទៈ សភាវធម៌ដែលពេញចិត្តនឹងធ្វើកិច្ចការតាមបំណង។

~អកុសលចេតសិក ១៤ គឺ:

អកុសលចេតសិក ជាចេតសិកផ្នែកអាក្រក់ ជាបាប ប្រកបបានចំពោះចិត្តជាអកុសល ១២ មិនប្រកបជាមួយអហេតុកចិត្ត ១៨ និងសោភណចិត្តទាំង ៥៩ ឬ៩១។

១-មោហៈ សភាវធម៌ដែលវង្វេងក្នុងអារម្មណ៍ មិនដឹងសច្ចធម៌ បុណ្យ និងបាប។

២-អហិរិកៈ សភាវធម៌ដែលមិនខ្មាសខ្ពើមបាប។

៣-អនោត្តប្បៈ សភាវធម៌ដែលមិនក្រែងខ្លាចបាប ព្រោះមិនឃើញទោសរបស់បាប។

៤-ឧទ្ធច្ចៈ សភាវធម៌ដែលកញ្ជ្រោលចិត្ត មិនស្ងប់ក្នុងអារម្មណ៍ រាយមាយ រវើរវាយ។

៥-លោភៈ សភាវធម៌ដែលជាប់ជំពាក់ក្នុងអារម្មណ៍ ពេញចិត្ត ប្រាថ្នា ចង់បាន។

៦-ទិដ្ឋិ: សភាវធម៌ដែលយល់ឃើញខុសក្នុងសច្ចធម៌។

៧-មានះ: សភាវធម៌ដែលលើកតម្កើងខ្លួនប្រកាន់មាំក្នុងទិដ្ឋិ។

៨-ទោសៈ សភាវធម៌ដែលប្រទូសក្នុងអារម្មណ៍ មិនពេញចិត្ត ខឹង ស្អប់។

៩-ឥស្សាៈ សភាវធម៌ដែលកើតសេចក្តីច្រណែន។

១០-មច្ឆរិយៈ សភាវធម៌ដែលកើតសេចក្តីកំណាញ់។

១១-កុក្កុច្ចៈ សភាវធម៌ដែលក្តៅក្រហាយចិត្ត សោកសៅ សោកស្តាយ។

១២-ថីនៈ សភាវធម៌ដែលរួញរា អស់កម្លាំងចិត្ត ច្រអូស លះបង់សេចក្តីព្យាយាម។

១៣-មិទ្ធៈ សភាវធម៌ដែលងោកងុយ រាថយ។

១៤-វិចិកិច្ឆាៈ សភាវធម៌ដែលមានការសង្ស័យ ញាប់ញ័រ ស្ទាក់ស្ទើរ មិនមានជំនឿចិត្ត។ សេចក្តីសង្ស័យ ៨ យ៉ាងគឺ:

-ពុទ្ធេ កង្ខតិ: សង្ស័យក្នុងព្រះពុទ្ធគុណ។

-ធម្មេ កង្ខតិៈ សង្ស័យក្នុងព្រះធម្មគុណ។

-សង្ឃេ កង្ខតិៈ សង្ស័យក្នុងព្រះសង្ឃគុណ។

-សិក្ខាយ កង្ខតិៈ សង្ស័យក្នុងសិក្ខាបទ គឺឧបដិបត្តិជាប់ទាក់ទងជាមួយសីល សមាធិ បញ្ញា។

-បុព្វន្តេ កង្ខតិៈ សង្ស័យក្នុងខន្ធ ៥ ដែលជាអតិត គឺសង្ស័យថាសត្វទាំងឡាយធ្លាប់កើតមកហើយក្នុងអតីត នឹងមានពិតឬអត់ទេហ្ន៎?។

-អបរន្តេ កង្ខតិៈ សង្ស័យក្នុងខន្ធ ៥ ដែលជាអនាគត គឺសង្ស័យថាសត្វទាំងឡាយស្លាប់ហើយនឹងកើតតទៅខាងមុខ នឹងមានពិតឬអត់ទេហ្ន៎?។

-បុព្វន្តាបរន្តេ កង្ខតិៈ សង្ស័យក្នុងខន្ធ ៥ ទាំងអតីត ទាំងអនាគត គឺថាបច្ចុប្បន្នជាតិសត្វទាំងឡាយកំពុងប្រាកដក្នុងបច្ចុប្បន្ននេះ ធ្លាប់កើតមកហើយឬអត់ទេហ្ន៎? តើនឹងកើតតទៅទៀតទេហ្ន៎?។

-ឥធប្បច្ចយតា បដិច្ចសមុប្បន្នេសុ ធម្មេសុ កង្ខតិៈ សង្ស័យក្នុងបដិច្ចសមុប្បន្នធម៌ (សភាវធម៌ដែលកើតឡើងហើយ ព្រោះអាស្រ័យបច្ច័យ) ដូចជាសង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ក្នុងបដិច្ចសមុប្បាទធម៌(ការកើតឡើងនៃហេតុ ព្រោះអាស្រ័យគ្នា ក្នុងទីនេះសំដៅយកបច្ច័យ) ដូចជាអវិជ្ជាជាបច្ច័យនៃសង្ខារ(អភិសង្ខារ) ជាបច្ច័យក្នុងរឿងបុណ្យបាប និងការបន្តក្នុងភពថ្មី ការឃើញ ការបានឮរបស់សត្វទាំងឡាយជាដើម ដែលជាប់ទាក់ទងជាមួយសេចក្តីវង្វេង និងការកាត់តែងចាត់ចែងនៃកាយ វាចា ចិត្តជាដើម ដោយហេតុនោះតែងមានពិត ឬអត់ទេហ្ន៎?៕

## ~សោភណចេតសិក ២៥ គឺៈ

សោភណចេតសិក ជាចេតសិកផ្នែកល្អ មិនប្រកបជាមួយនិងអកុសលចិត្ត ១២ និងអហេតុកចិត្ត ១៨ ទេ ប្រកបជាមួយនឹងសោភណចិត្ត ៥៩ ឬ ៩១ ចែកជាផ្នែកៈ សោភណសាធារណចេតសិក ១៩ វិរតិចេតសិក ៣ អប្បមញ្ញាចេតសិក ២ បញ្ញិន្ទ្រិយចេតសិក ១។

-សោភណសាធារណចេតសិក ១៩ គឺ:

១-សទ្ធា: សភាវធម៌ដែលជឿជាក់ជ្រះថ្លាក្នុងព្រះត្រៃរតន ក្នុងកម្ម និងផល។

២-សតិ: សភាវធម៌ដែលរឭក មិនវង្វេងភ្លេចស្មារតី។

៣-ហិរិ: សភាវធម៌ដែលខ្មាសខ្ពើមបាប។

៤-ឱត្តប្ប: សភាវធម៌ដែលញញើតខ្លាចបាប ព្រោះឃើញទោសរបស់បាប។

៥-អលោភ: សភាវធម៌ដែលមិនមានសេចក្តីពេញចិត្តក្នុងអារម្មណ៍ មិនហួងហែង។

៦-អទោស: សភាវធម៌ដែលមិនប្រទូសអារម្មណ៍ មានចិត្តត្រជាក់ មេត្តា។

៧-តត្រមជ្ឈត្តតា: សភាវធម៌ដែលមានភាពជាកណ្តាលក្នុងអារម្មណ៍ គឺឧបេក្ខា។

៨-កាយបស្សទ្ធិ: សភាវធម៌ដែលញ៉ាំងកាយស្រាលស្រឡះ បានដល់ការរម្ងាប់នូវនាមកាយគឺ វេទនា សញ្ញា សង្ខារខន្ធឲ្យស្ងប់។

៩-ចិត្តបស្សទ្ធិ: សភាវធម៌ដែលញ៉ាំងចិត្តឲ្យស្ងប់ស្រឡះ គឺការរម្ងាប់នូវរាគាទិក្កិលេសញ៉ាំងចិត្តឲ្យស្ងប់ស្រឡះ។

១០-កាយលហុតា: សភាវធម៌ដែលញ៉ាំងកាយឲ្យស្រាល។

១១-ចិត្តលហុតា: សភាវធម៌ដែលញ៉ាំងសហជាតចេតសិកឲ្យស្រាល។

(មានការស្ងប់ភាពធ្ងន់របស់កាយ និងចិត្ត មានការមិនយឺតយូររបស់កាយ និងចិត្ត)

១២-កាយមុទុតា: សភាវធម៌ដែលញ៉ាំងកាយឲ្យទន់។

១៣-ចិត្តមុទុតា: សភាវធម៌ដែលញ៉ាំងសហជាតចេតសិកឲ្យទន់។

(មានការស្ងប់ភាពរឹងរបស់កាយ និងចិត្ត មានភាពមិនជំទាស់)

១៤-កាយកម្មញ្ញតា: សភាវធម៌ដែលញ៉ាំងកាយឲ្យគួរដល់ការងារ។

១៥-ចិត្តកម្មញ្ញតា: សភាវធម៌ដែលញ៉ាំងសហជាតចេតសិកឲ្យគួរដល់ការងារ។

(មានការរម្ងាប់កាយ និងចិត្តដែលមិនគួរដល់ការងារ មានការដល់ព្រមក្នុងការធ្វើ

អារម្មណ៍ឲ្យកាយ និងចិត្ត)

១៦-កាយបាគុញ្ញតា: សភាវធម៌ដែលញ៉ាំងកាយឲ្យមានការស្ទាត់ជំនាញ។

១៧-ចិត្តបាគុញ្ញតា: សភាវធម៌ដែលញ៉ាំងសហជាតធម៌ឲ្យមានការស្ទាត់ជំនាញ។

(មានការស្ងប់ភាពឈឺរបស់កាយ និងចិត្ត មានការប្រាសចាកទោស)

១៨-កាយុជ្ជុកតា: សភាវធម៌ដែលញ៉ាំងកាយឲ្យត្រង់។

១៩-ចិត្តុជ្ជុកតា: សភាវធម៌ដែលញ៉ាំងសហជាតចេតសិកឲ្យត្រង់។

(មានការកម្ចាត់សេចក្ដីមិនត្រង់របស់កាយ និងចិត្ត មានភាពត្រង់របស់កាយ និងចិត្ត)

**-វិរតិចេតសិក ៣ គឺ:**

១-សម្មាវាចា: សភាវធម៌ដែលវាចាប្រពៃ វៀរចាកវចីទុច្ចរិត ៤។

២-សម្មាកម្មន្តៈ សភាវធម៌ដែលប្រកបការងារប្រពៃ វៀរចាកកាយទុច្ចរិត ៣។

៣-សម្មាអាជីវៈ សភាវធម៌ដែលចិញ្ចឹមជីវិតដោយប្រពៃ វៀរចាកកាយទុច្ចរិត ៣ និងវចីទុច្ចរិត ៤។

**-អប្បមញ្ញាចេតសិក ២** ប្រព្រឹត្តទៅក្នុងសត្វមិនមានប្រមាណ។

១-ករុណា: សភាវធម៌ដែលអាណិតដល់សត្វមានទុក្ខ។

២-មុទិតា: សភាវធម៌ដែលរីករាយត្រេកអរចំពោះអ្នកដទៃបាននូវសេចក្ដីសុខ។

**-បញ្ញិន្ទ្រិយចេតសិក ១ គឺ:**

១-បញ្ញិន្ទ្រិយៈ សភាវធម៌ដែលដឹងហេតុ និងផល ដឹងអរិយសច្ចជាដើម គឺបញ្ញា។

បញ្ញាចេតសិកនេះ កាលកើតឡើង រមែងដឹងទូទៅដល់ធម៌ទាំងដែលជាកុសល អកុសល ធម៌ដែលគួរសេព ធម៌ដែលមិនគួរសេព ដឹងធម៌ដែលអាក្រក់ ធម៌ដែលប្រណិត ធម៌ដែលចូលគ្នាបាន និងធម៌ដែលចូលគ្នាមិនបាន។

*ឧបេក្ខា ១០ យ៉ាង:

១-ឆឡង្គុបេក្ខា: ភាពបរិសុទ្ធព្រងើយជាកណ្តាលក្នុងអារម្មណ៍ទាំង ៦ ដែលមិនសោមនស្ស មិនទោមនស្សក្នុងទ្វារទាំង ៦ នៃព្រះខីណាស្រព បានដល់តត្រមជ្ឈត្តតាចេតសិក។

២-ព្រហ្មវិហារុបេក្ខា: ភាពព្រងើយជាកណ្តាលក្នុងសត្វទាំងឡាយ(ឧបេក្ខាក្នុងព្រហ្មវិហារធម៌) បានដល់តត្រមជ្ឈត្តតាចេតសិក។

៣-ពោជ្ឈង្គុបេក្ខា: ភាពព្រងើយជាកណ្តាលក្នុងសហជាតធម៌ដែលអាស្រ័យវិវេកធម៌ បានដល់តត្រមជ្ឈត្តតាចេតសិក។

៤-វិរិយុបេក្ខា: សេចក្តីព្យាយាមជាកណ្តាល មិនធូរថយ និងមិនប្រឹងប្រែងខ្លាំងពេក បានដល់វិរិយចេតសិក។

៥-សង្ខារុបេក្ខា: ភាពព្រងើយជាកណ្តាលក្នុងសង្ខារធម៌ទាំងឡាយ បានដល់បញ្ញាចេតសិក។

៦-វេទនុបេក្ខា: ភាពព្រងើយជាកណ្តាលក្នុងអារម្មណ៍(ឧបេក្ខាវេទនា) មិនមែនសុខ មិនមែនទុក្ខ បានដល់វេទនាចេតសិក។

៧-វិបស្សនុបេក្ខា: ភាពជាកណ្តាលក្នុងការពិចារណាលះនូវខន្ធបញ្ចកចោល បានដល់បញ្ញាចេតសិក។

៨-តត្រមជ្ឈត្តុបេក្ខា: សភាវធម៌ដែលញ៉ាំងសហជាតិធម៌ឲ្យប្រព្រឹត្តទៅព្រងើយជាកណ្តាលក្នុងធម៌ទាំងឡាយ បានដល់តត្រមជ្ឈត្តតាចេតសិក។

៩-ឈានុបេក្ខា: ភាពព្រងើយជាកណ្តាលចំពោះសេចក្តីសុខនៃឈាន គឺអារម្មណ៍ស្មើ មិនឡើងមិនចុះ បានដល់តត្រមជ្ឈត្តតាចេតសិក។

១០-បារិសុទ្ធុបេក្ខា: ភាពបរិសុទ្ធព្រងើយជាកណ្តាលស្ងប់ចាកបច្ចនិកធម៌(ធម៌ជាសត្រូវ គឺនីវរណធម៌) ដោយមិនខ្វល់ខ្វាយក្នុងការរម្ងាប់បច្ចនិកធម៌ ជាឧបេក្ខាចិត្តក្នុងចតុត្ថជ្ឈានប្រកបដោយសតិដ៏បរិសុទ្ធ បានដល់តត្រមជ្ឈត្តតាចេតសិក។

### ង-ចិត្តបរមត្ថ ៨៩-១២១ ដួង:

#### +កាមាវចរចិត្ត ៥៤ ដួង:

អកុសលចិត្ត ១២ ដួង + អហេតុកចិត្ត ១៨ ដួង + សោភណចិត្ត ២៤ ដួង។

#### ~អកុសលចិត្ត ១២ ដួង:

លោភ:មូលចិត្ត ៨ ដួង + ទោស:មូលចិត្ត ២ ដួង + មោហ:មូលចិត្ត ២ ដួង។

អកុសលចិត្ត ជាចិត្តមិនល្អ មិនស្អាត អាក្រក់ ថោកទាប ជាចិត្តដែលប្រកបជាមួយអកុសលចេតសិក ជាបាប មានទោស ឲ្យផលជាទុក្ខ។

មូល: ជាដើមហេតុ ឬឫសគល់របស់អកុសលធមិទាំងឡាយមាន: លោភចេត-សិក ទោសចេតសិក មោហចេតសិក។

#### -លោភមូលចិត្ត ៨ ដួង:

លោភមូលចិត្ត គឺចិត្តដែលមានលោភចេតសិកប្រកបជាមួយ ជាចិត្តដែលជាប់ជំពាក់អារម្មណ៍ ពេញចិត្ត ប្រាថ្នា ចង់បាន។

១-សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ លោភមូលចិត្តំ. លោភមូលចិត្តកើតឡើងព្រមដោយសោមនស្សវេទនា(សោមនស្សសហគតំ) ប្រកបដោយទិដ្ឋិ(ទិដ្ឋិគតសម្បយុត្តំ) មិនមានការបបួលដឹកនាំ(អសង្ខារិកំ) គឺមានកម្លាំង។

២-សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ លោភមូលចិត្តំ. លោភមូលចិត្តកើតឡើងព្រមដោយសោមនស្សវេទនា ប្រកបដោយទិដ្ឋិ មានការបបួលដឹកនាំ(សសង្ខារិកំ) គឺខ្សោយ។

៣-សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ លោភមូលចិត្តំ. លោភមូលចិត្តកើតឡើងព្រមដោយសោមនស្សវេទនា ប្រាសចាកទិដ្ឋិ(ទិដ្ឋិគតវិប្បយុត្តំ) មិនមានការបបួលដឹកនាំ។

៤-សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ លោភមូលចិត្តំ. លោភមូលចិត្តកើតឡើងព្រមដោយសោមនស្សវេទនា ប្រាសចាកទិដ្ឋិ មានការបបួលដឹកនាំ។

៥-ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ លោភមូលចិត្តំ. លោភមូលចិត្ត កើតឡើងព្រមដោយឧបេក្ខាវេទនា ប្រកបដោយទិដ្ឋិ មិនមានការបបួលដឹកនាំ។

៦-ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ លោភមូលចិត្តំ. លោភមូលចិត្ត កើតឡើងព្រមដោយឧបេក្ខាវេទនា ប្រកបដោយទិដ្ឋិ មានការបបួលដឹកនាំ។

៧-ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ លោភមូលចិត្តំ. លោភមូលចិត្ត កើតឡើងព្រមដោយឧបេក្ខាវេទនា ប្រាសចាកទិដ្ឋិ មិនមានការបបួលដឹកនាំ។

៨-ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ លោភមូលចិត្តំ. លោភមូលចិត្ត កើតឡើងព្រមដោយឧបេក្ខាវេទនា ប្រាសចាកទិដ្ឋិ មានការបបួលដឹកនាំ។

### -ទោសមូលចិត្ត ២ ដួង:

ទោសមូលចិត្ត គឺចិត្តដែលមានទោសចេតសិកប្រកបជាមួយ ជាចិត្តដែលប្រទូស អារម្មណ៍ មិនពេញចិត្ត មិនរីករាយ អន់ចិត្ត ខឹងក្រោធ ស្អប់ ខ្លាច តូចចិត្ត តក់ស្លុត ចង្អៀតចង្អល់ចិត្តជាដើម។

១-ទោមនស្សសហគតំ បដិឃសម្បយុត្តំ អសង្ខារិកំ ទោសមូលចិត្តំ. ទោសមូលចិត្ត កើតឡើងព្រមដោយទោមនស្សវេទនា ប្រកបដោយបដិឃ(ទោសចេតសិក) មិនមានការបបួលដឹកនាំ គឺមានកម្លាំង។

២-ទោមនស្សសហគតំ បដិឃសម្បយុត្តំ សសង្ខារិកំ ទោសមូលចិត្តំ. ទោសមូលចិត្ត កើតឡើងព្រមដោយទោមនស្សវេទនា ប្រកបដោយបដិឃ មានការបបួលដឹកនាំ គឺខ្សោយ។

### -មោហមូលចិត្ត ២ ដួង:

មោហមូលចិត្ត គឺចិត្តដែលមានមោហចេតសិកប្រកបជាមួយ ជាចិត្តដែលវង្វេងក្នុងអារម្មណ៍ មិនដឹងសច្ចធម៌ បុណ្យ និងបាប។

១-ឧបេក្ខាសហគតំ វិចិកិច្ឆាសម្បយុត្តំ អសង្ខារិកំ មោហមូលចិត្តំ. មោហមូលចិត្ត កើតឡើងព្រមដោយឧបេក្ខាវេទនា ប្រកបដោយវិចិកិច្ឆា មិនមានការបបួលដឹកនាំ។

២-ឧបេក្ខាសហគតំ ឧទ្ធច្ចសម្បយុត្តំ អសង្ខារិកំ មោហមូលចិត្តំ. មោហមូលចិត្ត កើតឡើងព្រមដោយឧបេក្ខាវេទនា ប្រកបដោយឧទ្ធច្ច មិនមានការបបួលដឹកនាំ។

លោភមូលចិត្ត មិនមានទោសចេតសិកប្រកបជាមួយ។ ទោសមូលចិត្ត មិនមានលោភចេតសិកប្រកបជាមួយ។ មោហមូលចិត្ត មិនមានលោភចេតសិក និងទោសចេតសិកប្រកបជាមួយ។ អកុសលចិត្តទាំង ៣ ប្រកបជាមួយមោហចេតសិក អហិរិកចេតសិក អនោត្តប្បចេតសិក និងឧទ្ធច្ចចេតសិកគ្រប់ខណៈ៕

*អកុសលធម៌ ៩ កង:

១-អាសវៈ ធម៌ដែលដេកត្រាំនៅក្នុងសន្តាន មាន ៤ គឺ: កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ។

២-ឱឃៈ ធម៌ដែលប្រៀបដូចអន្លង់ទឹកញាំងសត្វឲ្យលិចចុះក្នុងវដ្តៈ មាន ៤ គឺ: កាមោឃៈ ភវោឃៈ ទិដ្ឋោឃៈ អវិជ្ជោឃៈ។

៣-យោគៈ ធម៌ដែលប្រកបសត្វទុកក្នុងភូមិភព មាន ៤ គឺ: កាមយោគៈ ភវយោគៈ ទិដ្ឋិយោគៈ អវិជ្ជាយោគៈ។

៤-គន្ថៈ ធម៌ជាគ្រឿងចងសត្វទុក មាន ៤ គឺ: អភិជ្ឈាកាយគន្ថៈ ព្យាបាទកាយគន្ថៈ សីលព្វតបរាមាសកាយគន្ថៈ ឥទំសច្ចាភិនិវេសកាយគន្ថៈ។

៥-ឧបាទានៈ ធម៌ជាគ្រឿងប្រកាន់មាំ មាន ៤ គឺ: កាមុបាទាន ទិដ្ឋុបាទាន សីលព្វតុ-បាទាន អត្តវាទុបាទាន។

៦-នីវរណៈ ធម៌ជាគ្រឿងរារាំងអំពើល្អ មាន ៦ គឺ: កាមឆន្ទៈ ព្យាបាទៈ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ចៈ វិចិកិច្ឆា អវិជ្ជា។

៧-អនុសយៈ ធម៌ដែលដេកសម្ងំនៅក្នុងសន្តាន មាន ៧ គឺ: កាមរាគានុសយ ភវរាគា-នុសយ បដិឃានុសយ មានានុសយ ទិដ្ឋានុសយ វិចិកិច្ឆានុសយ អវិជ្ជានុសយ។

៨-សញ្ញោជនៈ=សំយោជនៈ ធម៌ជាគ្រឿងរួបរឹតសត្វទុក មាន ១០ គឺ: កាមរាគៈ ភវរាគៈ មានៈ ទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ឥស្សា មច្ឆរិយៈ បដិឃៈ អវិជ្ជា (សញ្ញោជន ១០ ក្នុងអភិធម្ម)។

៩-កិលេស: ធម៌ជាគ្រឿងសៅហ្មង មាន ១០ គឺ: លោភ: ទោស: មោហ: មានះ ទិដ្ឋិ វិចិកិច្ឆា ថីន: ឧទ្ធច្ច: អហិរិក: អនោត្តប្ប:។

*តណ្ហា និង ឧបាទាន:

តណ្ហា និងឧបាទាន មានសេចក្ដីផ្សេងគ្នា គឺតណ្ហាដែលមានកម្លាំងខ្សោយ ឈ្មោះថា តណ្ហា ចំណែកតណ្ហាដែលមានកម្លាំងខ្លាំង ឈ្មោះថា ឧបាទាន។ម្យ៉ាងទៀត សេចក្ដីប្រាថ្នាក្នុងអារម្មណ៍ នៅមិនមកដល់ជាតណ្ហា ប្រៀបដូចជាចោរលូកដៃចេញទៅក្នុងទីងងឹត សេចក្ដីប្រកាន់មាំក្នុងអារម្មណ៍ដែលដល់ហើយ ជាឧបាទាន ដូចចោរចាប់របស់បានហើយ។ តណ្ហា ជាមូលហេតុនៃទុក្ខក្នុងការស្វែងរក ចំណែកឧបាទាន ជាមូលហេតុនៃទុក្ខក្នុងការរក្សា៕

*សំយោជន (ក្នុងព្រះសុត្តន្ត) ១០ គឺ:

១-សក្កាយទិដ្ឋិ: ឃើញថាកាយជារបស់ខ្លួន គឺយល់ឃើញថាមានសត្វ បុគ្គល តួខ្លួន។

២-វិចិកិច្ឆា: សេចក្ដីសង្ស័យ។

៣-សីលព្វតបរាមាស: ការស្ទាបអង្អែលនូវសីលព្វត គឺទម្លាប់ និងវត្តប្រតិបត្តិខុសទំនងដែលអ្នកប្រព្រឹត្តជឿថាជាផ្លូវបរិសុទ្ធនាំឲ្យរួចចាកទុក្ខ។

៤-កាមរាគ: តម្រេកក្នុងកាមទាំងឡាយ គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វ។

៥-បដិឃ: សេចក្ដីថ្នាំងថ្នាក់ចិត្ត។

៦-រូបរាគ: តម្រេកក្នុងរូបភព។

៧-អរូបរាគ: តម្រេកក្នុងអរូបភព។

៨-មានះ: សេចក្ដីប្រកាន់។

៩-ឧទ្ធច្ច: ចិត្តរាយមាយមិនស្ងប់។

១០-អវិជ្ជា: សេចក្ដីមិនដឹងអរិយសច្ចធម៌ ៤។

សំយោជន ៣ គឺសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស លះជាសមុច្ឆេទដោយ

សោតាបត្តិមគ្គ។ កាមរាគ បដិឃ ត្រូវបានលះឲ្យស្រាលស្តើងដោយសកទាគាមិមគ្គ សំយោជន ទាំង ២ នេះ ត្រូវលះជាសមុច្ឆេទដោយអនាគាមិមគ្គ។ សំយោជន ៥ ទៀត គឺរូបរាគ អរូបរាគ មានះ ឧទ្ធច្ច អវិជ្ជា លះជាសមុច្ឆេទដោយអរហត្តមគ្គ៕

*អាសវៈ ៤ គឺ:

១-កាមាសវៈ អាសវជាប់ជំពាក់ក្នុងកាម(កាមតាមទ្វារ ៦)។

២-ភវាសវៈ អាសវជាប់ជំពាក់ក្នុងភព(កាមភព រូបភព អរូបភព)។

៣-ទិដ្ឋាសវៈ អាសវៈជាប់ជំពាក់ក្នុងទិដ្ឋិ(សេចក្តីយល់ខុស)។

៤-អវិជ្ជាសវៈ អាសវៈជាប់ជំពាក់ក្នុងអវិជ្ជា(មិនដឹងអរិយសច្ចធម៌)។

*កិលេស ៣ យ៉ាង:

១-វិតិក្កមកិលេសៈ គឺរាគៈ និងទោសៈជាកិលេសយ៉ាងគ្រោតគ្រាតដែលកើតរួមជវនវិថីចិត្ត ធ្វើឲ្យប្រព្រឹត្តនូវវចីទុច្ចរិត និងកាយទុច្ចរិត។ វិរតិ(លះវៀរ)នូវវិតិក្កមកិលេសបានដោយអំណាចសីល៕

២-បរិយុដ្ឋានកិលេសៈ គឺនីវរណធម៌ ៥ ជាកិសេលយ៉ាងកណ្តាលដែលកើតរួមជវន-វិថីចិត្ត ធ្វើឲ្យប្រព្រឹត្តនូវមនោទុច្ចរិត។ រម្ងាប់បរិយុដ្ឋានកិលេសបានមួយរយៈៗដោយវិក្ខម្ភនប្បហាន គឺលះនីវរណធម៌ដោយការគ្របសង្កត់របស់ឈាន៕

៣-អនុសយកិលេសៈ គឺកាមរាគានុសយ ភវរាគានុសយ បដិឃានុសយ មានានុ-សយ ទិដ្ឋានុសយ វិចិកិច្ឆានុសយ អវិជ្ជានុសយ ជាកិលេសយ៉ាងល្អិតដែលដេកសម្ងំនៅក្នុងសន្តាន ពេលណានៅមិនទាន់បានរម្លត់កិលេសទេ អនុសយកិលេសក៏ត្រាំនៅក្នុងចិត្ត ដែលកើតរលត់បន្តគ្នាជាក្រសែជាបច្ច័យឲ្យកើតនូវបរិយុដ្ឋានកិលេសទៀត។ អនុសយកិលេសនឹងលះជាសមុច្ឆេទប្បហានដោយលោកុត្តរបញ្ញាតាមលំ-ដាប់នៃមគ្គចិត្តនោះៗ៕

~អហេតុកចិត្ត ១៨ ដួង:

អកុសលវិបាកចិត្ត ៧ ដួង + កុសលវិបាកចិត្ត ៨ ដួង + កិរិយាចិត្ត ៣ ដួង។

អហេតុកចិត្ត មិនកើតរួមហេតុ ៦ គឺៈ អកុសលហេតុ ៣ បានដល់ លោភៈ ទោសៈ មោហៈ និងសោភណហេតុ ៣ បានដល់ អលោភៈ អទោសៈ អមោហៈគឺបញ្ញា។

## -អកុសលវិបាកចិត្ត ៧ ដួងៈ

អកុសលវិបាកចិត្ត ជាអហេតុកចិត្ត ជាផលរបស់អកុសលកម្មដែលខ្លួនបានធ្វើទុកហើយក្នុងអតីតជាតិ ឬបច្ចុប្បន្នជាតិដោយចេតនានោះមានកម្លាំង ឬខ្សោយ ទើបឲ្យផលក្នុងបវត្តិកាល(កាលបន្ទាប់អំពីបដិសន្ធិខណរលត់រហូតដល់ចុតិកាល) ដើម្បីទទួលអនិដ្ឋារម្មណ៍(អារម្មណ៍មិនជាទីពេញចិត្ត)តាមបញ្ចទ្វារ។

១-ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ អសង្ខារិកំ អកុសលវិបាកំ. អកុសលវិបាកចក្ខុវិញ្ញាណកើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យចក្ខុប្រសាទឃើញនូវរូបដែលមិនល្អ មិនមានការបបួលដឹកនាំ។

២-ឧបេក្ខាសហគតំ សោតវិញ្ញាណំ អសង្ខារិកំ អកុសលវិបាកំ. អកុសលវិបាកសោតវិញ្ញាណកើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យសោតប្រសាទឮសំឡេងដែលមិនល្អ មិនមានការបបួលដឹកនាំ។

៣-ឧបេក្ខាសហគតំ ឃានវិញ្ញាណំ អសង្ខារិកំ អកុសលវិបាកំ. អកុសលវិបាកឃានវិញ្ញាណកើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យឃានប្រសាទធុំក្លិនដែលមិនល្អ មិនមានការបបួលដឹកនាំ។

៤-ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណំ អសង្ខារិកំ អកុសលវិបាកំ. អកុសលវិបាកជិវ្ហាវិញ្ញាណកើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យជិវ្ហាប្រសាទស្រូបរសដែលមិនល្អ មិនមានការបបួលដឹកនាំ។

៥-ទុក្ខសហគតំ កាយវិញ្ញាណំ អសង្ខារិកំ អកុសលវិបាកំ. អកុសលវិបាកកាយវិញ្ញាណកើតឡើងព្រមដោយទុក្ខវេទនា អាស្រ័យកាយប្រសាទប៉ះខ្ទប់សម្ផស្សដែលមិនល្អ មិនមានការបបួលដឹកនាំ។

៦-ឧបេក្ខាសហគតំ សម្បដិច្ឆន្នចិត្តំ អសង្ខារិកំ អកុសលវិបាកំ. អកុសលវិបាកសម្បដិច្ឆន្នចិត្តកើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យហទយរូបទទួលនូវ

បញ្ចារម្មណ៍ដែលមិនល្អ មិនមានការបបួលដឹកនាំ។

៧-ឧបេក្ខាសហគតំ សន្តីរណចិត្តំ អសង្ខារិកំ អកុសលវិបាកំ. អកុសលវិបាកសន្តីរណចិត្តកើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យហទយរូបពិចារណានូវបញ្ចារម្មណ៍ដែលមិនល្អ មិនមានការបបួលដឹកនាំ។

+**អកុសលសន្តីរណចិត្ត ធ្វើកិច្ច ៥ យ៉ាង**:

១-បដិសន្ធិកិច្ច: ធ្វើកិច្ចកាត់តែងក្នុងភពថ្មី។

២-ភវង្គកិច្ច: ធ្វើកិច្ចរក្សាភព(ជីវិតក្នុងភព)។

៣-ចុតិកិច្ច: ធ្វើកិច្ចឃ្លាតចាកភព។

៤-សន្តីរណកិច្ច: ធ្វើកិច្ចពិចារណានូវអារម្មណ៍។

៥-តទាលម្ពណកិច្ច: ធ្វើកិច្ចទទួលអារម្មណ៍តពីជវន។

-**អហេតុកកុសលវិបាកចិត្ត ៨ ដួង**:

អហេតុកកុសលវិបាកចិត្ត ជាផលរបស់កុសលកម្មដែលខ្លួនបានធ្វើទុកហើយក្នុងអតីតជាតិ ឬបច្ចុប្បន្នជាតិដោយចេតនានោះមានកម្លាំង ឬខ្សោយ ទើបឲ្យផលក្នុងបវត្តិកាល ដើម្បីទទួលឥដ្ឋារម្មណ៍(អារម្មណ៍ជាទីពេញចិត្ត ឥដ្ឋារម្មណ៍ មាន ២ គឺ ១.សភាវឥដ្ឋារម្មណ៍ បានដល់អារម្មណ៍ដែលល្អ ដែលគួរត្រេកអរ គួរប្រាថ្នាដោយសភាវៈ ដូចរូប សំឡេង ក្លិន រស ផោដ្ឋព្វជាដើមដែលល្អ ជាអារម្មណ៍ដែលគួរត្រេកអរដល់ជនទូទៅ។ ២.បរិកប្បិដ្ឋារម្មណ៍ បានដល់អារម្មណ៍ដែលគួរត្រេកអរ គួរប្រាថ្នាចំពោះសត្វ ឬចំពោះបុគ្គល មិនទូទៅដល់សត្វ និងបុគ្គលទាំងអស់ទេ ជាអារម្មណ៍ដែលល្អ ដែលពេញចិត្តតែចំពោះខ្លួនប៉ុណ្ណោះ។)តាមបញ្ចទ្វារ។

១-ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ អសង្ខារិកំ អហេតុកកុសលវិបាកំ. អហេតុកកុសលវិបាកចក្ខុវិញ្ញាណកើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យចក្ខុប្រសាទឃើញនូវរូបដែលល្អ មិនមានការបបួលដឹកនាំ។

២-ឧបេក្ខាសហគតំ សោតវិញ្ញាណំ អសង្ខារិកំ អហេតុកកុសលវិបាកំ. អហេតុក

កុសលវិបាកសោតវិញ្ញាណកើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យសោតប្រសាទឮសំឡេងដែលល្អ មិនមានការបបួលដឹកនាំ។

៣-ឧបេក្ខាសហគតំ ឃានវិញ្ញាណំ អសង្ខារិកំ អហេតុកកុសលវិបាកំ. អហេតុក-កុសលវិបាកឃានវិញ្ញាណកើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យឃានប្រសាទធុំក្លិនដែលល្អ មិនមានការបបួលដឹកនាំ។

៤-ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណំ អសង្ខារិកំ អហេតុកកុសលវិបាកំ. អហេតុកកុសលវិបាកជិវ្ហាវិញ្ញាណកើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យជិវ្ហាប្រសាទស្រូបរសដែលល្អ មិនមានការបបួលដឹកនាំ។

៥-សុខសហគតំ កាយវិញ្ញាណំ អសង្ខារិកំ អហេតុកកុសលវិបាកំ. អហេតុកកុសលវិបាកកាយវិញ្ញាណកើតឡើងព្រមដោយសុខវេទនា អាស្រ័យកាយប្រសាទប៉ះខ្ទប់សម្ផស្សដែលល្អ មិនមានការបបួលដឹកនាំ។

៦-ឧបេក្ខាសហគតំ សម្បដិច្ឆន្នចិត្តំ អសង្ខារិកំ អហេតុកកុសលវិបាកំ. អហេតុកកុសលវិបាកសម្បដិច្ឆន្នចិត្តកើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យហទយរូបទទួលនូវបញ្ចារម្មណ៍ដែលល្អ មិនមានការបបួលដឹកនាំ។

៧-សោមនស្សសហគតំ សន្តីរណចិត្តំ អសង្ខារិកំ អហេតុកកុសលវិបាកំ. អហេតុកកុសលវិបាកសន្តីរណចិត្តកើតឡើងព្រមដោយសោមនស្សវេទនា អាស្រ័យហទយរូប ពិចារណានូវបញ្ចារម្មណ៍ដែលល្អក្រៃលែង មិនមានការបបួលដឹកនាំ។

៨-ឧបេក្ខាសហគតំ សន្តីរណចិត្តំ អសង្ខារិកំ អហេតុកកុសលវិបាកំ. អហេតុកកុសលវិបាកសន្តីរណចិត្តកើតឡើងព្រមដោយឧបេក្ខាវេទនា អាស្រ័យហទយរូបពិចារណានូវបញ្ចារម្មណ៍ដែលល្អ មិនមានការបបួលដឹកនាំ។

សោមនស្សសន្តីរណចិត្ត ធ្វើនាទីពិចារណាអារម្មណ៍ក្នុងផ្នែកកុសលវិបាក មាន ២ ប្រភេទគឺ: ឥដ្ឋមជ្ឈត្តារម្មណ៍ បានដល់អារម្មណ៍ដែលល្អធម្មតា ១ និងអតិឥដ្ឋា-រម្មណ៍បានដល់អារម្មណ៍ដែលល្អក្រៃលែង ១។ សន្តីរណចិត្តដែលកើតព្រមនឹងឧបេ-ក្ខាវេទនាទទួលអាម្មណ៍ដែលល្អតអំពីសម្បដិច្ឆន្នចិត្ត ហើយក៏ធ្វើការពិចារណា ឬត្រិះរិះពិនិត្យអារម្មណ៍ហើយក៏រលត់ទៅ។ សន្តីរណចិត្តដែលកើតព្រមនឹងសោមន-

ស្សវេទនានោះ ជាវិបាកដែលកើតឡើងពិចារណាអារម្មណ៍ដែលល្អក្រៃលែង ព្រោះជាផលរបស់កុសលកម្មដែលល្អក្រៃលែង ធ្វើការពិចារណាអារម្មណ៍ដែលល្អក្រៃលែងនោះ ហើយក៏រលត់ទៅដូចគ្នា៕

### -អហេតុកកិរិយាចិត្ត ៣ ដួង:

អហេតុកកិរិយាចិត្ត មិនមែនជាកុសលចិត្ត មិនមែនជាអកុសលចិត្ត មិនមែនជាវិបាកចិត្ត ជាចិត្តអព្យាកត។

១-ឧបេក្ខាសហគតំ បញ្ចទ្វារាវជ្ជនចិត្តំ អសង្ខារិកំ អហេតុកកិរិយា. អហេតុកកិរិយាបញ្ចទ្វារាវជ្ជនចិត្តកើតឡើងព្រមដោយឧបេក្ខាវេទនា រាវរកអារម្មណ៍តាមបញ្ចទ្វារ មិនមានការបបួលដឹកនាំ។

២-ឧបេក្ខាសហគតំ មនោទ្វារាវជ្ជនចិត្តំ អសង្ខារិកំ អហេតុកកិរិយា. អហេតុកកិរិយាមនោទ្វារាវជ្ជនចិត្តកើតឡើងព្រមដោយឧបេក្ខាវេទនា រាវរកអារម្មណ៍តាមមនោទ្វារ មិនមានការបបួលដឹកនាំ។

៣-សោមនស្សសហគតំ ហសិតុប្បាទចិត្តំ អសង្ខារិកំ អហេតុកកិរិយា. អហេតុកកិរិយាហសិតុប្បាទចិត្តកើតឡើងព្រមដោយសោមនស្សវេទនា ធ្វើការញញឹមរបស់ព្រះអរហន្តមិនមានការបបួលដឹកនាំ។

### ~កាមាវចរសោភណចិត្ត ២៤ ដួង:

មហាកុសលចិត្ត ៨ ដួង + មហាវិបាកចិត្ត ៨ ដួង + មហាកិរិយាចិត្ត ៨ ដួង។

សោភណចិត្ត ជាចិត្តដែលមានសោភណចេតសិកប្រកបជាមួយ ជាចិត្តល្អ ស្អាតផុតពីមន្ទិល គឺកិលេសជាដើម។

### -មហាកុសលចិត្ត ៨ ដួង:

១-សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ. មហាកុសលចិត្តកើតឡើងព្រមដោយសោមនស្សវេទនា ប្រកបដោយបញ្ញា(ញាណសម្បយុត្តំ) មិនមានការបបួលដឹកនាំ។

២-សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ. មហាកុសលចិត្តកើតឡើងព្រមដោយសោមនស្សវេទនា ប្រកបដោយបញ្ញា មានការបបួលដឹកនាំ។

៣-សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ. មហាកុសលចិត្តកើតឡើងព្រមដោយសោមនស្សវេទនា ប្រាសចាកបញ្ញា(ញាណវិប្បយុត្តំ) មិនមានការបបួលដឹកនាំ។

៤-សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ. មហាកុសលចិត្តកើតឡើងព្រមដោយសោមនស្សវេទនា ប្រាសចាកបញ្ញា មានការបបួលដឹកនាំ។

៥-ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ. មហាកុសលចិត្តកើតឡើងព្រមដោយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មិនមានការបបួលដឹកនាំ។

៦-ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ. មហាកុសលចិត្តកើតឡើងព្រមដោយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានការបបួលដឹកនាំ។

៧-ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ. មហាកុសលចិត្តកើតឡើងព្រមដោយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មិនមានការបបួលដឹកនាំ។

៨-ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ. មហាកុសលចិត្តកើតឡើងព្រមដោយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានការបបួលដឹកនាំ។

មហាកុសលញាណវិប្បយុត្តចិត្ត ៤ ប្រកបដោយហេតុ ២ គឺ អលោភហេតុ និងអទោសហេតុហៅថា ទ្វិហេតុកចិត្ត ការធ្វើកុសលណាៗក៏ដោយ មានការឲ្យទានរក្សាសីលជាដើម ការដែលកុសលនោះនឹងកើតឡើងបាន ព្រោះខណៈនោះមិនមានលោភៈ មិនមានទោសៈ បើនៅមានលោភក៏លំបាកនឹងលះបង់ទ្រព្យរបស់ខ្លួនឲ្យជាទានបាន ឬកាលកំពុងក្រោធក៏លំបាកនឹងលះបង់ដូចគ្នា។ ចំណែកមហាកុសលញាណសម្បយុត្តចិត្ត ៤ ប្រកបដោយហេតុ ៣ គឺ អលោភហេតុ អទោសហេតុ និងអមោហ(បញ្ញា)ហេតុ ហៅថា តិហេតុកចិត្ត ការធ្វើកុសលណាៗដែលប្រកបដោយបញ្ញារមែងជាកុសលដ៏ប្រសើរបំផុត។

*ចេតនា ៣ យ៉ាង:

១-បុព្វចេតនា: ចេតនាមុនធ្វើ គឺចិត្តជ្រះថ្លាក្នុងបុញ្ញកិរិយាដែលនឹងធ្វើនោះ។

២-មុញ្ចនចេតនា: ចេតនាកំពុងធ្វើ គឺចិត្តជ្រះថ្លាក្នុងបុញ្ញកិរិយាដែលកំពុងធ្វើនោះ។

៣-អបរចេតនា និង អបរាបរចេតនា: ចេតនាពេលធ្វើរួចហើយ។

-អបរចេតនា: ចេតនាពេលធ្វើរួចហើយ គឺចិត្តជ្រះថ្លាក្នុងបុញ្ញកិរិយាដែលធ្វើរួចនោះ។

-អបរាបរចេតនា: បុញ្ញកិរិយាដែលធ្វើរួចហើយ ទោះជាកន្លងទៅ ១ ខែ ១ ឆ្នាំ ១០ ឆ្នាំក្ដី តែងរឭកដល់បុណ្យនោះៗកើតសេចក្ដីជ្រះថ្លារឿយៗ កុសលកើតទៀតរឿយៗ។

*បុញ្ញកិរិយាវត្ថុ (ចេតនាចេតសិកក្នុងកាមាវចរកុសលចិត្ត ៨ ដួងរមែងសម្រេចជាកុសលកម្ម) ១០ យ៉ាង:

បុញ្ញ(បុណ្យ) ធម្មជាតិណា រមែងជម្រះ គឺរមែងញុំាងសន្តានរបស់ខ្លួនឲ្យបរិសុទ្ធ។

១-ទានមយ: បុណ្យសម្រេចពីការធ្វើទាន គឺការបរិច្ចាគទ្រព្យឲ្យជាប្រយោជន៍ដល់អ្នកដទៃ។

២-សីលមយ: បុណ្យសម្រេចពីការរក្សាសីល គឺវៀរទុច្ចរិតកម្ម។

៣-ភាវនាមយ: បុណ្យសម្រេចពីការចម្រើនសមថ និងវិបស្សនា។

៤-អបចាយនមយ: បុណ្យសម្រេចពីការគោរព ធ្វើសក្ការដល់បុគ្គលដែលគួរគោរព។

៥-វេយ្យាវច្ចមយ: បុណ្យសម្រេចពីការជួយធ្វើកិច្ចការនៃកុសលធម៌ទាំងឡាយ ។

៦-បត្តិទានមយ: បុណ្យសម្រេចពីការឧទ្ទិសចំណែកបុណ្យដែលខ្លួនបានធ្វើហើយឲ្យដល់អ្នកដទៃ។

៧-បត្តានុមោទនាមយ: បុណ្យសម្រេចពីការអនុមោទនា។

៨-ទេសនាមយ: បុណ្យសម្រេចពីការសម្ដែងព្រះធម៌។

៩-សវនមយ: បុណ្យសម្រេចពីការស្ដាប់ព្រះធម៌។

១០-ទិដ្ឋុជុកម្មមយៈ បុណ្យសម្រេចពីការធ្វើទិដ្ឋិឲ្យត្រឹមត្រូវល្អ(តម្រង់ពីការយល់ខុសមកឃើញត្រូវតាមធម៌ពិតវិញ)។

## -មហាវិបាកចិត្ត ៨ ដួងៈ

មហាកុសលចិត្ត ៨ ជាបច្ច័យឲ្យផលជាសហេតុកមហាវិបាកចិត្ត ៨ និងអហេតុកកុសលវិបាកចិត្ត ៨ ទៀត រួមជាកុសលវិបាកចិត្ត ១៦។ អហេតុកកុសល-វិបាក ឧបេក្ខាសន្តីរណចិត្ត ១ ធ្វើបដិសន្ធិកិច្ចក្នុងមនុស្សភូមិ ១ ក្នុងចាតុម្មហារាជិកា-ភូមិ ១ ក្នុងបវត្តិកាលអហេតុកកុសលវិបាកចិត្ត ៨ កើតឡើងទទួលផលរបស់កុសលកម្មក្នុងកាមភូមិ ១១ ក្នុងរូបភូមិ ១៥(វៀរអសញ្ញសត្តាភូមិ)តាមសមគួរដល់ទ្វារ និងអារម្មណ៍។ ចំណែកសហេតុកមហាវិបាកចិត្តទាំង ៨ នោះឲ្យផលកើតបានក្នុងសុគតិភូមិ ៧ ជាន់ប៉ុណ្ណោះ គឺឲ្យផលបដិសន្ធិក្នុងបដិសន្ធិកាល ក្នុងបវត្តិកាលជាភវង្គកិច្ច និងតទាលម្ពណកិច្ច៕

១-សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ. មហាវិបាកចិត្តកើតឡើងព្រមដោយសោមនស្សវេទនា ប្រកបដោយបញ្ញា មិនមានការបបួលដឹកនាំ។

២-សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ. មហាវិបាកចិត្តកើតឡើងព្រមដោយសោមនស្សវេទនា ប្រកបដោយបញ្ញា មានការបបួលដឹកនាំ។

៣-សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ. មហាវិបាកចិត្តកើតឡើងព្រមដោយសោមនស្សវេទនា ប្រាសចាកបញ្ញា មិនមានការបបួលដឹកនាំ។

៤-សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ. មហាវិបាកចិត្តកើតឡើងព្រមដោយសោមនស្សវេទនា ប្រាសចាកបញ្ញា មានការបបួលដឹកនាំ។

៥-ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ. មហាវិបាកចិត្តកើតឡើងព្រមដោយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មិនមានការបបួលដឹកនាំ។

៦-ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ. មហាវិបាកចិត្ត

កើតឡើងព្រមដោយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានការបបួលដឹកនាំ។

៧-ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ. មហាវិបាកចិត្ត កើតឡើងព្រមដោយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មិនមានការបបួលដឹកនាំ។

៨-ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ. មហាវិបាកចិត្ត កើតឡើងព្រមដោយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានការបបួលដឹកនាំ។

មហាវិបាកចិត្ត ៨ រមែងចែកសត្វឲ្យប្រព្រឹត្តទៅតាមកម្ម គឺបដិសន្ធិក្នុងកាមសុគតិភូមិ ៧ តាមសមគួរដល់កម្លាំងរបស់មហាកុសលចិត្តនោះ និងធ្វើសត្វឲ្យផ្សេងគ្នា សូម្បីកើតក្នុងភូមិតែមួយក៏ដោយ ក៏ការដែលកម្មចែកសត្វឲ្យផ្សេងគ្នានោះ គឺព្រោះកិលេស និងកម្លាំងសទ្ធាជាដើមក្នុងអតីតកាល។ សូម្បីក្នុងការឲ្យទានដូចគ្នាក៏វិបាករបស់ទាននោះអាចញុំាងសត្វឲ្យកើតក្នុងទីផ្សេងៗគ្នាដល់ ៧ កន្លែង៕

***មហាវិបាកចិត្តចែកសត្វឲ្យផ្សេងគ្នា ៧ កន្លែង:**

១-អ្នកណាឲ្យទាន ដោយប្រាថ្នាផលតបមកវិញយ៉ាងណាមួយក្នុងភពខាងមុខ កាលស្លាប់ហើយ នឹងកើតជាទេវតាជាន់ចាតុម្មហារាជិកា។

២-អ្នកណាឲ្យទាន ដោយមិនប្រាថ្នាផលតបមកវិញក្នុងភពខាងមុខទេ គឺឲ្យដោយគិតថា ការឲ្យទានជាការល្អ កាលស្លាប់ហើយ នឹងកើតជាទេវតាជាន់តាវត្តិង្ស។

៣-អ្នកណាឲ្យទាន ដោយគិតថា មាតា បិតា យាយ តា ធ្លាប់ធ្វើមកហើយ គួរធ្វើតទៅ មិនឲ្យខូចប្រពៃណី កាលស្លាប់ហើយ នឹងកើតជាទេវតាជាន់យាមា។

៤-អ្នកណាឲ្យទាន ដោយមេត្តា ប្រាថ្នានឹងឲ្យអ្នកទទួលទានមានសេចក្ដីសុខ មិនមានសេចក្ដីលំបាក កាលស្លាប់ហើយ នឹងកើតជាទេវតាជាន់តុសិត។

៥-អ្នកណាឲ្យទាន ដើម្បីបដិបត្តិតាមអ្នកប្រាជ្ញ អ្នកឲ្យទានកន្លងមកពីកាលមុន កាលស្លាប់ហើយ នឹងកើតជាទេវតាជាន់និម្មានរតី។

៦-អ្នកណាឲ្យទាន ដោយឃើញថា កាលឲ្យទានហើយ នឹងធ្វើចិត្តឲ្យសោមនស្ស កើតសេចក្ដីជ្រះថ្លា កាលស្លាប់ហើយ នឹងកើតជាទេវតាជាន់បរនិម្មិតវសវត្តី។

៧-អ្នកណាឲ្យទាន ដើម្បីជម្រះចិត្តឲ្យផូរផង់ បានឈាន កាលស្លាប់ហើយ នឹងកើតក្នុងព្រហ្មលោក។

*កុសលកម្មឲ្យផលផ្សេងគ្នា ៧ យ៉ាង:

១-មានអាយុវែង: ព្រោះមិនសម្លាប់សត្វ។

២-មានរោគតិច: ព្រោះមិនបៀតបៀនសត្វ។

៣-មានសម្បុរល្អ: ព្រោះមិនក្រោធ។

៤-មានសក្តិធំ: ព្រោះមិនច្រណែនក្នុងលាភជាដើមរបស់អ្នកដទៃ។

៥-មានភោគច្រើន: ព្រោះជាអ្នកឲ្យទានច្រើន។

៦កើតក្នុងត្រកូលខ្ពស់: ព្រោះជាអ្នកមិនរឹងត្អឹង ចេះគោរព។

៧-មានបញ្ញាច្រើន: ព្រោះសាកសួរ និងសិក្សាធម៌។

-មហាកិរិយាចិត្ត ៨ ដួង:

មហាកិរិយាចិត្ត មិនមែនជាកុសលចិត្ត មិនមែនជាអកុសលចិត្ត មិនមែនជាវិបាកចិត្ត ជាចិត្តអព្យាកត គឺត្រឹមតែការធ្វើកិច្ច មិនដល់ភាពជាជវន ឬដល់ភាពជាជវនក្តី កិរិយាចិត្តនោះក៏មិនមានផល។

១-សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ. មហាកិរិយាចិត្តកើតឡើងព្រមដោយសោមនស្សវេទនា ប្រកបដោយបញ្ញា មិនមានការបបួលដឹកនាំ។

២-សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ. មហាកិរិយាចិត្តកើតឡើងព្រមដោយសោមនស្សវេទនា ប្រកបដោយបញ្ញា មានការបបួលដឹកនាំ។

៣-សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ. មហាកិរិយាចិត្តកើតឡើងព្រមដោយសោមនស្សវេទនា ប្រាសចាកបញ្ញា មិនមានការបបួល

ដឹកនាំ។

៤-សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ. មហាកិរិយាចិត្តកើតឡើងព្រមដោយសោមនស្សវេទនា ប្រាសចាកបញ្ញា មានការបបួលដឹកនាំ។

៥-ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ. មហាកិរិយាចិត្តកើតឡើងព្រមដោយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មិនមានការបបួលដឹកនាំ។

៦-ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ. មហាកិរិយាចិត្តកើតឡើងព្រមដោយឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានការបបួលដឹកនាំ។

៧-ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ. មហាកិរិយាចិត្តកើតឡើងព្រមដោយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មិនមានការបបួលដឹកនាំ។

៨-ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ. មហាកិរិយាចិត្តកើតឡើងព្រមដោយឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានការបបួលដឹកនាំ។

មហាកិរិយាចិត្តរបស់ព្រះអរហន្តដែលកើតព្រមដោយសោមនស្សវេទនា រមែងកើតក្នុងបញ្ចទ្វារ និងមនោទ្វារដែលរមែងកើតឡើងព្រោះប្រារព្ធអតីត និងអនាគត។ រីឯឧបេក្ខាវេទនា រមែងប្រកដក្នុងខណដែលលោកពិចារណាអារម្មណ៍ដែលមកប៉ះខ្ទប់ក្នុងទ្វារទាំង ៦ ដោយឆឡង្គុបេក្ខាមិនមានសេចក្តីញាប់ញ័រ៕

## +រូបាវចរសោភណចិត្ត ១៥ ដួង:

រូបាវចរកុសលចិត្ត ៥ ដួង + រូបាវចរវិបាកចិត្ត ៥ ដួង + រូបាវចរកិរិយាចិត្ត ៥ ដួង។

សោភណចិត្តដែលត្រាច់ទៅក្នុងរូបភព បានដល់រូបជ្ឈានដែលជាកុសលស្ងប់ចាកកាម ស្ងប់ចាកអកុសលធម៌ទាំងឡាយ។

## -រូបាវចរកុសលចិត្ត ៥ ដួង:

ចិត្តប្រព្រឹត្តទៅជាមួយធម៌: វិតក្ក វិចារ បីតិ សុខ ឯកគ្គតា។

១-វិតក្កវិចារបីតិសុខេកគ្គតាសហិតំ សសង្ខារិកំ បឋមជ្ឈានកុសលចិត្តំ. បឋមជ្ឈានកុសលចិត្តប្រកបដោយអង្គ វិតក្ក វិចារ បីតិ សុខ ឯកគ្គតា មានការបបួលដឹកនាំ។

២-វិចារបីតិសុខេកគ្គតាសហិតំ សសង្ខារិកំ ទុតិយជ្ឈានកុសលចិត្តំ. ទុតិយជ្ឈានកុសលចិត្តប្រកបដោយអង្គ វិចារ បីតិ សុខ ឯកគ្គតា មានការបបួលដឹកនាំ។

៣-បីតិសុខេកគ្គតាសហិតំ សសង្ខារិកំ តតិយជ្ឈានកុសលចិត្តំ. តតិយជ្ឈានកុសលចិត្តប្រកបដោយអង្គ បីតិ សុខ ឯកគ្គតា មានការបបួលដឹកនាំ។

៤-សុខេកគ្គតាសហិតំ សសង្ខារិកំ ចតុត្ថជ្ឈានកុសលចិត្តំ. ចតុត្ថជ្ឈានកុសលចិត្តប្រកបដោយអង្គ សុខ ឯកគ្គតា មានការបបួលដឹកនាំ។

៥-ឧបេក្ខេកគ្គតាសហិតំ សសង្ខារិកំ បញ្ចមជ្ឈានកុសលចិត្តំ. បញ្ចមជ្ឈានកុសលចិត្តប្រកបដោយអង្គ ឧបេក្ខា ឯកគ្គតា មានការបបួលដឹកនាំ។

### -រូបាវចរវិបាកចិត្ត ៥ ដួង:

រូបាវចរកុសលចិត្ត ជាហេតុឲ្យកើតរូបាវចរវិបាកចិត្តដែលធ្វើបដិសន្ធិក្នុងរូបភព។

១-វិតក្កវិចារបីតិសុខេកគ្គតាសហិតំ សសង្ខារិកំ បឋមជ្ឈានវិបាកចិត្តំ. បឋមជ្ឈានវិបាកចិត្តប្រកបដោយអង្គ វិតក្ក វិចារ បីតិ សុខ ឯកគ្គតា មានការបបួលដឹកនាំ។

២-វិចារបីតិសុខេកគ្គតាសហិតំ សសង្ខារិកំ ទុតិយជ្ឈានវិបាកចិត្តំ. ទុតិយជ្ឈានវិបាកចិត្តប្រកបដោយអង្គ វិចារ បីតិ សុខ ឯកគ្គតា មានការបបួលដឹកនាំ។

៣-បីតិសុខេកគ្គតាសហិតំ សសង្ខារិកំ តតិយជ្ឈានវិបាកចិត្តំ. តតិយជ្ឈានវិបាកចិត្តប្រកបដោយអង្គ បីតិ សុខ ឯកគ្គតា មានការបបួលដឹកនាំ។

៤-សុខេកគ្គតាសហិតំ សសង្ខារិកំ ចតុត្ថជ្ឈានវិបាកចិត្តំ. ចតុត្ថជ្ឈានវិបាកចិត្តប្រកបដោយអង្គ សុខ ឯកគ្គតា មានការបបួលដឹកនាំ។

៥-ឧបេក្ខេកគ្គតាសហិតំ សសង្ខារិកំ បញ្ចមជ្ឈានវិបាកចិត្តំ. បញ្ចមជ្ឈានវិបាចិត្តប្រកបដោយអង្គ ឧបេក្ខា ឯកគ្គតា មានការបបួលដឹកនាំ។

### -រូបាវចរកិរិយាចិត្ត ៥ ដួង:

រូបាវចរកិរិយាចិត្ត ជារូបជ្ឈានចិត្តរបស់ព្រះខីណាស្រពដែលមិនមានកម្មវិបាកនោះទេ ជាទិដ្ឋធម្មសុខវិហារធម៌ គឺដើម្បីនៅជាសុខក្នុងបច្ចុប្បន្នប៉ុណ្ណោះ។

១-វិតក្កវិចារបីតិសុខេកគ្គតាសហិតំ សសង្ខារិកំ បឋមជ្ឈានកិរិយាចិត្តំ. បឋមជ្ឈានកិរិយាចិត្តប្រកបដោយអង្គ វិតក្ក វិចារ បីតិ សុខ ឯកគ្គតា មានការបបួលដឹកនាំ។

២-វិចារបីតិសុខេកគ្គតាសហិតំ សសង្ខារិកំ ទុតិយជ្ឈានកិរិយាចិត្តំ. ទុតិយជ្ឈានកិរិយាចិត្តប្រកបដោយអង្គ វិចារ បីតិ សុខ ឯកគ្គតា មានការបបួលដឹកនាំ។

៣-បីតិសុខេកគ្គតាសហិតំ សសង្ខារិកំ តតិយជ្ឈានកិរិយាចិត្តំ. តតិយជ្ឈានកិរិយាចិត្តប្រកបដោយអង្គ បីតិ សុខ ឯកគ្គតា មានការបបួលដឹកនាំ។

៤-សុខេកគ្គតាសហិតំ សសង្ខារិកំ ចតុត្ថជ្ឈានកិរិយាចិត្តំ. ចតុត្ថជ្ឈានកិរិយាចិត្តប្រកបដោយអង្គ សុខ ឯកគ្គតា មានការបបួលដឹកនាំ។

៥-ឧបេក្ខេកគ្គតាសហិតំ សសង្ខារិកំ បញ្ចមជ្ឈានកិរិយាចិត្តំ. បញ្ចមជ្ឈានកិរិយាចិត្តប្រកបដោយអង្គ ឧបេក្ខា ឯកគ្គតា មានការបបួលដឹកនាំ។

**+អរូបាវចរសោភណចិត្ត ១២ ដួង:**

អរូបាវចរចិត្ត ចាត់តាមអារម្មណ៍ មាន ៤ ប្រការ។

**-អរូបាវចរកុសលចិត្ត ៤ ដួង:**

អរូបាវចរកុសលចិត្ត ជាអ្នកតាក់តែងជាតិ ភព សម្បត្តិ ធ្វើជវនកិច្ច។

១-អាកាសានញ្ចាយតនកុសលចិត្តំ ជាអាកាសានញ្ចាយតនកុសលចិត្ត។

២-វិញ្ញាណញ្ចាយតនកុសលចិត្តំ ជាវិញ្ញាណញ្ចាយតនកុសលចិត្ត។

៣-អាកិញ្ចញ្ញាយតនកុសលចិត្តំ ជាអាកិញ្ចញ្ញាយតនកុសលចិត្ត។

៤-នេវសញ្ញានាសញ្ញាយតនកុសលចិត្តំ ជានេវសញ្ញានាសញ្ញាយតនកុសលចិត្ត។

**-អរូបាវចរវិបាកចិត្ត ៤ ដួង:**

អរូបាវចរវិបាកចិត្ត ជាផលរបស់អរូបាវចរកុសលចិត្ត នៅពេលមុននឹងចុតិចិត្តកើតឡើងនោះ អរូបាវចរកុសលចិត្តណាមួយកើតឡើងមុនហើយទើបចុតិ កាលចុតិចិត្តរលត់ហើយ អរូបាវចរវិបាកចិត្តណាមួយក៏កើតឡើងធ្វើកិច្ចបដិសន្ធិបន្ទាប់ពីចុតិ

នោះភ្លាម។

១-អាកាសានញ្ចាយតនវិបាកចិត្តំ ជាអាកាសានញ្ចាយតនវិបាកចិត្ត។

២-វិញ្ញាណញ្ចាយតនវិបាកចិត្តំ ជាវិញ្ញាណញ្ចាយតនវិបាកចិត្ត។

៣-អាកិញ្ចញ្ញាយតនវិបាកចិត្តំ ជាអាកិញ្ចញ្ញាយតនវិបាកចិត្ត។

៤-នេវសញ្ញានាសញ្ញាយតនវិបាកចិត្តំ ជានេវសញ្ញានាសញ្ញាយតនវិបាកចិត្ត។

### *ចុតិចិត្ត និង បដិសន្ធិចិត្ត:

ចុតិចិត្ត ជាចិត្តដួងចុងក្រោយបញ្ចប់ជីវិតឃ្លាតចាកភព ជាតិ សភាពជាបុគ្គលភ្លាម បដិសន្ធិចិត្តក៏កើតឡើងក្នុងភពថ្មី។ ចុតិចិត្តជាវិបាករបស់ឧបេក្ខាសន្តីរណ-អហេតុកអកុសលវិបាកចិត្ត ១ ដួងដឹកនាំឲ្យបដិសន្ធិក្នុងអបាយភូមិ ទោសនាំឲ្យកើតជាសត្វនរក លោភនាំឲ្យកើតជាប្រេត មោហនាំឲ្យកើតជាតិរច្ឆាន ទិដ្ឋិមានះនាំឲ្យកើតជាអសុរកាយ រីឯឧបេក្ខាសន្តីរណអហេតុកកុសលវិបាកចិត្ត ១ ដួងជាផលនៃកុសលកម្មមានកម្លាំងខ្សោយដឹកនាំឲ្យបដិសន្ធិក្នុងភពមនុស្ស និងចាតុម្មហារាជិកា។ មហាវិបាកចិត្ត ៨ ដួងដឹកនាំឲ្យបដិសន្ធិក្នុងភូមិមនុស្ស និងទេវលោក ៦ ឋានផ្សេងៗគ្នាតាមកម្លាំងរបស់កុសលកម្ម។ រូបាវចរវិបាកចិត្ត ៥ ដួងដឹកនាំឲ្យបដិសន្ធិក្នុងរូបព្រហ្មភូមិ អរូបាវចរវិបាកចិត្ត ៤ ដួងដឹកនាំឲ្យបដិសន្ធិក្នុងអរូបព្រហ្មភូមិ។ បុគ្គលខ្លះកើតក្នុងមនុស្សភូមិ ដែលជាកុសលវិបាកធ្វើកិច្ចបដិសន្ធិមិនមានបញ្ញាចេតសិកកើតរួមនឹងជាកុសលកម្មយ៉ាងខ្សោយបំផុត កុសលវិបាកដែលធ្វើកិច្ចបដិសន្ធិនោះ ទើបមិនប្រកបដោយសោភណចេតសិក គឺអលោភ និងអទោស ហើយមានអកុសលកម្មបៀតបៀនធ្វើឲ្យជាបុគ្គលពិការ ខ្វាក់ ខ្វិន គ ថ្លង់ ខ្ចើយ វិកលចរិតជាដើមតាំងពីកំណើត។ បើបដិសន្ធិចិត្តជាផលរបស់កុសលកម្មដែលប្រកបដោយបញ្ញាចេតសិកយ៉ាងខ្សោយ ឬមិនមានបញ្ញាចេតសិកកើតរួម ជាបដិសន្ធិចិត្តដែលកើតរួមសោភណចេតសិក មានហេតុ ២ គឺ: អលោភ និងអទោស ជាទ្វិហេតុកបុគ្គល ទ្វិហេតុកបុគ្គលមិនអាចទន្លុះឈាន ឬលោកុត្តរធម៌ក្នុងជាតិនេះបានឡើយ។ បើបដិសន្ធិចិត្តជាផលរបស់កុសលកម្មដែលប្រកបដោយបញ្ញាហៅថា តិហេតុកបុគ្គល ព្រោះមានហេតុ ៣ គឺ: អលោភ អទោស និងអមោហ(បញ្ញា)កើតរួម តិហេតុកបុគ្គលកាលបាន

ស្តាប់ព្រះធម៌ក៏អាចពិចារណាយល់ព្រះធម៌ ហើយអាចអប់រំចិត្តចម្រើនបញ្ញារហូតដល់ទម្លុះឈានចិត្ត ឬឃើញច្បាស់ ដឹងច្បាស់នូវអរិយសច្ចធម៌ ៤ យ៉ាងទម្លុះមគ្គផលក្នុងជាតិនេះបាន៕

### -អរូបាវចរកិរិយាចិត្ត ៤ ដួង:

អរូបាវចរកិរិយាចិត្តនេះកើតដល់ព្រះអរហន្តប៉ុណ្ណោះ ព្រោះលោកចម្រើនឈាននេះប្រព្រឹត្តទៅជាគុណធម៌ដោយមិនមានកម្មវិបាក។

១-អាកាសានញ្ចាយតនកិរិយាចិត្តំ ជាអាកាសានញ្ចាយតនកិរិយាចិត្ត។

២-វិញ្ញាណញ្ចាយតនកិរិយាចិត្តំ ជាវិញ្ញាណញ្ចាយតនកិរិយាចិត្ត។

៣-អាកិញ្ចញ្ញាយតនកិរិយាចិត្តំ ជាអាកិញ្ចញ្ញាយតនកិរិយាចិត្ត។

៤-នេវសញ្ញានាសញ្ញាយតនកិរិយាចិត្តំ ជានេវសញ្ញានាសញ្ញាយតនកិរិយាចិត្ត។

## ~លោកុត្តរសោភណចិត្ត:

### -លោកុត្តរកុសលចិត្ត ៤ ដួង:

សោតាបត្តិមគ្គចិត្តំ ១ សកទាគាមិមគ្គចិត្តំ ១ អនាគាមិមគ្គចិត្តំ ១ អរហត្តមគ្គចិត្តំ ១។

### -លោកុត្តរវិបាកចិត្ត ៤ ដួង:

សោតាបត្តិផលចិត្តំ ១ សកទាគាមិផលចិត្តំ ១ អនាគាមិផលចិត្តំ ១ អរហត្តផល-ចិត្តំ ១។

### -លោកុត្តរចិត្ត ៤០ ដួង:

១-សោតាបត្តិមគ្គចិត្ត ៥: បឋមជ្ឈានសោតាបត្តិមគ្គចិត្ត ១ ទុតិយជ្ឈានសោតាបត្តិ-មគ្គចិត្ត ១ តតិយជ្ឈានសោតាបត្តិមគ្គចិត្ត ១ ចតុត្ថជ្ឈានសោតាបត្តិមគ្គចិត្ត ១ បញ្ចមជ្ឈានសោតាបត្តិមគ្គចិត្ត ១។

២-សោតាបត្តិផលចិត្ត ៥: បឋមជ្ឈានសោតាបត្តិផលចិត្ត ១ ទុតិយជ្ឈានសោតាបត្តិ-ផលចិត្ត ១ តតិយជ្ឈានសោតាបត្តិផលចិត្ត ១ ចតុត្ថជ្ឈានសោតាបត្តិផលចិត្ត ១

បញ្ចមជ្ឈានសោតាបត្តិផលចិត្ត ១។

៣-សកទាគាមិមគ្គចិត្ត ៥: បឋមជ្ឈានសកទាគាមិមគ្គចិត្ត ១ ទុតិយជ្ឈានសកទាគាមិមគ្គចិត្ត ១ តតិយជ្ឈានសកទាគាមិមគ្គចិត្ត ១ ចតុត្ថជ្ឈានសកទាគាមិមគ្គចិត្ត ១ បញ្ចមជ្ឈានសកទាគាមិមគ្គចិត្ត ១។

៤-សកទាគាមិផលចិត្ត ៥: បឋមជ្ឈានសកទាគាមិផលចិត្ត ១ ទុតិយជ្ឈានសកទាគាមិផលចិត្ត ១ តតិយជ្ឈានសកទាគាមិផលចិត្ត ១ ចតុត្ថជ្ឈានសកទាគាមិផលចិត្ត ១ បញ្ចមជ្ឈានសកទាគាមិផលចិត្ត ១។

៥-អនាគាមិមគ្គចិត្ត ៥: បឋមជ្ឈានអនាគាមិមគ្គចិត្ត ១ ទុតិយជ្ឈានអនាគាមិមគ្គចិត្ត ១ តតិយជ្ឈានអនាគាមិមគ្គចិត្ត ១ ចតុត្ថជ្ឈានអនាគាមិមគ្គចិត្ត ១ បញ្ចមជ្ឈានអនាគាមិមគ្គចិត្ត ១។

៦-អនាគាមិផលចិត្ត ៥: បឋមជ្ឈានអនាគាមិផលចិត្ត ១ ទុតិយជ្ឈានអនាគាមិផលចិត្ត ១ តតិយជ្ឈានអនាគាមិផលចិត្ត ១ ចតុត្ថជ្ឈានអនាគាមិផលចិត្ត ១ បញ្ចមជ្ឈានអនាគាមិផលចិត្ត ១។

៧-អរហត្តមគ្គចិត្ត ៥: បឋមជ្ឈានអរហត្តមគ្គចិត្ត ១ ទុតិយជ្ឈានអរហត្តមគ្គចិត្ត ១ តតិយជ្ឈានអរហត្តមគ្គចិត្ត ១ ចតុត្ថជ្ឈានអរហត្តមគ្គចិត្ត ១ បញ្ចមជ្ឈានអរហត្តមគ្គចិត្ត ១។

៨-អរហត្តផលចិត្ត ៥: បឋមជ្ឈានអរហត្តផលចិត្ត ១ ទុតិយជ្ឈានអរហត្តផលចិត្ត ១ តតិយជ្ឈានអរហត្តផលចិត្ត ១ ចតុត្ថជ្ឈានអរហត្តផលចិត្ត ១ បញ្ចមជ្ឈានអរហត្តផលចិត្ត ១។

+**អាយតនៈ** (អាយតនក្នុង ៦ និងអាយតនក្រៅ ៦) **១២ គឺ**:

-អាយតនក្នុង គឺចក្ខាយតន សោតាយតន ឃានាយតន ជិវ្ហាយតន កាយាយតន និងមនាយតន។

-អាយតនក្រៅ គឺរូបាយតន សទ្ទាយតន គន្ធាយតន រសាយតន ផោដ្ឋព្វាយតន និងធម្មាយតន។

+អារម្មណ៍ ៦ គឺ:

រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ធម្មារម្មណ៍។

+ធាតុ ១៨ គឺ:

១-ចក្ខុធាតុ: បានដល់ភ្នែក។

២-សោតធាតុ: បានដល់ត្រចៀក។

៣-ឃានធាតុ: បានដល់ច្រមុះ។

៤-ជិវ្ហាធាតុ: បានដល់អណ្តាត។

៥-កាយធាតុ: បានដល់កាយ។

៦-មនោធាតុ: បានដល់បញ្ចទ្វារាវជ្ជនចិត្ត ១ និងសម្បដិច្ឆន្នចិត្តទាំង ២។

៧-រូបធាតុ: បានដល់រូប។

៨-សទ្ទធាតុ: បានដល់សំឡេង។

៩-គន្ធធាតុ: បានដល់ក្លិន។

១០-រសធាតុ: បានដល់រស។

១១-ផោដ្ឋព្វធាតុ: បានដល់សម្ផស្ស។

១២-ធម្មធាតុ: បានដល់ចេតសិកទាំង ៥២។

១៣-ចក្ខុវិញ្ញាណធាតុ: បានដល់ចក្ខុវិញ្ញាណ។

១៤-សោតវិញ្ញាណធាតុ: បានដល់សោតវិញ្ញាណ។

១៥-ឃានវិញ្ញាណធាតុ: បានដល់ឃានវិញ្ញាណ។

១៦-ជិវ្ហាវិញ្ញាណធាតុ: បានដល់ជិវ្ហាវិញ្ញាណ។

១៧-កាយវិញ្ញាណធាតុ: បានដល់កាយវិញ្ញាណ។

១៨-មនោវិញ្ញាណធាតុ: បានដល់ចិត្ត ៦៧ ដូចគឺ: មនោទ្វារាវជ្ជនចិត្ត ១, ជវនចិត្ត ៥៥, តទាលម្ពណចិត្ត ១១។ ជវនចិត្ត ៥៥: បានដល់អកុសលជវន ១២(អកុសលចិត្តទាំង ១២), កាមាវចរជវន ៨(មហាកុសលចិត្តទាំង ៨), កាមាវចរកិរិយាជវន ៨(មហា-កិរិយាចិត្តទាំង ៨), ហសិតុប្បាទជវន ១, មហគ្គតជវន ១៨(រូបាវចរកុសលចិត្ត ៥, អរូបាវចរកុសលចិត្ត ៤, រូបាវចរកិរិយាចិត្ត ៥, អរូបាវចរកិរិយាចិត្ត ៤), លោកុត្តរជវន ៨(មគ្គចិត្ត ៤ ផលចិត្ត ៤)៕

*បញ្ចទ្វារវិថី មានអារម្មណ៍បានត្រឹម ៥ គឺ:

រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍។

-ភវង្គ: ជាចិត្តដែលកើតរលត់បន្តគ្នាជាក្រសែ រក្សាអង្គភពឲ្យនៅជាសភាពបុគ្គលម្នាក់។ ចិត្តនេះបរិសុទ្ធមិនដឹងអារម្មណ៍តាមទ្វារទាំង ៦ គឺខណៈកំពុងដេកលក់ស៊ប់ មិនយល់សប្តិ គឺជាភវង្គចិត្ត ដោយហេតុថាមិនមានសេចក្តីដឹងខ្លួនថាស្រឡាញ់ ស្អប់ រីករាយ ទុក្ខសោក ព្រោះមិនឃើញ មិនឮ មិនដឹងសភាវដែលខ្ទប់សម្ផស្ស(ប៉ះពាល់ត្រូវ) មិននឹកគិតអ្វីៗទាំងអស់។ មួយខណៈចិត្ត មាន ៣ អនុខណៈ: ឧប្បាទ កើតឡើង ឋិតិ តាំងនៅ ភង្គ បែកធ្លាយ។

-អតីតភវង្គ: ភវង្គរបស់អតីត។ ក្នុងខណៈដែលរូបកើតឡើងប៉ះខ្ទប់នឹងបសាទរូប ហើយប៉ះខ្ទប់នឹងភវង្គខណៈ។

-ភវង្គចលន: ភវង្គរញ្ជួយ។ ក្នុងខណៈនៃភវង្គចលននេះ រូបារម្មណ៍កើតឡើងច្បាស់ប្រាកដក្នុងចក្ខុទ្វារហើយ។

-ភវង្គុបច្ឆេទ: ភវង្គឈប់។ ខ្សែភវង្គដែលហូរជាធម្មតាត្រូវឈប់បន្ទាប់ពីចិត្តនេះរលត់។

១-បញ្ចទ្វារាវជ្ជន ១ ខណៈ: ចិត្តដឹងអារម្មណ៍ដែលប៉ះខ្ទប់នឹងបញ្ចទ្វារ(វិថីចិត្តទី ១)។ ជាចិត្តទី ១ ជាដរាបក្នុងខ្សែបញ្ចទ្វារវិថី វាដាច់ចេញពីភវង្គងាកទៅរកទ្វារវិញ្ញាណ។ ជាអហេតុកកិរិយាចិត្ត នៅជាមនោធាតុ គឺចិត្តមិនដឹងអារម្មណ៍៕

២-បញ្ចវិញ្ញាណ ១ ខណៈ: ចិត្តអាស្រ័យប្រសាទរូប ៥ ដឹងអារម្មណ៍តាមបញ្ចទ្វារ(វិថី

ចិត្តទី ២)។ វាបង្កើតផស្ស(ការប៉ះខ្ទប់អារម្មណ៍) ហើយបញ្ជូនផស្សនោះទៅឲ្យចិត្តមួយទៀតមុននឹងវារលត់ទៅ។

៣-សម្បដិច្ឆន ១ ខណៈ ចិត្តទទួលនូវបញ្ចារម្មណ៍(វិថីចិត្តទី ៣)។ វាទទួលយកអារម្មណ៍ ហើយបញ្ជូនទៅឲ្យចិត្តបន្ទាប់ មុននឹងវារលាត់ទៅ។

៤-សន្តីរណ ១ ខណៈ ចិត្តពិចារណាអារម្មណ៍ដោយប្រពៃ(វិថីចិត្តទី ៤)។ ចិត្តនេះពិចារណាអារម្មណ៍តពីសម្បដិច្ឆន។

៥-វោដ្ឋព្វន ១ ខណៈ ចិត្តធ្វើកិច្ចកាត់ក្តីអារម្មណ៍តាមសន្តីរណចិត្តដែលពិចារណាហើយ(វិថីចិត្តទី ៥)។ ចិត្តនេះធ្វើកិច្ចកាត់សេចក្តីអារម្មណ៍ដោយសភាពជាកុសល អកុសល ឬកិរិយា តាមអំណាចនៃយោនិសោមនសិការ ឬអយោនិសោមនសិការឲ្យជវនចិត្តកើតឡើង៕

៦-ជវន ៧ ខណៈ ចិត្តដែលស្ទុះទៅសោយអារម្មណ៍(វិថីចិត្តទី ៦)។ វាជាចិត្តមានមនសិការដែលឲ្យសម្រេចជវនកិច្ចរត់ទៅ ៧ ខណចិត្តសន្សំសន្តានជាកុសលកម្ម ឬអកុសលកម្ម។

៧-តទាលម្ពណ ២ ខណៈ ចិត្តនេះធ្វើកិច្ចដឹងអារម្មណ៍តពីជវនវិថី(វិថីចិត្តទី ៧)។ ជាចិត្តដួងចុងក្រោយដែលដឹងអារម្មណ៍តាមទ្វារនីមួយៗកើតរលត់ ២ ខណ នៅពេលតទាលម្ពណចិត្តរលត់ទៅ អារម្មណ៍ និងបសាទរូបក៏រលត់ព្រមគ្នា ព្រោះអាយុរបស់វិថីចិត្តដែលមាន ១៧ ខណបានចប់សព្វគ្រប់ ហើយចិត្តក៏ប្រព្រឹត្តទៅក្នុងក្រសែភវង្គ។ តពីនោះ ទើបមនោទ្វារាវជ្ជនចិត្តដែលដឹងអារម្មណ៍តាមមនោទ្វារ ក៏កើតឡើងដឹងអារម្មណ៍តែមួយដូចបញ្ចទ្វារវិថីចិត្តដែរ៕

### *វិសយប្បវត្តិ ៤ គឺ:

វិសយប្បវត្តិ គឺការប្រព្រឹត្តិទៅរបស់អារម្មណ៍ក្នុងទ្វារមួយនៃទ្វារប្រាំ តាំងពីកើតឡើងដរាបដល់អស់អារម្មណ៍ ហៅថា វារៈ ១។

១-មោឃវារៈ វិថីចិត្តនេះមានអារម្មណ៍កើតឡើងចាប់ពីអតីតភវង្គដល់ភវង្គុបច្ឆេទ។ មោឃវារមិនមានវិថីចិត្តកើតឡើងដឹងអារម្មណ៍ដែលប៉ះខ្ទប់ ហៅថា អតិបរិត្តារម្មណ៍

គឺអារម្មណ៍ដែលមានកម្លាំងតិចបំផុត។

២-វោដ្ឋពូនវារ: វិថីចិត្តនេះមានអារម្មណ៍កើតឡើងចាប់ពីអតីតភវង្គដល់វោដ្ឋពូនវិថីចិត្ត។ កាលវោដ្ឋពូនវិថីចិត្តកើតរលត់ ៣ ឬ ២ ខណហើយអារម្មណ៍ក៏រលត់ទៅ ជវនចិត្តកើតមិនបាន ហៅថា បរិត្តារម្មណ៍ គឺអារម្មណ៍ដែលមានកម្លាំងតិច។

៣-ជវនវារ: វិថីចិត្តនេះមានអារម្មណ៍កើតឡើងចាប់ពីអតីតភវង្គដល់ជវនវិថីចិត្ត។ កាលជវនចិត្តកើតរលត់បន្តគ្នា ៧ ខណហើយអារម្មណ៍ក៏រលត់ទៅ តទាលម្ពណចិត្តកើតមិនបាន ហៅថា មហន្តារម្មណ៍ គឺអារម្មណ៍ដែលមានកម្លាំងខ្លាំង។ មហន្តា-រម្មណ៍មានវិថីចិត្តកើតបាន ៦ វិថីតិចជាងអតិមហន្តារម្មណ៍ ១ វីថី ព្រោះខ្វះខាតបច្ច័យណាមួយ គឺប្រសាទវត្ថុ ឬបញ្ចារម្មណ៍ ព្រោះអារម្មណ៍កន្លងផុតទៅ ២ ឬ ៣ ខណចិត្ត។

៤-តទាលម្ពណវារ: វិថីចិត្តនេះមានអារម្មណ៍កើតឡើងចាប់ពីអតីតភវង្គដល់តទា-លម្ពណវិថីចិត្ត។ កាលជវនចិត្តកើតរលត់ ៧ ខណហើយអារម្មណ៍នៅមិនទាន់រលត់ ជាបច្ច័យឲ្យតទាលម្ពណចិត្តកើតឡើងដឹងអារម្មណ៍បន្ត ២ ខណទៀត ហៅថា អតិ-មហន្តារម្មណ៍ គឺអារម្មណ៍ដែលមានកម្លាំងខ្លាំងច្រើន។

*មនោទ្វារវិថី មានអារម្មណ៍បាន ៦ គឺ:

រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ធម្មារម្មណ៍។

មនោទ្វារវិថីមិនមានអតីតភវង្គទេ ព្រោះជាវិថីចិត្តដែលទទួលអារម្មណ៍តាមផ្លូវចិត្តតពីបញ្ចទ្វារ កាលបញ្ចារម្មណ៍ប៉ះខ្ទប់ទ្វារនៅជាបរមត្ថ ជាអារម្មណ៍បច្ចុប្បន្ន មិនអាចដឹងអត្ថន័យរបស់អារម្មណ៍នោះៗបាន កាលអារម្មណ៍តាមបញ្ចទ្វារកើតបន្តទៅកាន់មនោទ្វារហើយ ទើបអាចដឹងអត្ថន័យរបស់អារម្មណ៍នោះៗបានច្បាស់។

-ភវង្គចលនៈ ដូចគ្នានឹងបញ្ចទ្វារ។

-ភវង្គុបច្ឆេទៈ ដូចគ្នានឹងបញ្ចទ្វារ។

-មនោទ្វារាវជ្ជនវិថីចិត្តៈ ជាអហេតុកកិរិយា គឺឧបេក្ខាសហគតំ មនោទ្វារាវជ្ជនចិត្តំ ជាមនោវិញ្ញាណធាតុ គឺចិត្តដឹងអារម្មណ៍។

-ជវនវិថីចិត្ត: ដូចគ្នានឹងបញ្ចទ្វារ។

-តទាលម្ពណវិថីចិត្ត ២ ខណ: ចិត្តនេះធ្វើកិច្ចដឹងអារម្មណ៍តពីជវនវិថី ជាចិត្តដួងចុងក្រោយដែលដឹងអារម្មណ៍តាមមនោទ្វារកើតរលត់ ២ ខណ ហើយក៏ប្រព្រឹត្តទៅក្នុងក្រសែភវង្គ រហូតមានវិថីចិត្តវារៈបន្ទាប់កើតឡើងដឹងអារម្មណ៍តាមទ្វារណាមួយ។ ការដឹងអារម្មណ៍តាមមនោទ្វារវិថីមាន ២ វិសយប្បវត្តិគឺ វិភូតារម្មណ៍ ជាអារម្មណ៍ដែលច្បាស់ វិថីចិត្តនេះមានអារម្មណ៍កើតឡើងចាប់ពីភវង្គចលនដល់ជវនវិថី ឬតទាលម្ពណវិថី ១, អវិភូតារម្មណ៍ ជាអារម្មណ៍ដែលមិនច្បាស់ វិថីចិត្តនេះមានអារម្មណ៍កើតឡើងចាប់ពីភវង្គចលនដល់ភវង្គុបច្ឆេទ ឬមនោទ្វារាវជ្ជន ១៕

☺ចិត្តកើតរលត់តគ្នាជាក្រសែយ៉ាងរហ័សប្រៀបដូចផ្លេកបន្ទោរ។

*វិញ្ញត្តិគហណវិថី:

វិញ្ញត្តិគហណវិថី មាន ២ គឺកាយវិញ្ញត្តិគហណវិថី ជាវិថីដែលដឹងការកម្រើកញ័រតាមផ្លូវកាយ និងវចីវិញ្ញត្តិគហណវិថី ជាវិថីដែលដឹងការកម្រើកញ័រតាមផ្លូវវាចា។

១-កាយវិញ្ញត្តិគហណវិថី: ចក្ខុទ្វារវិថីឃើញការបក់ដៃ គឺឃើញរូបារម្មណ៍ដែលជាបរមត្ថបច្ចុប្បន្ន។ មនោទ្វារវិថី គឺអតីតគហណវិថី(វិថីដែលមានអារម្មណ៍ជាអតីត) កើតឡើង ទទួលរូបារម្មណ៍តពីចក្ខុទ្វារវិថីជាអារម្មណ៍បរមត្ថ(បរមត្ថារម្មណ៍ បានដល់រូប ចិត្ត ចេតសិក និព្វាន បាន ៦ អារម្មណ៍ គឺដឹងត្រឹមជារូបារម្មណ៍ និងសទ្ទារម្មណ៍ តែមិនដឹងរូបជាមនុស្ស ឬសត្វ ឬវត្ថុផ្សេងៗ ក៏មិនដឹងសំឡេងជារបស់មនុស្សប្រុស ឬស្រី ហើយក៏មិនដឹងន័យសេចក្ដីរបស់សំឡេង) វិថីនេះ កើតផ្លាស់ប្ដូរគ្នានឹងចក្ខុទ្វារវិថីច្រើនៗវិថី។ សមូហគហណវិថី(វិថីរួមអារម្មណ៍)កើតឡើង ប្រមូលរូបារម្មណ៍ដែលចក្ខុទ្វារវិថី និងអតីតគហណវិថីទទួលមក សមូហគហណវិថីនេះ នឹងកើតច្រើនដុំ តែនៅជាអារម្មណ៍បរមត្ថដែលនៅជាអតីត។ អត្ថគហណវិថី(វិថីដែលដឹងអត្ថន័យ ដឹងអត្ថន័យរឿងរ៉ាវរបស់អារម្មណ៍ វិថីនេះ មានអារម្មណ៍បញ្ញត្តិ បើអារម្មណ៍តាមផ្លូវបញ្ចទ្វារ មានពណ៌ជាអារម្មណ៍ វិថីនេះ ក៏ដឹងរូបរាង ឬសណ្ឋានរបស់រូបារម្មណ៍នោះថាជាមនុស្ស ឬសត្វ ឬវត្ថុផ្សេងៗ)កើតឡើង ដឹងអត្ថន័យថា ជាការបក់ដៃ ជាវិថីទទួលបញ្ញត្តិជាអារម្មណ៍(បញ្ញត្យារម្មណ៍ បានដល់អត្ថប្បញ្ញត្តិ និងសទ្ទប្បញ្ញត្តិ ជាធម្មារម្ម-

ណ៍)។ កាយវិញ្ញត្តិគហណវិថី មានការបក់ដៃដែលជាបញ្ញត្តិជាអារម្មណ៍ ដោយដឹងន័យនៃការបក់ដៃ"ហៅយើង"។ អធិប្បាយគហណវិថី កើតឡើតមានបញ្ញត្តិក្នុងការបក់ដៃជាអារម្មណ៍ ដោយដឹងសេចក្តីប្រាថ្នា យើងនឹងទៅជួបគេ៕

២-វចីវិញ្ញត្តិគហណវិថី: សោតទ្វារវិថី កើតឡើងមានសំឡេងជាអារម្មណ៍ គឺបានឮសំឡេងជាអារម្មណ៍បរមត្ថ និងជាអារម្មណ៍បច្ចុប្បន្នផង មិនមានការដឹងអារម្មណ៍បញ្ញត្តិយ៉ាងណាទេ។ អតីតគហណវិថី កើតឡើងមានសំឡេងបរមត្ថជាអារម្មណ៍អតីត ទាំងពីរវិថីនេះកើតផ្លាស់ប្តូរគ្នាច្រើនៗវារៈ។ សមូហគហណវិថី កើតឡើងនៅមានជាបរមត្ថសទ្ទារម្មណ៍ជាអតីតារម្មណ៍។ ធ្វើនាទីប្រមូលសំឡេង ជាពាក្យដែលមានច្រើនជាង ១ ព្យាង្គដែលសោតទ្វារវិថី និងអតីតគហណវិថីទទួលមក វិថីនេះក៏កើតឡើងមកច្រើនៗដុំដូចគ្នា។ នាមគហណវិថី កើតឡើងទទួលនាមបញ្ញត្តិជាអារម្មណ៍ គឺឈ្មោះរបស់យើង។ អត្ថគហណវិថី កើតឡើងទទួលនាមបញ្ញត្តិជាអារម្មណ៍ ដឹងអត្ថន័យថា ជាឈ្មោះរបស់យើង។ វចីវិញ្ញត្តិគហណវិថី កើតឡើងដឹងន័យរបស់សទ្ទារម្មណ៍នោះ គឺដឹងថា "គេហៅយើង" ជាបញ្ញត្តារម្មណ៍។ អធិប្បាយ-គហណវិថី កើតឡើងដឹងបញ្ញត្តារម្មណ៍នោះ គឺដឹងសេចក្តីថា "អ្នកនោះ ហៅយើងឲ្យចូលទៅជួប" ជាបញ្ញត្តារម្មណ៍៕

## *មរណាសន្នវិថី:

មរណាសន្នវិថី គឺជាវិថីចិត្តដែលកើតឡើងក្នុងវេលាជិតស្លាប់ ក្នុងវិថីនេះមានជវនកើតបានត្រឹម ៥ ខណៈ ព្រោះចិត្តមានកម្លាំងថយចុះ ចាប់ពីកម្មដែលកើតនោះជិតអស់អំណាចហើយ និងទាំងហទយវត្ថុដែលជាទីអាស្រ័យកើតក៏កំពុងសាបសូន្យចុះគ្រប់ខណៈ ដូច្នោះ កម្លាំងរបស់ជវនចិត្តទើបមានត្រឹម ៥ ខណៈប៉ុណ្ណោះ កាលចុតិរបស់សត្វរលត់ហើយភ្លាមនោះ បដិសន្ធិក៏នឹងកើតឡើងដោយមិនមានអ្វីរាំងព្រោះនៅមានបោនោព្ភវិកាតណ្ហា គឺវិថីដំបូងរបស់សត្វអ្នកមានតណ្ហាដែលនាំកើតក្នុងភពថ្មី។ ក្នុងវេលាជិតស្លាប់ សត្វនឹងមានអារម្មណ៍ទាំង ៣ យ៉ាងណាមួយគឺ កម្មដែលឲ្យបដិសន្ធិក្នុងភពដទៃ បានដល់កុសលកម្មមានការធ្វើទាន រក្សាសីល ចម្រើនភាវនាជាដើម និងអកុសលកម្មមានការសម្លាប់សត្វ លួចទ្រព្យជាដើម ដែលសត្វធ្វើទុកក្នុងអតីតមកយ៉ាងណាមួយ នឹងមកប្រាកដចំពោះមុខដោយសញ្ញាដែលធ្លាប់ធ្វើ

ទុកក្នុងកាលណោះ ជាកម្មដូចនឹងថា កំពុងកើតឡើងជាមួយខ្លួនដោយប្រាកដតាមមនោទ្វារប៉ុណ្ណោះ កម្មនេះជាអតីតារម្មណ៍។ កម្មនិមិត្ត បានដល់គ្រឿងសម្គាល់ដែលធ្វើកម្ម គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វ និងធម្មារម្មាណ៍ ជាហេតុធ្វើកម្មដោយកាយវាចា ចិត្តក្នុងវេលាជិតស្លាប់ កម្មនិមិត្តនេះ រមែងជាអារម្មណ៍ប្រាកដក្នុងទ្វារណាមួយផ្នែងខាងកុសល ដូចជាបានឃើញព្រះពុទ្ធបដិមា ព្រះចេតិយ បានធ្វើការបូជាដោយផ្កាឈើ បានឮសំឡេងភិក្ខុសម្តែងធម៌ បានស្រូបក្លិនក្រអូបដែលបូជាព្រះធម៌ មានទឹកមុខញញឹមជាដើមដែលកំពុងរស់នៅ ផ្នែកខាងអកុសល មានការឃើញសត្វដែលខ្លួនសម្លាប់ ឃើញគ្រឿងសម្លាប់ ស្រែកដូចសត្វដែលខ្លួនសម្លាប់ មានអាការដូចសត្វដែលខ្លួនសម្លាប់ ក្រហល់ក្រហាយ ភ័យ វង្វេងជាដើមកំពុងប្រព្រឹត្តទៅ កម្មនិមិត្តនេះ ជាអារម្មណ៍ដែលជាអតីត និងបច្ចុប្បន្នប្រព្រឹត្តទៅក្នុងទ្វារ ៦។ គតិនិមិត្ត បានដល់គ្រឿងសម្គាល់ដែលនឹងត្រូវកើតក្នុងភពខាងមុខ បើសត្វនឹងកើតក្នុងសុគតិ(ភព)ភូមិ គតិនិមិត្តក៏ប្រាកដជាប្រាសាទ វិមានទិព្វ ដើមកប្បព្រឹក្ស ទេវបុត្រ ទេពធីតាជាដើមក្នុងសួគ៌ដែលជាទេវភូមិ នឹងកើតជាទេវតា បើឃើញគភ៌មាតា អារាម ផ្ទះមនុស្ស ភិក្ខុ សាមណេរជាដើមក្នុងភូមិមនុស្ស ក៏នឹងកើតជាមនុស្ស។ បើនឹងកើតក្នុងទុគ្គតិភូមិ ក៏ឃើញសត្វផ្សេងៗ មានដំរីជាដើមដែលជាភូមិរបស់សត្វតិរច្ឆាន ក៏នឹងកើតជាតិរច្ឆាន បើឃើញប្រេត ឬអសុរកាយ ព្រៃស្ងាត់ ជ្រោះជាដើមដែលជាភូមិរបស់ប្រេត និងអសុរកាយ ក៏នឹងកើតជាប្រេត ឬអសុរកាយ។ បើឃើញគ្រឿងប្រហារផ្សេងៗ ភ្លើងនរក និងនាយនិរយបាលជាដើម ក៏នឹងកើតក្នុងនរកភូមិ គតិនិមិត្តដែលទ្វារទាំង ៦ កាន់យកជាអារម្មណ៍ដែលជាបច្ចុប្បន្ន និងអតីត។ ចុតិចិត្តដែលជាទីបំផុតនៃភពបច្ចុប្បន្នរបស់សត្វដែលជិតស្លាប់កើតឡើងហើយរលត់ទៅ ដោយអំណាចនៃការឃ្លាតទៅក្នុងទីបំផុតនៃវិថីចិត្ត ឬក្នុងការអស់ទៅនៃភវង្គ។ អារម្មណ៍ទាំង ៣ មានកម្មជាដើម រមែងកើតឡើងដោយកម្ម ៤ យ៉ាង៕

*កិច្ចចតុក្ក (កិច្ចរបស់កម្ម មាន ៤):

១-ជនកកម្មៈ កម្មឲ្យកើត គឺចេតនាកម្មដែលជាមហាកុសលចិត្ត ៨ រូបាវចរកុសលចិត្ត ៥ អរូបាវចរកុសលចិត្ត ៤ និងអកុសលចិត្ត ១២ ដែលឲ្យវិបាក និងកដត្តារូប(បដិ-សន្ធិកម្មជរូប បវត្តិកម្មជរូប អសញ្ញីសត្តកម្មជរូប)កើតឡើងក្នុងបដិសន្ធិកាល។

២-ឧបត្ថម្ភកកម្មៈ កម្មឧបត្ថម្ភ គឺចេតនាកម្មដែលជាមហាកុសលចិត្ត ៨ និងអកុសលចិត្ត ១២ ដែលមិនអាចឲ្យវិបាកកើតឡើងបានដោយខ្លួនឯង តែជាបច្ច័យដល់កម្មដទៃក្នុងការញ៉ាំងវិបាកដែលជាសុខ ឬជាទុក្ខឲ្យប្រព្រឹត្តទៅយឺនយូរ ដើម្បីមិនឲ្យបច្ច័យដែលជាហេតុកាត់ផ្តាច់កើតឡើង។

៣-ឧបបីឡកកម្មៈ កម្មបៀតបៀន គឺចេតនាកម្មដែលជាមហាកុសលចិត្ត ៨ និងអកុសលចិត្ត ១២ ដែលចូលទៅបៀតបៀនកម្មយ៉ាងណាមួយ ដែលជាហេតុជំទាស់ការប្រព្រឹត្តទៅយឺនយូរនៃវិបាកដែលជាសុខ ឬជាទុក្ខ ដែលកម្មដទៃឲ្យកើត។

៤-ឧបឃាតកកម្មៈ កម្មចូលទៅកាត់ផ្តាច់ គឺចេតនាកម្មដែលជាមហាកុសលចិត្ត ៨ រូបាវចរកុសលចិត្ត ៥ អរូបាវចរកុសលចិត្ត ៤ លោកុត្តរកុសលចិត្ត ៤ និងអកុសលចិត្ត ១២ ដែលចូលទៅកាត់ផ្តាច់នូវអំណាចដែលត្រៀមកម្លាំងហើយ ហាមវិបាកកម្មដែលមិនមានកម្លាំងនោះចេញ ឲ្យវិបាកកើតឡើង។ ភាពផ្សេងគ្នារវាងជនកកម្ម និងឧបឃាតកកម្ម គឺជនកកម្ម មិនចូលទៅកាត់ផ្តាច់កម្មដទៃឡើយ ឲ្យវិបាកកើតឡើងបាន តែឧបឃាតកកម្ម មានការចូលទៅកាត់ផ្តាច់វិបាកនៃកម្មដទៃមុនហើយឲ្យវិបាកកើតឡើង៕

*បាកចតុក្ក (ការឲ្យផលរបស់កម្ម មាន ៤):

១-គរុកម្មៈ កម្មមានអានុភាពច្រើន(ផ្នែកកុសល គឺមហគ្គតកម្ម(ឈាន) ផ្នែកអកុសលគឺអនន្តរិយកម្ម)ដែលកម្មដទៃមិនអាចជំទាស់រារាំងបាន។

២-អាសន្នកម្មៈ កម្មដែលតាមរឭកបានក្នុងពេលជិតស្លាប់ ឬកម្មដែលធ្វើក្នុងវេលាជិតស្លាប់ ជាកម្មនិមិត្ត។

៣-អាចិណ្ណកម្មៈ កម្មដែលធ្វើជាប់រឿយៗ ឬកម្មដែលធ្វើតែម្តង តែសេពប្រព្រឹត្តជានិច្ច គឺរឭកដល់កម្មដែលធ្វើហើយកើតសេចក្តីជ្រះថ្លា ឬសៅហ្មងចិត្តរឿយៗ។

៤-កដត្តាកម្មៈ កម្មដែលធ្វើបន្តិចបន្តួច គឺកម្មដែលធ្វើហើយមិនដល់ភាពជាគរុកម្ម។

*កាលចតុក្ក (វេលាឲ្យផលរបស់កម្ម មាន ៤):

១-ទិដ្ឋធម្មវេទនីយកម្មៈ កម្មដែលគប្បីសោយក្នុងភពបច្ចុប្បន្ន គឺអត្តភាពដែលឃើញ

ប្រចក្ស បានដល់ផលដែលជាបច្ចុប្បន្ននេះ។

២-ឧបបជ្ជវេទនីយកម្មៈ កម្មដែលគប្បីសោយក្នុងភពខាងមុខ គឺកម្មដែលសត្វត្រូវកើតតពីភពបច្ចុប្បន្ន ទើបសោយផល។

៣-អបរាបរិយវេទនីយកម្មៈ កម្មដែលគប្បីសោយក្នុងភពតទៅ គឺកម្មដែលសត្វគប្បីសោយផលតៗ ទៅក្នុងអត្តភាពដទៃណាមួយ ក្រៅចាកភពបច្ចុប្បន្ននេះ និងភពទី ២ គឺភពទី ៣ រហូតដល់ភពចុងក្រោយ។

៤-អហោសិកម្មៈ កម្មដែលមិនឲ្យផល គឺកម្មដែលមានហើយ ឯផលរបស់កម្មនោះមិនមានទេ ព្រោះការខ្វះខាតនៃបច្ច័យ ឬពេលដែលសង្សារវដ្តត្រូវកាត់ផ្តាច់ហើយ។

*ឋានចតុក្ក (ឋានដែលឲ្យផលរបស់កម្ម មាន ៤):

១-អកុសលៈ កម្មដែលមិនមែនកុសល។

២-កាមាវចរកុសលៈ កម្មដែលជាកាមាវចរកុសល។

៣-រូបាវចរកុសលៈ កម្មដែលជារូបាវចរកុសល។

៤-អរូបាវចរកុសលៈ កម្មដែលជាអរូបាវចរកុសល។

*និយតមិច្ឆាទិដ្ឋិ ៣ យ៉ាង:

១-នត្ថិកទិដ្ឋិៈ យល់ថា ផលរបស់បុណ្យ និងបាបមិនមាន។

២-អហេតុកទិដ្ឋិៈ យល់ថា មិនមានហេតុ។

៣-អកិរិយទិដ្ឋិៈ យល់ថា កម្មដែលធ្វើហើយមិនមាន។

បុគ្គលដែលមិនជឿកម្មផល នរក សួគ៌ មគ្គ ផល និព្វាន និងការត្រាស់ដឹងរបស់ព្រះពុទ្ធ សន្សំការយល់ខុសបែបនេះយូរៗទៅនឹងជាបុគ្គលនិយតមិច្ឆាទិដ្ឋិ បុគ្គលនោះនឹងបដិសន្ធិក្នុងលោកន្តរនរកនៅចន្លោះមុម ៣ នៃភ្នំចក្រវាឡ ទីនោះងងឹតឈឹង ហើយខាងក្រោមជាទឹកត្រជាក់ដ៏ក្រៃលែងដែលទ្រផែនដី សូម្បីភ្លើងឆេះកប្បក៏ឆេះមិនដល់ផង សត្វនរកនោះក្បាលសំយុងចុះក្រោមដូចសត្វជ្រឹង តោងថ្ពក់ជើងភ្នំ

ចក្រវាលខាងក្រោម ពេលធ្លាក់ចូលទឹកក៏បែកជាដុំៗ មានអាយុវែងរងទុក្ខយូរក្រៃ។

*មរណ ៤ យ៉ាង:

១-អាយុក្ខយមរណៈ ស្លាប់ព្រោះអស់អាយុ(កម្មនៅមិនទាន់អស់)។

២-កម្មក្ខយមរណៈ ស្លាប់ព្រោះអស់កម្ម(អាយុនៅមិនទាន់អស់)។

៣-ឧភយក្ខយមរណៈ ស្លាប់ព្រោះអស់ទាំងអាយុ អស់ទាំងកម្ម។

៤-ឧបច្ឆេទក្ខយមរណៈ ស្លាប់ព្រោះត្រូវកម្មដទៃកាត់ផ្តាច់។

*សុបិនវិថី:

សុបិនវិថី គឺជាវិថីនៃការយល់សប្ត កើតឡើងក្នុងខណៈដែលដេកលក់មិនស្និទ្ធ វិថីនេះជាកាមជវនវិថី ប្រព្រឹត្តទៅតាមផ្លូវមនោទ្វារ។ ហេតុនៃការយល់សប្តមាន ៤ គឺ:

១-ធាតុខោភតោ ព្រោះការកម្រើកនៃធាតុ គឺធាតុក្នុងរាងកាយកម្រើកមិនប្រក្រតី មានការឈឺជាដើម ធ្វើឲ្យយល់សប្ត ការយល់សប្តនេះមិនពិតទេ។

២-អនុភូតបុព្វតោ ព្រោះធ្លាប់ជួបមក គឺយល់សប្តកើតអំពីការនឹកគិតដល់អារម្មណ៍ដែលធ្លាប់ជួបមក ឬកប់ទុកក្នុងចិត្ត ក៏យល់សប្តទៅដោយចិត្តដែលរវើរវាយនោះ ការយល់សប្តនេះមិនពិតទេ។ ក្រោយពេលដេកលក់ហើយ ចិត្តក៏បន្តការគិតរហូតចិត្តឡើងចាកភវង្គក៏កើតជាការយល់សប្ត ដឹងអារម្មណ៍តាមមនោទ្វារ៕

៣-ទេវតោបសំហារតោ ព្រោះទេវតាចូលទៅបណ្តាលចិត្ត គឺយល់សប្តកើតអំពីទេវតាមកប្រាប់ហេតុល្អ ឬហេតុអាក្រក់ឲ្យដឹងជាមុន ការយល់សប្តនេះមានពិតខ្លះ មានមិនពិតខ្លះ បើទេវតាសម្មាទិដ្ឋិក៏ប្រាប់នូវរឿងដែលពិត បើទេវតាមិច្ឆាទិដ្ឋិក៏ប្រាប់នូវរឿងដែលមិនពិត។

៤-បុព្វនិមិត្តតោ ព្រោះបុព្វនិមិត្ត គឺយល់សប្តិកើតដោយអំណាចនៃកុសលកម្ម ឬអកុសលកម្មដែលធ្វើទុកពីអតីតជាតិ កាលវេលានឹងឲ្យជ្រាបដល់សេចក្តីសុខ ឬទុក្ខក៏នឹងប្រាកដជានិមិត្ត ការយល់សប្តនេះជាការពិតប្រាកដ ដូចការយល់សប្ត(សុបិននិមិត្ត)របស់ព្រះនាងសិរិមហាមាយា។

ការយល់សប្តមានជាកុសលខ្លះ ជាអកុសលខ្លះ ជាអព្យាកតខ្លះ ក្នុងខណណា យល់សប្តបានថ្វាយបង្គំព្រះចេតិយជាដើម ខណនោះក៏ជាកុសល ហៅថា កុសល-សុបិនវិថី សុបិនវិថីនេះនឹងផុតវិថីត្រង់ជវនវារៈ ឬតទាលម្ពណវារៈ។ បើយល់សប្តធ្វើបាណាតិបាតជាដើម ជាអកុសលសុបិនវិថី សុបិនវិថីនេះនឹងផុតវិថីត្រង់ជវនវារៈ ឬតទាលម្ពណវារៈ។ ចំណែកការយល់សប្តដែលជាអព្យាកតវិថីនោះ អារម្មណ៍ដែលយល់សប្តនឹងផុតរលត់ត្រង់វោដ្ឋវនវារៈ ឬជាមោឃវារៈ៕

## *ហេតុឲ្យកើតបញ្ញា ៣ យ៉ាង:

១-សុតាមយបញ្ញា: បញ្ញាកើតអំពីការស្តាប់(រៀន) ២-ចិន្តាមយបញ្ញា: បញ្ញាកើតអំពីការគិតពិចារណា ៣-ភាវនាមយបញ្ញា: បញ្ញាកើតអំពីភាវនា។ បញ្ញាទាំងឡាយដែលនឹងកើតឡើងបាន ទាល់តែអាស្រ័យបច្ច័យឲ្យកើត គឺការស្តាប់។ សុតាមយ-បញ្ញានេះ ត្រូវអាស្រ័យអ្នកដទៃប្រាប់ ឬរៀនយកអំពីគ្រូ ទើបបានបញ្ញានេះ ជាបញ្ញាជាន់ទាប។ ចំណែកចិន្តាមយបញ្ញារបស់មនុស្សធម្មតា រមែងកើតព្រោះអាស្រ័យការស្តាប់ជាខាងដើម ទើបកើតបាន តែសម្រាប់អ្នកមានបារមីដែលបានសន្សំមកយ៉ាងល្អ មិនបាច់ស្តាប់អ្នកដទៃក៏អាចកើតឡើងបាន។ ចំណែកភាវនាមយបញ្ញា ជាបញ្ញាកើតអំពីភាវនា បានដល់ការចម្រើនវិបស្សនា៕

## *ហេតុឲ្យកើតកុសលញាណសម្បយុត្ត:

១-បរិបុច្ឆកតា: ភាពជាអ្នកសាកសួរច្រើន។

២-វត្ថុវិសទក្រិយតា: ស្អាតទាំងកាយ ចិត្ត និងវត្ថុ។

៣-ឥន្ទ្រិយសមត្តបដិបាទនតា: មានឥន្ទ្រិយទាំង ៥ ស្មើគ្នា។

៤-ទុប្បញ្ញាបុគ្គលបរិវជ្ជនា: គេចចេញពីអ្នកមានបញ្ញាខ្សោយ។

៥-បញ្ញវន្តបុគ្គលសេវនា: សេពគប់នឹងអ្នកមានបញ្ញា។

៦-គម្ភីរញាណចរិយបច្ចវេក្ខណា: ពិចារណាញាណចរិយាដ៏ជ្រាលជ្រៅ។

៧-តទធិមុត្តតា: ភាពជាអ្នកបង្អោនចិត្តទៅក្នុងញាណនោះ។

*ចក្ក(សម្បត្តិ) ៤ ជាហេតុធ្វើឲ្យកុសលកើតឡើង:

១-បដិរូបទេសវាសោ: ការនៅក្នុងប្រទេសដ៏សមគួរ។

២-សប្បុរិសូបស្សយោ: ការចូលទៅសេពគប់នឹងពួកសប្បុរស។

៣-អត្តសម្មាបណិធិ: ការតម្កល់ខ្លួនទុកដោយល្អ។

៤-បុព្វេ ច កតបុញ្ញតា: បុណ្យដែលបានធ្វើទុកហើយក្នុងកាលមុន។

*ហេតុឲ្យកើតអកុសលចិត្ត ១២ មាន ៤ យ៉ាង:

១-បុព្វេ អកតបុញ្ញតា: មិនបានធ្វើបុណ្យទុកពីកាលមុន។

២-អប្បដិរូបទេសវាស: ការនៅក្នុងប្រទេសដែលមិនសមគួរ។

៣-អសប្បុរិសូបនិស្សយ: មិនសេពគប់នឹងសប្បុរស។

៤-អត្តមិច្ឆាបណិធិ: ការតម្កល់ខ្លួនទុកដោយមិនល្អ។

*អកុសលកម្មបថ ១០ គឺ:

កម្មបថ ជាផ្លូវ ឬគន្លងនៃកម្ម គឺដំណើររបស់អំពើអាក្រក់ ឬល្អដែលសត្វលោកធ្វើដោយកាយ វាចា ចិត្ត។

-កាយទុច្ចរិត ៣ គឺ:

១-បាណាតិបាតា: កិរិយាសម្លាប់សត្វដោយកាយរបស់ខ្លួន ឬប្រើគេឲ្យសម្លាប់ដោយវាចា។

២-អទិន្នាទានា: កិរិយាលាក់ឆក់លួចដណ្ដើមទ្រព្យគេដោយកាយរបស់ខ្លួន ឬប្រើឲ្យគេលួចលាក់ឆក់ដណ្ដើមដោយវាចា។

៣-កាមេសុមិច្ឆាចារា: កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺធ្វើនូវមេថុនសេវននឹងស្ត្រី ឬបុរសដែលមានគេហួងហែងរក្សា។

-វចីទុច្ចរិត ៤ គឺ:

១-មុសាវាទា: កិរិយាពោលនូវពាក្យកុហក។

២-បិសុណាវាចា: កិរិយាពោលនូវពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ។

៣-ផរុសវាចា: កិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម។

៤-សម្ផប្បលាបា: កិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍។

**-មនោទុច្ចរិត ៣ គឺ:**

១-អភិជ្ឈា: ចិត្តសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបម្រុងនឹងឲ្យបានជារបស់ខ្លួន។

២-ព្យាបាទ: ចិត្តចងគំនុំគុំកួនប៉ងនឹងឲ្យអ្នកដទៃដល់នូវសេចក្ដីវិនាស។

៣-មិច្ឆាទិដ្ឋិ: ការយល់ខុស បានដល់និយតមិច្ឆាទិដ្ឋិ(មើលទំព័រ ៤១)។

*__កុសលកម្មបថ ១០ គឺ:__

**-កាយសុចរិត ៣ គឺ:**

១-បាណាតិបាតា វេរមណី: ចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ។

២-អទិន្នាទានា វេរមណី: ចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យដោយកាយ ឬវាចា។

៣-កាមេសុមិច្ឆាចារា វេរមណី: ចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។

**-វចីសុចរិត ៤ គឺ:**

១-មុសាវាទា វេរមណី: ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក។

២-បិសុណាវាចា វេរមណី: ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ។

៣-ផរុសវាចា វេរមណី: ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោក ជេរប្រទេចអ្នកដទៃជាដើម។

៤-សម្ផប្បលាបា វេរមណី: ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍។

-មនោសុចរិត ៣ គឺ:

១-អនភិជ្ឈា: មិនមានចិត្តសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបម្រុងនឹងឲ្យបានជារបស់ខ្លួន។

២-អព្យាបាទ: មិនមានចិត្តចងគំនុំគុំកួនប៉ងនឹងឲ្យអ្នកដទៃដល់នូវសេចក្ដីវិនាស។

៣-សម្មាទិដ្ឋិ: ការយល់ត្រូវ បានដល់បញ្ញា(បញ្ញិន្ទ្រិយចេតសិក មើលទំព័រ ១១)។

*សីលប្រាំ និងអង្គនៃសិក្ខាបទ:

សីល ជាតួចេតនាវៀរចាកបាបមានបាណាតិបាតជាដើម ទ្រទ្រង់នូវកុសលធម៌ ធ្វើឲ្យស្អាតកាយវាចាចិត្ត មិនក្ដៅក្រហាយខាងដើម និងមានអនុបាទានបរិនិព្វាន(ទីរម្លត់ទុក្ខ)ខាងចុង បុគ្គលដែលរក្សាសីល គប្បីកាន់យកនូវកុសលកម្មបថ ១០ វៀរចាកអកុសលកម្មបថ ១០ សីលជាបាទរបស់សមាធិ និងជាធម៌បិទបាំងអបាយភូមិ។

១-បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ។

+បាណាតិបាតា មានអង្គ ៥ គឺ:

-បាណា: សត្វមានជីវិត។

-បាណសញ្ញិតា: សេចក្ដីដឹងថា សត្វមានជីវិត។

-វធកចិត្តំ: មានចិត្តគិតនឹងសម្លាប់។

-ឧបក្កមោ: ព្យាយាមសម្លាប់។

-តេន មរណំ: សត្វស្លាប់ដោយការព្យាយាមនោះ។

២-អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ដោយកាយឬដោយវាចា។

+អទិន្នាទាន មានអង្គ ៥ គឺ:

-បរបរិគ្គហិតំ: ទ្រព្យដែលមានម្ចាស់គេហួងហែងរក្សា។

-បរបរិគ្គហិតសញ្ញិតា: សេចក្តីដឹងថា ទ្រព្យនោះមានម្ចាស់គេហួងហែងរក្សា។

-ថេយ្យចិត្តំ: មានចិត្តគិតនឹងលួច។

-ឧបក្កមោ: ព្យាយាមលួច។

-តេន ហរណំ: លួចបានមកដោយសេចក្តីព្យាយាមនោះ។

៣-កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរ ចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។

+កាមេសុមិច្ឆាចារ មានអង្គ ៤ គឺ:

-អគមនីយវត្ថុ: ស្ត្រីដែលមិនគួរនឹងគប់រក គឺស្ត្រីដែលមានគេហួងហែងរក្សា។

-តស្មឹ សេវនចិត្តំ: មានចិត្តគិតសេពនូវមេថុនធម្មនឹងស្ត្រីនោះ។

-ឧបក្កមោ: ព្យាយាមសេពនូវមេថុនធម្ម។

-មគ្គេន មគ្គប្បដិបាទនំ: ញ៉ាំងមគ្គ និងមគ្គឲ្យដល់គ្នា។

៤-មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក។

+មុសាវាទ មានអង្គ ៤ គឺ:

-អតថំវត្ថុ: វត្ថុ(រឿង)មិនពិត។

-វិសំវាទនចិត្តំ: មានចិត្តគិតនឹងពោលឲ្យខុស។

-តជ្ជោ វាយាមោ: ព្យាយាមពោលឲ្យខុស។

-បរស្ស តទត្ថវិជាននំ: ញ៉ាំងអ្នកដទៃឲ្យដឹងសេចក្តីនោះ។

៥-សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និង មេរ័យ។

+សុរាមេរយ មានអង្គ ៤ គឺ:

-មជ្ជនីយ វត្ថុ: វត្ថុជាទីតាំងនៃសេចក្តីស្រវឹង គឺសុរា និងមេរ័យ។

-បាតុកម្យតាចិត្តំ: មានចិត្តគិតបម្រុងនឹងផឹក។

-តជ្ជោ វាយាមោ: ព្យាយាមផឹកទឹកស្រវឹងនោះ។

-តស្ស បានំ: បានផឹកនូវទឹកស្រវឹងនោះឲ្យកន្លងបំពង់កចូលទៅ។

*បច្ចយ ២៤ គឺ:

១-ហេតុប្បច្ចយ: ធម៌ដែលជួយឧបការ ដោយភាវជាហេតុ។ ហេតុ: បច្ចយុប្បន្នធម៌(ផលធម៌ដែលកើតឡើងអំពីបច្ច័យ)រមែងប្រព្រឹត្តទៅជាហេតុនៃកម្ម បច្ច័យ: គឺជាឧបការ គឺជួយឧបត្ថម្ភ។ ឧទាហរណ៍: អានិសង្សនៃការស្តាប់ធម៌(ហេតុ) ជាបច្ច័យញ៉ាំងឲ្យមានសទ្ធាធ្វើទាន រក្សាសីល។

២-អារម្មណប្បច្ចយ: ធម៌ដែលជួយឧបការ ដោយភាវជាអារម្មណ៍។

៣-អធិបតិប្បច្ចយ: ធម៌ដែលជួយឧបការ ដោយភាវជាធំ។

៤-អនន្តរប្បច្ចយ: ធម៌ដែលជួយឧបការ ដោយភាវបន្តជាប់គ្នាមិនមានរវាងចន្លោះ។

៥-សមនន្តរប្បច្ចយ: ធម៌ដែលជួយឧបការ ដោយភាវបន្តជាប់គ្នាមិនមានរវាងចន្លោះដោយល្អ។

៦-សហជាតប្បច្ចយ: ធម៌ដែលជួយឧបការ ដោយភាវកើតរួមគ្នា។

៧-អញ្ញមញ្ញប្បច្ចយៈ ធម៌ដែលជួយឧបការដល់គ្នា និងគ្នា។

៨-និស្សយប្បច្ចយៈ ធម៌ដែលជួយឧបការ ដោយភាវជាទីអាស្រ័យ។

៩-ឧបនិស្សយប្បច្ចយៈ ធម៌ដែលជួយឧបការ ដោយភាវជាទីអាស្រ័យដ៏មានកម្លាំង។

១០-បុរេជាតប្បច្ចយៈ ធម៌ដែលជួយឧបការ ដោយភាវកើតមុន។

១១-បច្ឆាជាតប្បច្ចយៈ ធម៌ដែលជួយឧបការ ដោយភាវកើតក្រោយ។

១២-អាសេវនប្បច្ចយៈ ធម៌ដែលជួយឧបការ ដោយភាវសេពញយៗ។

១៣-កម្មប្បច្ចយៈ ធម៌ដែលជួយឧបការ ដោយភាវតាក់តែងដើម្បីឲ្យកិច្ចផ្សេងៗ សម្រេចបាន។

១៤-វិបាកប្បច្ចយៈ ធម៌ដែលជួយឧបការ ដោយភាវជាផល។

១៥-អាហារប្បច្ចយៈ ធម៌ដែលជួយឧបការ ដោយភាវជាអ្នកនាំ។

១៦-ឥន្ទ្រិយប្បច្ចយៈ ធម៌ដែលជួយឧបការ ដោយភាវជាអ្នកគ្រប់គ្រង។

១៧-ឈានប្បច្ចយៈ ធម៌ដែលជួយឧបការ ដោយភាវជាអ្នកសម្លឹងអារម្មណ៍។

១៨-មគ្គប្បច្ចយៈ ធម៌ដែលជួយឧបការ ដោយភាវជាផ្លូវ។

១៩-សម្បយុត្តប្បច្ចយៈ ធម៌ដែលជួយឧបការ ដោយភាវជាអ្នកប្រកប។

២០-វិប្បយុត្តប្បច្ចយៈ ធម៌ដែលជួយឧបការ ដោយភាវជាអ្នកមិនប្រកប។

២១-អត្ថិប្បច្ចយៈ ធម៌ដែលជួយឧបការ ដោយភាវជាអ្នកនៅមាន។

២២-នត្ថិប្បច្ចយៈ ធម៌ដែលជួយឧបការ ដោយភាវជាអ្នកមិនមាន។

២៣-វិគតប្បច្ចយៈ ធម៌ដែលជួយឧបការ ដោយភាវជាអ្នកប្រាសទៅ។

២៤-អវិគតប្បច្ចយៈ ធម៌ដែលជួយឧបការ ដោយភាវជាអ្នកមិនទាន់ប្រាសទៅ។

## ច-បដិច្ចសមុប្បាទ:

នៅពេលបឋវីធាតុ តេជោធាតុ វាយោធាតុ អាបោធាតុ អាកាសធាតុ វិញ្ញាណ-ធាតុ ផ្សំផ្គុំកើតបានជាជីវៈមិនមានចិត្តអាស្រ័យនៅ និងជីវៈមានចិត្តអាស្រ័យនៅ។ ជីវៈដែលមិនមានចិត្តអាស្រ័យនៅ គឺជារុក្ខជាតិដែលកើតឡើងអំពីអវិនិព្ភោគរូប លក្ខណរូប អាកាសរូប និងវិញ្ញាណធាតុដែលមានថាមពលតិចកើតមិនបានជាចិត្ត ឧទាហរណ៍: មានដើមឈើពីរដើមដុះជិតគ្នារមែងចេះប្រជែងលូតកម្ពស់ដើម្បីយក ពន្លឺ និងសន្សើម បើដុះនៅជិតជញ្ជាំងក៏ដឹងខាងណាមានជញ្ជាំង មិនលូតលាស់មែក ទៅខាងជញ្ជាំង ហើយដុះចេះងាកចេញពីជញ្ជាំង រីឯជីវៈដែលមានចិត្តអាស្រ័យនៅ គឺជាសត្វ ឧទាហរណ៍: ដង្កូវទឹកដែលកើតអំពីអវិនិព្ភោគរូប លក្ខណរូប អាកាសរូប និងវិញ្ញាណធាតុដែលមានថាមពលច្រើនកើតបានជាចិត្ត គ្រប់លក្ខណជាសង្ខារធម៌ បានដល់អវិជ្ជាប្រព្រឹត្តទៅដោយតណ្ហាក៏ជាប់ក្នុងបដិច្ចសមុប្បាទធម៌ ១២ កងគឺ: អវិជ្ជាជាបច្ច័យនៃសង្ខារ សង្ខារជាបច្ច័យនៃវិញ្ញាណ វិញ្ញាណជាបច្ច័យនៃនាមរូប នាមរូបជាបច្ច័យនៃសឡាយតន សឡាយតនជាបច្ច័យនៃផស្ស ផស្សជាបច្ច័យនៃ វេទនា ៥ វេទនាជាបច្ច័យនៃតណ្ហា ៣ តណ្ហាជាបច្ច័យនៃឧបាទាន ឧបាទានជា បច្ច័យនៃភព ៣១ ភពជាបច្ច័យនៃជាតិ ជាតិជាបច្ច័យនៃជរាមរណ។ បដិច្ចសមុប្បាទ ជាកិលេសវដ្ដ កម្មវដ្ដ វិបាកវដ្ដដែលប្រាកដដោយលោកនៃចក្ខុវិញ្ញាណ សោត-វិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ និងមនោវិញ្ញាណ ជាលោកអនិច្ចំ ទុក្ខំ អនត្តា ការសិក្សាយល់ច្បាស់អំពីចតុរារិយសច្ច ទើបមើលឃើញទុក្ខដ៏ក្រៃលែង នេះ និងផ្លូវដែលទៅកាន់ការរលត់ទុក្ខ៕

### *អរិយសច្ច ៤ គឺ:

### -ទុក្ខអរិយសច្ច:

១-ជាតិទុក្ខ: កំណើតដែលកើតជាដំបូង(ការចាប់ផ្ទៃ) ជាទុក្ខ។

២-ជរាទុក្ខ: សេចក្ដីចាស់គ្រាំគ្រា ទ្រុឌទ្រោមឥន្ទ្រិយទាំងឡាយ ជាទុក្ខ។

៣-មរណទុក្ខ: សេចក្ដីស្លាប់ ការបែកធ្លាយនៃខន្ធទាំងឡាយ ជាទុក្ខ។

៤-សោកទុក្ខ: សេចក្ដីស្ដាយស្រណោះ សោកសៅ ក្រៀមក្រំ ដែលប្រកបហើយ

ដោយសេចក្តីវិនាសណាមួយ ឬសេចក្តីទុក្ខណាមួយពាល់ត្រូវហើយ ជាទុក្ខ។

៥-បរិទេវទុក្ខៈ សេចក្តីខ្សឹកខ្សួល ទួញរៀបរាប់ យំអណ្តឺតអណ្តក ដែលប្រកបហើយ ដោយសេចក្តីវិនាសណាមួយ ឬសេចក្តីទុក្ខណាមួយពាល់ត្រូវហើយ ជាទុក្ខ។

៦-ទុក្ខទុក្ខៈ សេចក្តីលំបាកកាយ មិនសប្បាយកាយ ដែលកើតអំពីកាយសម្ផស្ស ការទទួលរងសេចក្តីមិនស្រួល ជាទុក្ខ។

៧-ទោមនស្សទុក្ខៈ សេចក្តីលំបាកក្នុងចិត្ត មិនសប្បាយក្នុងចិត្ត អាក់អន់តូចចិត្ត ដែលកើតអំពីមនោសម្ផស្ស ការទទួលអារម្មណ៍មិនស្រួល ជាទុក្ខ។

៨-ឧបាយាសទុក្ខៈ សេចក្តីតានតឹងក្នុងចិត្ត ចង្អៀតចង្អល់ចិត្ត ដែលប្រកបហើយ ដោយសេចក្តីវិនាសណាមួយ ឬសេចក្តីទុក្ខណាមួយពាល់ត្រូវហើយ ជាទុក្ខ។

៩-អប្បិយេហិ សម្បយោគទុក្ខៈ ដំណើរជួបប្រសព្វដោយសត្វ និងសង្ខារ(វត្ថុ)ទាំងឡាយដែលមិនជាទីស្រឡាញ់ ជាទុក្ខ។

១០-បិយេហិ វិប្បយោគទុក្ខៈ សេចក្តីព្រាត់ប្រាសចាកសត្វ និងសង្ខារទាំងឡាយ ដែលជាទីស្រឡាញ់ ជាទុក្ខ។

១១-យម្បិច្ឆំ ន លភតិ តម្បិទុក្ខៈ កាលចង់បាននូវរបស់ណា តែមិនបាន ឯការមិនបានរបស់នោះ ជាទុក្ខ។

១២-សង្ខិត្តេន បញ្ចុបាទានក្ខន្ធាទុក្ខាៈ សេចក្តីបំប្រួញ ឧបាទានក្ខន្ធ ៥ ជាទុក្ខ។

-**ទុក្ខសមុទយអរិយសច្ចៈ** ប្រភពនៃសេចក្តីទុក្ខគឺ តណ្ហាដែលនាំឲ្យសត្វកើតក្នុងកាមភព រូបភព អរូបភព ដែលប្រកបដោយរាគ(សេចក្តីត្រេកត្រអាល)។

១-កាមតណ្ហាៈ សេចក្តីប្រាថ្នាវត្ថុកាម(រូប សំឡេង ក្លិន រស ផោដ្ឋព្វ) និងកិលេសកាម (ឆន្ទរាគ គឺលោភចេតសិក ជាសភាវធម៌ដែលត្រេកអរពេញចិត្តជាប់ជំពាក់អារម្មណ៍ ដូច្នេះវត្ថុកាមជាទីតាំងជាទីត្រេកអរពេញចិត្តនៃលោភចេតសិក)។

២-ភវតណ្ហាៈ សេចក្តីប្រាថ្នាភព ឬតម្រេកប្រកបដោយសស្សតទិដ្ឋិ(ការយល់ឃើញថា ខ្លួន និងលោកជាសភាវទៀង)។

៣-វិភវតណ្ហា: សេចក្ដីមិនប្រាថ្នាភព ឬតម្រេកប្រកបដោយឧច្ឆេទទិដ្ឋិ(ការយល់ឃើញថា ស្លាប់ទៅហើយសូន្យមិនកើតទៀត)។

**-ទុក្ខនិរោធអរិយសច្ច:** បានដល់ព្រះនិព្វានជាទីរលត់កងទុក្ខទាំងពួង។

**-ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច:** ផ្លូវទៅកាន់ការរំលត់ទុក្ខ គឺជាអរិយមគ្គមាន **អង្គ ៨ គឺ**:

១-សម្មាទិដ្ឋិ: បញ្ញាយល់ឃើញត្រូវក្នុងអរិយសច្ច ៤។

២-សម្មាសង្កប្ប: ការត្រិះរិះត្រូវ ៣ យ៉ាង: ត្រិះរិះរកឧបាយដើម្បីចេញចាកកាម, ត្រិះរិះរកឧបាយដើម្បីមិនព្យាបាទ, ត្រិះរិះរកឧបាយដើម្បីមិនបៀតបៀនសត្វដទៃ។

៣-សម្មាវាចា: វាចាត្រូវ គឺចេតនាវៀរចាកវចីទុច្ចរិត ៤។

៤-សម្មាកម្មន្ត: ការងារត្រូវ គឺចេតនាវៀរចាកកាយទុច្ចរិត ៣។

៥-សម្មាអាជីវ: ការចិញ្ចឹមជីវិតត្រូវ គឺចេតនាវៀរចាកការកេងប្រវ័ញ្ច បោកប្រាស់ លួចប្លន់ ជួញគ្រឿងសាស្ត្រាវុធ(សត្ថវណិជ្ជា) ជួញមនុស្ស(សត្តវណិជ្ជា) ជួញសាច់ គឺចិញ្ចឹមសត្វសម្លាប់យកសាច់លក់(មំសវណិជ្ជា) ជួញគ្រឿងស្រវឹង ឬគ្រឿងញៀន(មជ្ជវណិជ្ជា) ជួញថ្នាំពិស ឬថ្នាំពុល(វិសវណិជ្ជា) សម្លាប់ជីវិតដើម្បីប្រាក់។

៦-សម្មាវាយាម: ការព្យាយាមត្រូវ គឺចម្រើនសម្មប្បធាន ៤។

៧-សម្មាសតិ: ការរឭកត្រូវ គឺចម្រើនសតិប្បដ្ឋាន ៤។

៨-សម្មាសមាធិ: សមាធិត្រូវ គឺឧបេក្ខាប្រកបដោយសតិក្នុងចតុត្ថជ្ឈាន។

ព្រះសម្មាសម្ពុទ្ធកសាងបារមីបួនអសង្ខេយ្យមួយសែនមហាកប្ប ដើម្បីត្រាស់ដឹងសច្ចធម៌ សម្ដែងព្រះសទ្ធម្មទេសនាប្រោសសត្វលោកដោយមហាមេត្តាករុណាគុណថែមទាំងបានចងក្រងជាព្រះត្រៃបិដកតំណាងព្រះសាស្ដា សម្រាប់បង្ហាញផ្លូវសត្វលោកចេញចាកអំពីទុក្ខ ដែលបែងចែកជា ៣ ប្រភេទគឺ: បរិយត្តិធម៌: ពុទ្ធវចន គឺព្រះត្រៃបិដកសម្ដែងអំពីគោលធម៌ របៀបបែបផែនដំបូន្មាន ច្បាប់សម្រាប់ប្រតិបត្តិដែលពុទ្ធបរិស័ទត្រូវហាត់រៀនស្វាធ្យាយទ្រទ្រង់។ បដិបត្តិធម៌: ធម៌សម្រាប់ប្រតិបត្តិប្រ-

ព្រឹត្តតាមបានដល់សីល សមាធិ បញ្ញា ឬសេចក្តីប្រតិបត្តិតាម ធ្វើតាមកាន់តាមនូវធម៌ដ៏សមគួរដល់ធម៌ដែលខ្លួនបានរៀន បានស្តាប់ បានចេះដឹង ដើម្បីឲ្យដល់នូវធម៌ដែលខ្លួនមិនទាន់ដល់ ឲ្យសម្រេចនូវធម៌ដែលខ្លួនមិនទាន់សម្រេច ដើម្បីឲ្យជាក់ច្បាស់។ បដិវេធធម៌: ធម៌ដែលចាក់ធ្លុះអារម្មណ៍(ពាល់ត្រូវអារម្មណ៍)ដោយសភាវពិត មាន ២ប្រភេទគឺ: ១-បដិវេធលោកិយ គឺការចាក់ធ្លុះឈាន អភិញ្ញា ឬវិបស្សនាញាណក្រោមមគ្គញាណ។ ២-បដិវេធលោកុត្តរ គឺការចាក់ធ្លុះមគ្គ ផល ព្រះនិព្វាន ដែលជាផលសម្រេចអំពីការរៀនស្តាប់ចេះដឹង និងប្រតិបត្តិ។ ពុទ្ធបរិស័ទទាំងឡាយគប្បីបង្អោនចិត្តសិក្សាព្រះធម៌តាមរយៈការស្តាប់ រៀនអានចេះចាំយល់ដឹង ដើម្បីបានដល់សុតាមយបញ្ញា ពិចារណាឃើញធម៌តាមសេចក្តីពិត ដើម្បីបានដល់ចិន្តាមយបញ្ញា ចម្រើនសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋានឃើញធម៌តាមសភាវពិតដោយទម្លុះអារម្មណ៍ ដើម្បីបានដល់ភាវនាមយបញ្ញា៕

*ទោសរបស់កាមមានឧបមា ១០ យ៉ាង:

១-អដ្ឋិកង្ខលូបមា: ឧបមាដូចរាងឆ្អឹង ព្រោះមានសេចក្តីត្រេកអរតិច។

២-មំសបេសូបមា: ឧបមាដូចដុំសាច់ ព្រោះជារបស់ទូទៅដល់មនុស្សច្រើនគ្នា។

៣-តិណុក្កូបមា: ឧបមាដូចគប់ស្មៅ ព្រោះតាមដុត។

៤-អង្គារកាសូបមា: ឧបមាដូចរណ្តៅរងើកភ្លើង ព្រោះធ្វើឲ្យក្តៅរោលរាល។

៥-សុបិនកូបមា: ឧបមាដូចការយល់សប្តិ ព្រោះប្រាកដតិចតួច។

៦-យាចិតកូបមា: ឧបមាដូចរបស់ខ្ចីគេ ព្រោះត្រឹមតែមួយគ្រា។

៧-រុក្ខផលូបមា: ឧបមាដូចផ្លែឈើ ព្រោះជាផ្លែឈើពុលទម្លាយសព្វរាងកាយ។

៨-អសិសូនូបមា: ឧបមាដូចកាំបិត និងជ្រញ់ ព្រោះកាប់សាច់ចិញ្ច្រាំ។

៩-សត្តិសូលូបមា: ឧបមាដូចលំពែង និងដែកស្រួច ព្រោះចាក់ដោត។

១០-សប្បសិរូបមា: ឧបមាដូចក្បាលពស់ ព្រោះគួររង្កៀស និងមានភ័យចំពោះមុខ។

## ឆ-សមថកម្មដ្ឋានៈ

សមថកម្មដ្ឋាន ផ្ដែកចេតោវិមុត្តិ គឺរួចស្រឡះនីវរណដោយអំណាចចតុត្ថជ្ឈាន។ ការសិក្សាយល់ដឹងអំពីបរមត្ថធម៌ បដិច្ចសមុប្បាទធម៌ ចតុរារិយសច្ចធម៌ ដើម្បីមានបញ្ញាលះបង់សេចក្ដីប្រកាន់មាំចំពោះខន្ធបញ្ចក កើតមានសទ្ធា ៤ យ៉ាងគឺ កម្មសទ្ធាៈ ជឿអំពីកម្ម, វិបាកសទ្ធាៈ ជឿអំពីផលនៃកម្ម, កម្មស្សកតាសទ្ធាៈ ជឿអំពីកម្មដែលធ្វើហើយជារបស់ខ្លួន, តថាគតពោធិសទ្ធាៈ ជឿអំពីការត្រាស់ដឹងរបស់ព្រះតថាគត។ បញ្ញា និងសទ្ធាជាឧបការដល់ការចម្រើនសមថកម្មដ្ឋាន ៤០ មានកសិណ ១០ អនុស្សតិ ១០ អសុភ ១០ ព្រហ្មវិហារធម៌ ៤ អាហារេបដិកូលសញ្ញា ១ ចតុធាតុវវដ្ឋាន ១ អរូបជ្ឈាន ៤ ដែលយោគាវចរយកមករំពឹងគិតពិចារណាជាអារម្មណ៍ដើម្បីឲ្យកើតសមាធិ។ សមាធិៈ ចិត្តតាំងស្ងប់ស៊ប់ក្នុងអារម្មណ៍ សមាធិមាន ២ គឺ មិច្ឆាសមាធិៈ សមាធិដែលមិនចង់ឲ្យចិត្តរាយមាយ ឬចង់ឲ្យចិត្តស្ងប់ ខណមិនចង់ឲ្យចិត្តរាយមាយជាទោសមូលចិត្ត និងខណចង់ឲ្យចិត្តស្ងប់ជាលោភមូលចិត្ត ឯកគ្គតាចេតសិកកើតរួមអកុសលចិត្តស្ងប់ក្នុងអារម្មណ៍ បដិបត្តិមិច្ឆាសមាធិនឹងធ្វើឲ្យចម្រើននូវតណ្ហា ទិដ្ឋិ មានះ, សម្មាសមាធិៈ សមាធិដែលចម្រើននូវមហាកុសលចិត្តប្រកបដោយបញ្ញាឃើញទោសរបស់លោភ និងទោស ឯកគ្គតាចេតសិកកើតរួមកុសលចិត្តស្ងប់ក្នុងអារម្មណ៍ ចម្រើនសម្មាសមាធិនឹងកើតមានសទ្ធា សីល បាមោជ្ជ បីតិ បស្សទ្ធិ សុខ សមាធិ។ សមថៈ សេចក្ដីស្ងប់អារម្មណ៍រសេមរសាម។ ភាវនាៈ ការនឹកចំពោះត្រង់អារម្មណ៍នៃកម្មដ្ឋានរឿយៗ។ កម្មដ្ឋានៈ ការអប់រំចិត្តចម្រើនសតិបញ្ញា។ សមថកម្មដ្ឋានៈ ការអប់រំចិត្តចម្រើនសតិបញ្ញាស្ងប់ចាកនីវរណធម៌ បានដល់សមាធិ ៣ ថ្នាក់គឺ ខណិកសមាធិៈ ចិត្តស្ងប់ចាកនីវរណដែលកើតតាមខណៗ មួយភ្លែតៗ, ឧបចារសមាធិៈ ចិត្តស្ងប់ចាកនីវរណជិតដល់អប្បនា, អប្បនាសមាធិៈ ចិត្តស្ងប់ថ្លានឹងស្មើចាកនីវរណ ហៅថាឈាន។ មុននឹងចម្រើនកម្មដ្ឋានត្រូវរៀបចំកាយកុំឲ្យស្អុះស្អាប់សំលៀកបំពាក់មិនប្រឡាក់ធុំក្លិន ទីកន្លែងអនាមយ ត្រូវលះបង់បលិពោធ គឺការជាប់ជំពាក់កិច្ចការអ្វីមួយ ឬត្រូវធ្វើបង្ហើយដើម្បីកុំឲ្យចិត្តជាប់ជំពាក់ក្នុងកម្មដ្ឋាន ត្រូវពិចារណាទោសរបស់កាមគុណ ៥ គឺៈ រូប សំឡេង ក្លិន រស ផោដ្ឋព្វ ជានុយនៃសន្ទចវដ្ដ ដើម្បីកុំឲ្យចិត្តនឹករកកាមគុណទាំងនោះជាប់ជំពាក់ក្នុងកម្មដ្ឋាន ត្រូវជម្រះសីលរបស់ខ្លួនឲ្យបរិសុទ្ធ និងពិចារណាបដិបទា គឺផ្លូវដំណើររបស់ព្រះអរិយដែលលោកបដិបត្តិ

ដើម្បីរម្លត់ទុក្ខ។ យោគាវចរត្រូវលះបង់ទិដ្ឋិ "មានតួខ្លួនបដិបត្តិកម្មដ្ឋាន" ព្រោះការបដិបត្តិកម្មដ្ឋានត្រឹមជាកិច្ចរបស់សតិ និងញាណដែលជាបរមត្ថធម៌សុទ្ធសាធ ពេលចម្រើនកម្មដ្ឋានដំបូងអាទិកម្មិក(អ្នកផ្ដើមបដិបត្តិ)រមែងមានចិត្តរាយមាយ ក្រហល់ក្រហាយ ព្រោះអប់រំចិត្តមិនទាន់បានល្អ ដូច្នេះ ចូរកុំទោមនស្ស ត្រូវព្យាយាមបិទទ្វារ ៥ គឺបិទចក្ខុទ្វារកុំឲ្យចិត្តនឹកដល់រូប បិទសោតទ្វារកុំឲ្យចិត្តនឹកដល់សំឡេង បិទឃានទ្វារកុំឲ្យចិត្តនឹកដល់ក្លិន បិទជិវ្ហាទ្វារកុំឲ្យចិត្តនឹកដល់រស បិទកាយទ្វារកុំឲ្យចិត្តនឹកដល់ផោដ្ឋព្វ ត្រូវតាំងសតិរឭកដឹងអារម្មណ៍កម្មដ្ឋាន និងដឹងវារៈចិត្តដែលកើតឡើងជាកុសល ឬជាអកុសល បើចិត្តត្រាច់ទៅតោងអតីតារម្មណ៍នឹកឃើញរឿងអតីត ឬត្រាច់ទៅតោងអនាគតារម្មណ៍នឹកគិតរឿងអនាគត ត្រូវមានសតិដឹងហើយទាញចិត្តមកនៅក្នុងបច្ចុប្បន្នារម្មណ៍ នឹកសម្លឹងអារម្មណ៍កម្មដ្ឋាន។ យោគាវចរត្រូវសម្គាល់លក្ខណតេជោធាតុ ២ យ៉ាង ឧណ្ហតេជោកើតឡើងកាយមានសភាពក្ដៅ សីតតេជោកើតឡើងកាយមានសភាពត្រជាក់ និងវាយោធាតុ ២ យ៉ាង វិត្ថម្ភនវាយោកើតឡើងកាយមានសភាពតឹងរឹង គឺប្រឹងរឹងខ្លួនឯងៗ សមីរណវាយោកើតឡើងកាយមានសភាពកម្រើក ញ័រ។ ចម្រើនអានាបានស្សតិត្រូវប្រកបដោយសតិប្បដ្ឋាន អានាបានស្សតិចែកជា ៤ ចតុក្ក(ចតុក្កមាន ៤ វត្ថុ គឺខ្យល់ដង្ហើម) ចតុក្កទី ១ ជាកាយានុបស្សនាសតិប្បដ្ឋាន សម្ដែងសម្រាប់អាទិកម្មិក(អ្នកបដិបត្តិដំបូង) ចតុក្កទី ២ ជាវេទនានុបស្សនាសតិប្បដ្ឋាន ចតុក្កទី ៣ ជាចិត្តានុបស្សនាសតិប្បដ្ឋាន ចតុក្កទី ៤ ជាធម្មានុបស្សនាសតិប្បដ្ឋាន ចំពោះចតុក្កទី២ ៣ ៤សម្ដែងសម្រាប់បុគ្គលបានឈានតាំងពីបឋមចតុក្ក។ យោគាវចរត្រូវស្គាល់អំពីវាយោ ៤ ប្រភេទគឺ សម្មុតិវាយោ: ខ្យល់នៃការសន្មតិ ដូចជាខ្យល់ព្យុះ ខ្យល់បកល្ហើយៗ, អារម្មណវាយោ: ខ្យល់ដែលជាអារម្មណ៍របស់កម្មដ្ឋាន(វាយោកសិណ និងវាយោធាតុ), សសម្ភារវាយោ: ខ្យល់បកឡើងលើចុះក្រោម ក្នុងផ្ទៃ(ពោះ) ក្នុងក្រពះពោះវៀន ខ្យល់ផ្សាយសព្វក្នុងកាយ ខ្យល់ដង្ហើម (ចិត្តជវាយោ គឺខ្យល់កើតអំពីចិត្តជាសមុដ្ឋាន) និងខ្យល់ខាងក្រៅកាយ, បរមត្ថវាយោ: លក្ខណតឹង កម្រើក ញ័រ ដែលជាផោដ្ឋព្វារម្មណ៍ គឺជាអារម្មណ៍របស់វិបស្សនា៕

*អានាបានស្សតិ ១៦ វត្ថុ:

(១.២.៣.៤ ជាកាយានុបស្សនាសតិប្បដ្ឋាន សតិជាតួវិបស្សនារឭកដឹងផោដ្ឋព្វ:)

១-ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ. កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង។

-ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ. កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង។ ការចម្រើនអានាបានស្សតិត្រូវប្រកបដោយសតិ(សេចក្តីរឭក) និងញាណ(សេចក្តីដឹង)ធ្វើឲ្យប្រាកដចំពោះធម៌បីប្រការ គឺនិមិត្ត(ចុងច្រមុះដែលខ្យល់ប៉ះត្រូវជាទីចងទុកនៃសតិ) ១ ខ្យល់ដង្ហើមចេញ ១ ខ្យល់ដង្ហើមចូល ១ បុគ្គលណាមានធម៌បីប្រការនេះ កម្មដ្ឋានរបស់បុគ្គលនោះរមែងបានដល់ឧបចារសមាធិ និងអប្បនាសមាធិ។ ពេលចាប់ផ្តើមហ្វឹកហាត់ដំបូង យោគាវចរត្រូវអង្គុយពែនភ្នែនដាក់ជើងឆ្វេងនៅក្រោម ដាក់ជើងស្តាំលើជើងឆ្វេង គឺដាក់បាទជើងស្តាំប៉ះត្រឹមភ្លៅជើងឆ្វេង ហើយកំភួនជើងស្តាំដាក់ចំកណ្តាលប្រអប់ជើងឆ្វេងត្រង់កន្លែងផត(ភ្នែនបែបនេះមិនបត់ជង្គង់តឹងពេក ហើយក៏មិនធូរពេក បើភ្នែនតឹងងាយនឹងស្ពឹកជើង បើភ្នែនធូរគឺកំភួនជើងស្តាំកល់លើភ្នែកគោរ ឬកែងជើងឆ្វេងក៏ងាយនឹងស្ពឹកជើងដែរ) និងធ្វើដងខ្លួនឲ្យត្រង់ដើម្បីសម្រួលដល់ផ្លូវដង្ហើម បន្ទាប់មកត្រូវញ៉ាំងចិត្តឲ្យមានឆន្ទ ហើយប្រមូលអារម្មណ៍ឲ្យមូលតាំងសតិត្រង់និមិត្ត(ចុងច្រមុះ) ឬរឹមបបូរមាត់(សម្រាប់បុគ្គលមានចុងច្រមុះខ្លី) គឺផ្ចង់ចិត្តសម្លឹងចុងច្រមុះរហូតដឹងថាសតិតាំងនៅចុងច្រមុះ ទើបបិទភ្នែកកំណត់ដឹងខ្យល់ដង្ហើមប៉ះខ្ទប់ត្រង់និមិត្ត ដកដង្ហើមចេញវែង ត្រូវបរិកម្ម(និយាយក្នុងចិត្ត)កំណត់ទុកក្នុងចិត្តថា ខ្យល់ចេញវែង ដកដង្ហើមចូលវែង ត្រូវបរិកម្មកំណត់ទុកក្នុងចិត្តថា ខ្យល់ចូលវែង រហូតសតិតាំងនៅត្រង់និមិត្តដឹងអារម្មណ៍(អស្សាសប្បស្សាស)មិនមានចន្លោះ បានដល់បរិកម្មនិមិត្ត(អារម្មណ៍ដែលចិត្តកំណត់ទុកដោយប្រពៃ) ហើយសតិនឹងលះបង់បរិកម្មចោលមកកំណត់ដឹងខ្យល់ចេញវែង ខ្យល់ចូលវែង(ខណនេះច្រមុះរបស់យោគាវចរខ្លះមានអាការស្រើបៗ និងពាល់ត្រូវខ្យល់ដង្ហើមប្រព្រឹត្តទៅជាអនត្តា គឺខ្យល់ដង្ហើមចេញចូលដោយធម្មជាតិឯងៗ មិនមានសត្វ បុគ្គល តួខ្លួនជាអ្នកដកដង្ហើមឡើយ ព្រោះខ្យល់ដង្ហើមកើតអំពីចិត្តជាសមុដ្ឋាន ជួនវែងជួនខ្លី ជួនខ្លាំងជួនខ្សោយ ជួនញាប់ប្រព្រឹត្តទៅមិនទៀងជាអនិច្ចំ ខ្យល់ដង្ហើមកើតឡើងប្រព្រឹត្តទៅចេញអស់ក៏រលត់ ហើយកើតឡើងប្រព្រឹត្តទៅចូលអស់ក៏រលត់ សភាវធម៌ដែលមានកិរិយាកើតរលត់ជាទុក្ខំ)។ កាលយោគាវចរ ប្រមូលអារម្មណ៍មូលតាំងនៅថ្ងាសត្រង់លើចន្លោះចិញ្ចើមក្នុងភាវនា

ព្រមទាំងមានពន្លឺខាងក្រៅជាបច្ច័យផង ជួនក៏ឃើញតាមមនោទ្វារមានពណ៌ខ្មៅ ស ក្រហម លឿង បៃតង ខៀវ ស្វាយ ផ្កាឈូក ជួនពណ៌មួយរីកក្នុងពណ៌មួយ ជួនពណ៌ក្រៅរូបពណ៌ក្នុងឲ្យរួមបាត់ តែចិត្តកុំភ្ញាក់ផ្អើលជាប់ជំពាក់ ហើយត្រូវបន្តតាំងសតិត្រង់ចុងច្រមុះកំណត់ដឹងខ្យល់ដង្ហើម។ បើយោគាវចរចម្រើនដល់ឈានថ្នាក់ខ្ពស់មានបំណងឃើញអ្វីមួយ ត្រូវអធិដ្ឋានហើយធ្វើអារម្មណ៍ឲ្យមុតស្រួចទម្លុះជ្រែកពណ៌នោះ នឹងបានឃើញអ្វីមួយនៅពីក្រោយពណ៌នោះតាមឧបនិស្ស័យ៕

២-រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាតិ. កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី។

-រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតិ. កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី។ សភាពខ្យល់ក្នុងកាយប្រព្រឹត្តទៅខ្លះឡើងលើ ខ្លះចុះក្រោម ខ្លះកាត់ទទឹងកាយ ខ្លះជាដុំសកសៀតណែនក្នុងកាយ ខ្លះរាយបែកផ្សាយទៅពេញកាយបណ្ដាលឲ្យរសេបរសឹប តឹងមុខមាត់ ណែនខ្លួន ដៃ ជើង ពោះ ទ្រូង ក ក្បាលជាសភាពខ្យល់គ្រោតគ្រាតប្រព្រឹត្តក្នុងកាយមិនទៀងទាត់ បង្កើតជាទុក្ខវេទនា តែកុំទោមនស្ស ត្រូវពិចារណាថា៖ ទុក្ខវេទនាកើតឡើងអាស្រ័យខ្យល់ក្នុងកាយគ្រោតគ្រាតដែលកើតអំពីចិត្តគ្រោតគ្រាត វេទនាជាសង្ខារធម៌ប្រព្រឹត្តទៅជាអនិច្ចំ ទុក្ខំ អនត្តា ហើយត្រូវបន្តតាំងសតិត្រង់ចុងច្រមុះកំណត់ដឹងខ្យល់ដង្ហើម៕

៣-សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សា(ព្យាយាម)ថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវខ្យល់ខាងដើមគឺផ្ចិត កណ្ដាលគឺទ្រូង ចុងគឺចុងច្រមុះ ហើយដកដង្ហើមចេញ។

-សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវខ្យល់ខាងដើមគឺចុងច្រមុះ កណ្ដាលគឺដើមទ្រូង ចុងគឺផ្ចិត ហើយដកដង្ហើមចូល។ យោគាវចរតាំងសតិមាំល្អនៅចុងច្រមុះហើយក៏អាចនឹងដឹងដំណើររបស់អស្សាសប្បស្សាសសព្វក្នុងកាយដែលមានភាពល្អិតៗ ស្តើងៗ ក្នុងខ្យល់ដង្ហើមនេះ សសម្ភារវាយោបក់ទទឹងកាយញ៉ាំងកាយទ្រេតទៅស្ដាំ ទ្រេតទៅឆ្វេង ឱនទៅមុខ ផ្ងាកមកក្រោយ ឃ្លេងឃ្លោង យោលវិល ព្រោះចិត្តស្ងប់កាយមិនស្ងប់។ ជួនបក់ពីលើចុះក្រោមមានភាពធ្ងន់ចុះមកក្រោម ពីក្រោមឡើងលើមានភាពផើតឡើងទល់

នឹងលលាដ៍ក្បាល ជួនបរមត្ថវាយោកើតឡើងមានលក្ខណតឹង កម្រើក ញ័រកាយ ជួនភាពត្រជាក់ស្រួលផ្សាយពេញសព៌ាង្គកាយ កើតជាសុខវេទនា តែកុំជាប់ជំពាក់ ត្រូវពិចារណាថា៖ សុខវេទនាកើតឡើងអាស្រ័យខ្យល់ល្អិតផ្សាយសព្វសព៌ាង្គកាយ ដែលកើតអំពីចិត្តស្ងប់ ការជាប់ជំពាក់អារម្មណ៍ដែលជាកាមគុណទាំងឡាយ ធ្វើឲ្យវិលវល់ក្នុងវដ្តទុក្ខ ហើយត្រូវបន្តតាំងសតិត្រង់ចុងច្រមុះកំណត់ដឹងខ្យល់ដង្ហើម៕

៤-បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ(អស្សាសប្បស្សាសៈ) ដកដង្ហើមចេញ។

-បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ ដកដង្ហើមចូល។ កាលតាំងសតិទុកត្រង់និមិត្តយ៉ាងប្រាកដរហូតរម្ងាប់កាយ និងចិត្តឲ្យស្ងប់(សភាពស្ងប់របស់កាយ និងចិត្តគ្រាន់តែកើតពីការអប់រំចម្រើនកម្មដ្ឋានប៉ុណ្ណោះ មិនមានសត្វ បុគ្គល តួខ្លួនជាអ្នកស្ងប់ឡើយ ដូច្នេះកុំជាប់ជំពាក់នឹងសភាពស្ងប់) ខ្យល់ដង្ហើមក៏ល្អិតសុខុម ស្ងប់រម្ងាប់តាមខណៈៗ យោគាវចរខ្លះមានសតិរឹងមាំ និងញាណចាស់ក្លាអាចកំណត់ដឹងខ្យល់ដង្ហើមចេញពីគល់ច្រមុះមកត្រឹមចុងច្រមុះក៏ចូលទៅវិញ ខ្យល់ដង្ហើមនោះក៏រួមតូចឆ្មារប្រែជាត្រជាក់ប៉ះចុងច្រមុះដកដង្ហើមចូលកើតសុខវេទនា ដកដង្ហើមចេញជាខ្យល់ក្តៅប៉ះចុងច្រមុះកើតទុក្ខវេទនា កាលបើសុខ ទុក្ខ សោមនស្ស និងទោមនស្សរលត់ទៅ ឧបេក្ខា(វេទនា) ចិត្តក៏កើតឡើងមានសភាពព្រងើយៗជាកណ្តាល ស្ងប់ទៅៗរហូតបានដល់ទម្លុះខណិកសមាធិ ចម្រើនតទៅទៀតនឹងបានដល់បស្សទ្ធិទម្លុះឧបចារសមាធិដែលជាចិត្តវិសុទ្ធិ កាយមានសភាពស្រាលស្រឡះត្រជាក់។ ក្នុងឧបចារសមាធិ យោគាវចរខ្លះកើតឧគ្គហនិមិត្ត ខ្លះកើតបដិភាគនិមិត្ត ខ្លះទម្លុះអប្បនាសមាធិ។ ឧបចារសមាធិ និងអប្បនាសមាធិមានតត្រមជ្ឈត្តុបេក្ខា គឺភាពព្រងើយជាកណ្តាលក្នុងធម៌នោះៗកើតឡើងព្រោះមិនមានសេចក្តីព្យាយាមដើម្បីញុំាងឈានឲ្យកើតឡើងទៀត៕

(៥.៦.៧.៨ ជាវេទនានុបស្សនាសតិប្បដ្ឋាន សតិជាតួវិបស្សនារឭកដឹងវេទនា)

៥-បីតិបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវបីតិ ដកដង្ហើមចេញ។

-បីតិបដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវបីតិ ដកដង្ហើមចូល។ ការចូលបឋមជ្ឈាន និងទុតិយជ្ឈានដែលមានបីតិជាអង្គ៕

៦-សុខបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវសុខ ដកដង្ហើមចេញ។

-សុខបដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវសុខ ដកដង្ហើមចូល។ ការចូលតតិយជ្ឈានដែលមានសុខ(កាយិកសុខ: កាយត្រជាក់សុខស្រួលក្នុងឈានក្រៃលែង និង ចេតសិកសុខ: ចិត្តស្ងប់សុខស្រឡះក្នុងឈានក្រៃលែង)ជាអង្គ៕

៧-ចិត្តសង្ខារបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវចិត្តសង្ខារ ដកដង្ហើមចេញ។

-ចិត្តសង្ខារបដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវចិត្តសង្ខារ ដកដង្ហើមចូល។ ការចូលចតុត្ថជ្ឈានដែលមានឧបេក្ខាវេទនា៕

៨-បស្សម្ភយំ ចិត្តសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងរម្ងាប់នូវចិត្តសង្ខារ ដកដង្ហើមចេញ។

-បស្សម្ភយំ ចិត្តសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងរម្ងាប់នូវចិត្តសង្ខារ ដកដង្ហើមចូល។ ការរម្ងាប់នូវចិត្តសង្ខារ(វេទនា និងសញ្ញា)ដែលគ្រោតគ្រាតឲ្យស្ងប់។ កាលវេទនា និងសញ្ញាស្ងប់រម្ងាប់ដោយអំណាចឈានចិត្តហើយយោគាវចរខ្លះបានពាល់ត្រូវបាតុភូត ដូចជាមានធាតុ ឬធាតុត្រជាក់ស្រោចលើក្បាលជ្រាបសព៌ាងកាយស្រឹបៗ ជួនធាតុ ឬធាតុត្រជាក់ស្រោបក្តោបសព៌ាងកាយ៕

(៩.១០.១១.១២ ជាចិត្តានុបស្សនាសតិប្បដ្ឋាន សតិជាតួវិបស្សនាព្ញកដឹងចិត្ត)

៩-ចិត្តបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវចិត្ត ដកដង្ហើមចេញ។

-ចិត្តបដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវចិត្ត ដកដង្ហើមចូល។ ការកំណត់ដឹងឈានចិត្តទាំង ៤៕

១០-អភិប្បមោទយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យរីករាយក្រៃលែង ដកដង្ហើមចេញ។

-អភិប្បមោទយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យរីករាយក្រៃលែង ដកដង្ហើមចូល។ ការចូលបឋមជ្ឈាន និងទុតិយជ្ឈានដែលប្រកបដោយផរណាបីតិជាអង្គ៕

១១-សមាទហំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យតាំងមាំស្មើ ដកដង្ហើមចេញ។

-សមាទហំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យតាំងមាំស្មើ ដកដង្ហើមចូល។ ការធ្វើចិត្តឲ្យតាំងមាំស្មើក្នុងអារម្មណ៍ដោយអំណាចនៃអប្បនា៕

១២-វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងរដោះចិត្តចាកនីវរណ ដកដង្ហើមចេញ។

-វិមោចយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងរដោះចិត្តចាកនីវរណ ដកដង្ហើមចូល។ ការរដោះចិត្តចាកនីវរណដោយបឋមជ្ឈាន ចាកវិតក្កវិចារដោយទុតិយជ្ឈាន ចាកបីតិដោយតតិយជ្ឈាន ចាកសុខដោយចតុត្ថជ្ឈាន។ វិបស្សនា: រដោះចិត្តចាកនិច្ចសញ្ញាដោយអនិច្ចានុបស្សនា ចាកសុខសញ្ញាដោយទុក្ខានុបស្សនា ចាកអត្តសញ្ញាដោយអនត្តានុបស្សនា ចាកនន្ទិ(ការភ្លើតភ្លើន គឺតណ្ហាប្រកបដោយបីតិ)ដោយនិព្វិទានុបស្សនា ចាករាគដោយវិរាគានុបស្សនា ចាកសមុទយដោយនិរោធានុបស្សនា (បញ្ញាដែលតាមពិចារណាឃើញការរលត់ទៅនៃសង្ខារទាំងឡាយ) ចាកអាទាន(ការប្រកាន់មាំ)ដោយបដិនិស្សគ្គានុបស្សនា(អនុបស្សនាដែលប្រព្រឹត្តទៅដោយអាការលះបង់)៕

(១៣.១៤.១៥.១៦ ជាធម្មានុបស្សនាសតិប្បដ្ឋាន សតិជាតួវិបស្សនារឭកដឹងធម្មា)

១៣-អនិច្ចានុបស្សី អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកពិចារណាឃើញថា មិនទៀង ដកដង្ហើមចេញ។

-អនិច្ចានុបស្សី បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកពិចារណាឃើញថា មិនទៀង ដកដង្ហើមចូល។ វិបស្សនាឃើញបញ្ចក្ខន្ធដែលមិនទៀង គឺកើតឡើងហើយរលត់ទៅ៕

១៤-វិរាគានុបស្សី អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកពិចារណាឃើញនូវការប្រាសចាកតម្រេក ដកដង្ហើមចេញ។

-វិរាគានុបស្សី បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកពិចារណាឃើញនូវការប្រាសចាកតម្រេក ដកដង្ហើមចូល។ វិរាគ គឺការប្រាសទៅ មាន ២ គឺ: ខយវិរាគ: បញ្ចក្ខន្ធរលត់ទៅដែលមានជាខណៈ គឺពិចារណាឃើញដោយវិបស្សនាញាណ ១ អច្ចន្តវិរាគ(ឈ្មោះព្រះនិព្វាន)ជាធម៌ម្យ៉ាង កាលបុគ្គលសម្រេចហើយសង្ខារទាំងឡាយក៏រមែងរលត់ទៅជាប្រាកដ គឺពិចារណាឃើញដោយមគ្គញាណ ១។ វិបស្សនាញាណលះបង់កិលេសដោយតទង្គប្បហាន(លះជាខណៈៗ) ក៏បង្អោនចិត្តទៅអច្ចន្តវិរាគ។ មគ្គញាណលះបង់កិលេសជាសមុច្ឆេទដោយតទង្គប្បហាន៕

១៥-និរោធានុបស្សី អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកពិចារណាឃើញនូវការរលត់ ដកដង្ហើមចេញ។

-និរោធានុបស្សី បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកពិចារណាឃើញនូវការរលត់ ដកដង្ហើមចូល។ មានអត្ថដូចវិរាគានុបស្សីដែរ គ្រាន់តែដាក់បទថា"និរោធ"ជំនួសត្រង់បទថា"វិរាគ"៕

១៦-បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកពិចារណាឃើញនូវការរលាស់ចោល ដកដង្ហើមចេញ។

-បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ. ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកពិចារណាឃើញនូវការរលាស់ចោល ដកដង្ហើមចូល។ បដិនិស្សគ្គក៏មាន ២ គឺ: បរិច្ចាគបដិនិស្សគ្គ គឺការលះបង់ដោយការបរិច្ចាគជាតទង្គ ឬការលះបង់ដោយការបរិច្ចាគជាសមុច្ឆេទ ១ បក្ខន្ទនបដិនិស្សគ្គ គឺការបង្អោនចិត្តទៅក្នុងព្រះនិព្វាន ឬមាន

ព្រះនិព្វានជាអារម្មណ៍។ វិបស្សនាញាណលះបង់កិលេស និងខន្ធ(វិបាក) ព្រមទាំង អភិសង្ខារ(កម្ម) ដោយតទង្គប្បហាន ព្រោះឃើញទោសក្នុងសង្ខារធម៌ ក៏បង្អោនចិត្ត ទៅក្នុងព្រះនិព្វាន។ មគ្គញាណលះបង់កិលេស និងខន្ធ ព្រមទាំងអភិសង្ខារដោយ សមុច្ឆេទប្បហាន ហើយក៏មានព្រះនិព្វានជាអារម្មណ៍ គឺស្ងប់សុខត្រជាក់ទៅៗៗ៕

*លក្ខណសម្គាល់នៃសុខវេទនាពុំមែនជាអង្គឈាន និងសុខជាអង្គឈាន:

ក្នុងខ្យល់ទី ៣ យោគាវចរបានពាល់ត្រូវសុខវេទនា គឺកាយត្រជាក់ស្រួលដែលពុំ មែនជាអង្គឈាន សុខវេទនានោះកើតឡើងអាស្រ័យចិត្តស្ងប់ ខ្យល់ដង្ហើមល្អិត ស្ងប់ ពុំមានផរណាបីតិ(អង្គឈាន)ជាបុព្វភាគ។ សុខដែលជាអង្គរបស់ឈានកើតឡើង អាស្រ័យមានផរណាបីតិជាបុព្វភាគ គឺបីតិកើតឡើងព្រឺព្រួចកាយខ្វាកៗ ធូន់ខ្លួន ត្រជាក់សព្វសព៌ាង្គកាយ សុខក៏កើតឡើងកាយរាងសង្កៀរស្រួលខ្លួន។ ចូរចំណាំ៖ បើយោគាវចរចម្រើនសមាធិបានដល់ចិត្តស្ងប់ពាល់ត្រូវសុខវេទនា សូមកុំមានការ ភាន់ច្រឡំថាបានឈាន ព្រោះសូម្បីឧបចារសមាធិ ក៏ត្រូវចម្រើនប្រកបដោយអង្គ ឈាន(អង្គឈានក្នុងឧបចារសមាធិមានកម្លាំងខ្សោយ)នីមួយៗគ្រប់អង្គ រហូតរម្ងាប់ នូវនីវរណធម៌ ញ៉ាំងមហាកុសលញាណសម្បយុត្តចិត្តឲ្យមានកម្លាំងទម្លុះអប្បនា សមាធិ គឺចិត្តសង្កត់នូវកាមាវចរគោត្រហើយស្ទុះចូលទៅកាន់មហគ្គតគោត្រ៕

*បហាន(ប្រហារកិលេស) ៥ យ៉ាង:

១-តទង្គប្បហាន: លះកិលេសជាខណៈៗដោយវិបស្សនាញាណ។

២-វិក្ខម្ភនប្បហាន: លះនីវរណធម៌ដោយការគ្របសង្កត់របស់ឈាន។

៣-សមុច្ឆេទប្បហាន: លះកិលេសដាច់មិនឲ្យត្រឡប់ដោយអរិយមគ្គ។

៤-បដិបស្សទ្ធិប្បហាន: កិលេសទាំងឡាយដែលស្ងប់រម្ងាប់ក្នុងខណនៃអរិយផល។

៥-និស្សរណប្បហាន: ព្រះនិព្វានដែលលះបង់អស់នូវគ្រឿងតាក់តែងទាំងពួង។

ជ-ឧបចារសមាធិ(កាមាវចរមហាកុសលចិត្ត)

យោគាវចរអប់រំចិត្តចម្រើនភាវនាណាមួយនៃកម្មដ្ឋាន ៤០ មានសតិតាំងមាំល្អ ហើយ ចិត្តក៏ស្ងប់ជាបច្ច័យញ៉ាំងកាយឲ្យស្ងប់ កាលចិត្ត និងកាយស្ងប់ហើយ ក៏ជាបច្ច័យញ៉ាំងខ្យល់ដង្ហើមឲ្យស្ងប់រម្ងាប់ផងដែរ កាលបើខ្យល់ដង្ហើមស្ងប់រម្ងាប់ហើយ ចិត្តក៏តាំងស្ងប់ស៊ប់ក្នុងភាវនារហូតទម្លុះខណិកសមាធិ ចម្រើនតទៅទៀតនឹងបានដល់បស្សទ្ធិទម្លុះឧបចារសមាធិដែលជាចិត្តវិសុទ្ធិ កាយត្រជាក់ស្រាលស្រឡះ។ ក្នុងឧបចារសមាធិ យោគាវចរខ្លះកើតឧគ្គហនិមិត្ត ឃើញដូចប៉ុយគ ប៉ុយសំឡី ខ្សែ យោគាវចរខ្លះកើតបដិភាគនិមិត្ត ឃើញដូចដួងផ្កាយ ដុំកែវមណី ដុំគជ់ វត្ថុមានសម្ផស្សគ្រោតគ្រាត គ្រាប់កប្បាស ចម្រូងឈើខ្លឹម ខ្សែសង្វារវែង កម្រងផ្កា កម្សួលផ្សែង សរសៃពីងពាងដែលសន្ធឹង ដុំពពក ផ្កាឈូក កង់រថ វង់ព្រះចន្ទ វង់ព្រះអាទិត្យ ជួននិមិត្តឃើញរឿងដែលបានសន្សំក្នុងសន្តានកាលពីអតីតជាតិក៏មាន។ បុគ្គលខ្លះបានចម្រើនឈាន និងសន្សំកុសលច្រើនពីអតីតជាតិមកជាឧបនិស្ស័យ ពេលមានសទ្ធាបញ្ញាជ្រះថ្លាចំពោះព្រះពុទ្ធគុណក៏កើតផរណាបីតិទម្លុះឈាន។ បន្ទាប់ពីបានដល់ឧបចារសមាធិហើយ បើយោគាវចរមានបំណងឡើងកាន់អប្បនាសមាធិ ត្រូវតាំងចិត្តឲ្យស្ងប់នឹងស្មើប្រកបដោយសតិ និងញាណរឹងមាំរម្ងាប់នូវនីវរណធម៌ បើមានបំណងឡើងកាន់មគ្គផល ត្រូវចម្រើនរូបកម្មដ្ឋាន និងអរូប(វេទនា)កម្មដ្ឋានដែលជាវិបស្សនា៕

*ពោធិបក្ខិយធម៌ គឺពួកនៃធម៌ជាគ្រឿងត្រាស់ដឹងអរិយសច្ច មាន ៣៧ ប្រការ:

+សតិប្បដ្ឋាន ជាធម៌តាំងសតិរឭកពិចារណានូវធម៌ ៤ យ៉ាង:

១-កាយានុបស្សនាសតិប្បដ្ឋាន: កាយ + អនុបស្សនា(ការពិចារណារឿយៗ) + សតិ គឺសតិរឭកពិចារណារឿយៗនូវកាយក្នុងកាយ(ធម៌ដែលប្រជុំកើតឡើងក្នុងកាយ ដូចជាអស្សាសប្បស្សាសដែលប្រជុំកើតឡើងក្នុងកាយ) សំដៅដល់ធម៌មួយក្នុងធម៌ទាំង ៦ គឺ: អានាបានបព្វ ផ្នែកខ្យល់ដង្ហើម, ឥរិយាបថបព្វ ផ្នែកឥរិយាបថ ដេក ដើរ អង្គុយ ឈរ, សម្បជញ្ញបព្វ ផ្នែកសេចក្ដីភ្ញាក់រឭក, បដិកូលបព្វ ផ្នែកខ្ពើមរអើមក្នុងកាយ, ធាតុបព្វ ផ្នែកពិចារណារូបធាតុ, នវសីវថិកាបព្វ ផ្នែកពិនិត្យសាកសព ៩ យ៉ាង។

២-វេទនានុបស្សនាសតិប្បដ្ឋានៈ សតិរឭកពិចារណារឿយៗនូវវេទនាក្នុងវេទនា(ធម៌ដែលប្រជុំកើតឡើងក្នុងវេទនា ដូចជាសុខវេទនាដែលប្រជុំកើតឡើងក្នុងវេទនា) សំ-ដៅដល់វេទនាមួយក្នុងវេទនាទាំង ៩ គឺៈ សុខវេទនា, ទុក្ខវេទនា, អទុក្ខមសុខវេទនា (វេទនាមិនជាទុក្ខមិនជាសុខ), សាមិសសុខវេទនា(សោមនស្សវេទនាដែលអាស្រ័យកាមគុណ ៥ ប្រព្រឹត្តទៅក្នុងទ្វារ ៦), សាមិសទុក្ខវេទនា, សាមិសអទុក្ខមសុខវេទនា, និរាមិសសុខវេទនា(សោមនស្សវេទនាដែលអាស្រ័យនេក្ខម្មប្រព្រឹត្តទៅក្នុងទ្វារ ៦), និរាមិសទុក្ខវេទនា, និរាមិសអទុក្ខមសុខវេទនា។ វេទនាទាំង ៩ យ៉ាងខាងលើនេះ និយាយតែអំពីវេទនាផ្លូវកាយ ពុំមាននិយាយអំពីផ្លូវចិត្តឡើយ ព្រះមានព្រះភាគទ្រង់សម្តែងសង្កត់ធ្ងន់ទៅលើកាយវេទនាយ៉ាងនេះ ក៏ព្រោះតែព្រះអង្គទ្រង់ឈ្វេងយល់ថា ចិត្ត និងកាយមានការទាក់ទងគ្នាយ៉ាងជិតស្និទ្ធណាស់ រហូតទាល់តែអ្វីៗដែលកើតឡើងនៅក្នុងចិត្តតែងតែបញ្ចេញខ្លួនវាមកជាវេទនាលើកាយ។

៣-ចិត្តានុបស្សនាសតិប្បដ្ឋានៈ សតិរឭកពិចារណារឿយៗនូវចិត្តក្នុងចិត្ត(ធម៌ដែលប្រជុំកើតឡើងក្នុងចិត្ត ដូចជារាគដែលប្រជុំកើតឡើងក្នុងចិត្ត) សំដៅដល់ចិត្តមួយក្នុងចិត្តទាំង ១៦ គឺៈ សរាគំ ចិត្តប្រកបដោយរាគ(លោភមូលចិត្ត) ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគ, វីតរាគំ ចិត្តប្រាសចាករាគ(លោកិយកុសលចិត្ត និងអព្យាកតចិត្ត) ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគ, សទោសំ ចិត្តប្រកបដោយទោស ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោស, វីតទោសំ ចិត្តប្រាសចាកទោស ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោស, សមោហំ ចិត្តប្រកបដោយមោហ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហ, វីតមោហំ ចិត្តប្រាសចាកមោហ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហ, សង្ខិត្តំ ចិត្តរួញរា ក៏ដឹងច្បាស់ថា ចិត្តរួញរា, វិក្ខិត្តំ ចិត្តរាយមាយ ក៏ដឹងច្បាស់ថា ចិត្តរាយមាយ, មហគ្គតំ ចិត្តដល់នូវភាវជាធំ(ជារូបាវចរ និងអរូបាវចរ) ក៏ដឹងច្បាស់ថា ចិត្តដល់នូវភាវជាធំ, អមហគ្គតំ ចិត្តមិនដល់នូវភាវជាធំ(ជាកាមាវចរ) ក៏ដឹងច្បាស់ថា ចិត្តមិនដល់នូវភាវជាធំ, សឧត្តរំ ចិត្តនៅមានចិត្តដទៃប្រសើរជាង(ជាកាមាវចរ) ក៏ដឹងច្បាស់ថា ចិត្តនៅមានចិត្តដទៃប្រសើរជាង, អនុត្តរំ ចិត្តមិនមានចិត្តដទៃប្រសើរជាង(ជារូបាវចរ និងអរូបាវចរ) ក៏ដឹងច្បាស់ថា ចិត្តមិនមានចិត្តដទៃប្រសើរជាង, សមាហិតំ ចិត្តតាំងនៅមាំ(ជាឧបចារសមាធិ និងអប្បនាសមាធិ) ក៏ដឹងច្បាស់ថា ចិត្តតាំងនៅមាំ, អសមាហិតំ ចិត្តមិនតាំងនៅមាំ(ប្រាសចាកសមាធិទាំង ២) ក៏ដឹងច្បាស់ថា ចិត្តមិនតាំង

នៅមាំ, វិមុត្តំ ចិត្តរួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តរួចស្រឡះ, អវិមុត្តំ ចិត្តមិនទាន់រួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះ(ពាក្យថា ចិត្តរួចស្រឡះក្នុងទីនេះ សំដៅយកចិត្តដែលប្រកបដោយវិមុត្តិ ២ ប្រការគឺ តទង្គវិមុត្តិ ១ និងវិក្ខម្ភនវិមុត្តិ ១។ អនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម ហៅថា តទង្គវិមុត្តិ ព្រោះជាធម្មជាតិរួចស្រឡះចាកនិច្ចសញ្ញា តាមទំនងដែលយោគីបានកំណត់នូវអង្គនៃធម៌ជាសត្រូវដល់ធម៌នោះ។ សមាបត្តិ ៨ ហៅថា វិក្ខម្ភនវិមុត្តិ ព្រោះជាធម្មជាតិរួចស្រឡះចាកពួកអកុសលធម៌ មាននីវរណៈជាដើម តាមទំនងដែលយោគីបានសង្កត់សង្កិនដោយឈាន)។ ចិត្តានុបស្សនា ព្រះពុទ្ធបរមគ្រូទូន្មានភិក្ខុឲ្យពិចារណារឿយៗដោយសតិរឭកដឹងជានិច្ចអំពីចិត្តប្រកបដោយកិលេស និងចិត្តមិនប្រកបដោយកិលេស ដើម្បីព្យាយាមដុតកម្លោច(តប)៕

៤-ធម្មានុបស្សនាសតិប្បដ្ឋានៈ សតិរឭកពិចារណារឿយៗនូវធម៌ក្នុងធម៌(ធម៌ដែលប្រជុំកើតឡើងក្នុងធម៌ ដូចជាកាមច្ឆន្ទដែលប្រជុំកើតឡើងក្នុងនីវរណធម៌) សំដៅដល់ធម៌មួយក្នុងធម៌ទាំង ៥ គឺ: នីវរណធម៌ ៥, ខន្ធ ៥, អាយតន ១២, ពោជ្ឈង្គ ៧, អរិយសច្ចធម៌ ៤ គឺពិចារណាថា៖ ក្នុងខណៈនេះមានធម៌អ្វីនៅក្នុងចិត្តរបស់ខ្លួន ក៏ដឹងច្បាស់ធម៌នោះៗដោយពិចារណាធម៌ទាំងនោះជាកុសល អកុសល នឹងអព្យាកត៕

សតិប្បដ្ឋានកើតមានពីការបដិបត្តិសមថកម្មដ្ឋានដល់ចិត្តវិសុទ្ធិ ហើយបន្តបដិបត្តិវិបស្សនាកម្មដ្ឋានទៅទៀត សតិតាំងនៅមាំរឭកដឹងកាយ វេទនា ចិត្ត ធម្មាទាន់ពេលមិនយឺតយូរ សតិជាឧបការដល់បញ្ញាកើតឡើងពិចារណាហេតុប្បច្ចយលះសេចក្តីប្រកាន់ក្នុងសង្ខារធម៌ បានដល់សតិប្បដ្ឋានវិបស្សនា ឧបមាដូចជាម្តាយ(សតិ)មើលថែរំឭកកូន(ចិត្ត)គ្រប់ហេតុគ្រប់វេលា ឯឪពុក(បញ្ញា)ពន្យល់ហេតុផលអប់រំ។ បើមិនមានសតិប្បដ្ឋានទេក៏ប្រកាន់វេទនាថាជាតួខ្លួន កាលបើមានទុក្ខទោមនស្សកើតឡើងក៏មិនពេញចិត្តហើយប្រកាន់ថាអាត្មាដល់នូវទុក្ខទោមនស្ស ជាប់ជំពាក់នូវសេចក្តីប្រាថ្នា(តណ្ហា)សូមកុំឲ្យកើតមានទុក្ខទោមនស្ស កាលបើមានសុខសោមនស្សកើតឡើងក៏ពេញចិត្តហើយប្រកាន់ថាអាត្មាដល់នូវសុខសោមនស្ស ធ្វើឲ្យមានសេចក្តីប្រមាទព្រមទាំងជាប់ជំពាក់នូវសេចក្តីប្រាថ្នាសូមឲ្យបានសុខរហូត បើនៅជាឧបេក្ខាក៏ព្រងើយៗ។ បើមានសតិប្បដ្ឋាន ពេលមានសុខសោមនស្ស ឬទុក្ខទោមនស្សកើត

ឡើង សតិរមែងរឭកដឹងទាន់ពេលមិនយឺតយូរ បញ្ញាពិចារណាឃើញវេទនាកើតឡើងអាស្រ័យនាមរូបដែលជាបរមត្ថធម៌កើតរលត់មិនទៀង ជាទុក្ខ មិនមែនតួខ្លួន ហើយលះសេចក្ដីប្រកាន់ថាជាតួខ្លួន ជាពិសេសនៅពេលសោមនស្សកើតឡើងសតិក៏រឭកដឹងទាន់ពេលមិនយឺតយូរ បញ្ញាពិចារណាសោមនស្សដែលកើតឡើងប្រកបជាមួយកុសលចិត្ត ឬអកុសលចិត្ត ឧទាហរណ៍ៈ បុរសម្នាក់កសាងធម្មទាន ពេលមានបរិស័ទចូលបច្ច័យ បុរសនោះមានចិត្តសោមនស្ស សតិក៏រឭកដឹងទាន់ពេលមិនយឺតយូរ បញ្ញាពិចារណាហេតុប្បច្ច័យដែលសោមនស្សកើតឡើង គឺថាសោមនស្សកើតឡើងព្រោះឃើញបរិស័ទមានសទ្ធាក្នុងការកសាងធម្មទាន ជាសោមនស្សដែលកើតឡើងប្រកបនឹងកុសលចិត្ត បើសោមនស្សកើតឡើងព្រោះឃើញលាភបានមកពីការកសាងធម្មទាន ជាសោមនស្សដែលកើតឡើងប្រកបនឹងអកុសលចិត្តត្រូវតម្រង់ទិដ្ឋិ (ទិដ្ឋុជុកម្មមយ)លះសោមនស្សនោះចោល។ ម្យ៉ាងទៀត ពេលដែលឧទ្ធច្ចកុក្កុច្ចកើតឡើងសៅហ្មងចិត្ត សតិរឭកដឹងទាន់ពេលមិនយឺតយូរ បញ្ញាក៏ពិចារណាបច្ច័យដែលនាំឲ្យកើតឧទ្ធច្ចកុក្កុច្ច គឺឃើញថាការដែលបានប្រព្រឹត្តមនោទុច្ចរិតសន្សំអកុសលចេតនាក្នុងសន្ដាន នឹងមានឱកាលឲ្យផលដល់ជីវិតក្នុងសង្សារវដ្តជាពុំខាន ដូច្នេះ អកុសលធម៌ទាំងឡាយកុំថាឡើយជាកាយទុច្ចរិត ឬវចីទុច្ចរិត សូម្បីតែមនោទុច្ចរិតក៏គួរសង្វេគក្រៃលែង អារម្មណ៍សង្វេគនោះតាំងនៅរហូតរម្ងាប់សេចក្ដីសៅហ្មង។ សួរថាៈ អកុសលចិត្តកើតឡើងប្រកបនឹងឧទ្ធច្ចកុក្កុច្ចធ្វើចិត្តឲ្យសៅហ្មងរលត់ទៅហើយ កុសលចិត្តក៏កើតឡើងប្រកបនឹងសតិបញ្ញាដឹងពីអារម្មណ៍សៅហ្មង ដែលរលត់ទៅនោះបានយ៉ាងណា បើថាអកុសលចេតសិកមិនប្រកបនឹងកុសលចិត្តផង? ចម្លើយៈ ថ្វីបើអកុសលចេតសិកកើតរួមតែអកុសលចិត្ត មិនកើតរួមកុសលចិត្តក៏ពិតមែន តែសញ្ញាចេតសិកដែលសម្គាល់ចងចាំអារម្មណ៍អាចកើតរួមជាមួយអកុសលចិត្ត និងកុសលចិត្តគ្រប់ខណចិត្ត ដូច្នេះបានជាអកុសលចិត្តដែលមានអារម្មណ៍សៅហ្មងរលត់ទៅហើយ សតិ និងបញ្ញារួមកុសលចិត្តកើតតាមក្រោយបន្តដឹងអារម្មណ៍ដែលសៅហ្មងនោះមកចម្រើនសតិប្បដ្ឋាន។ បុគ្គលដែលយកទឹកចាក់ពន្លត់ភ្នក់ភ្លើងឲ្យរលត់អស់កម្ដៅភ្លាមៗយ៉ាងណា បុគ្គលដែលមានសតិប្បដ្ឋានវិបស្សនា ក៏រមែងរម្លត់នូវសេចក្ដីទុក្ខទោមនស្សភ្លាមៗយ៉ាងដូច្នោះ៕

ការរៀនសូត្រចេះចាំបរិយត្តិ បានត្រឹមចិន្តាមយបញ្ញា ក្នុងសម័យអាយុកប្បក្ខយចុះបែបនេះ មនុស្សបច្ចុប្បន្នចម្រើនដោយរាគ ព្រោះវត្ថុកាមសម្បូរបែបជាហេតុញ៉ាំងកិលេសឲ្យរឹងត្អឹង មានតែការព្យាយាមសិក្សាយល់ដឹងអំពីបរមត្ថធម៌ បដិច្ចសមុប្បាទធម៌ ចតុរារិយសច្ចធម៌ បន្តបដិបត្តិសមថវិបស្សនាកម្មដ្ឋានរហូតមានសតិប្បដ្ឋានកើតឡើងកំណត់ដឹងផោដ្ឋព្វ វេទនា ចិត្ត ធម្មាទាន់ពេលមិនយឺតយូរ។ ឧទាហរណ៍: បុគ្គលដែលមានសតិប្បដ្ឋានវិបស្សនា ពេលមានចិត្តក្រោធកើតឡើង សតិក៏កើតឡើងទាន់ពេលដឹងចិត្តប្រកបដោយទោស សតិជាឧបការដល់បញ្ញាកើតឡើងពិចារណាហេតុប្បច្ចយឃើញទោសរបស់ទោស អប់រំចិត្តលះបង់ឧបាទានរម្ងត់បដិឃភ្លាមៗ ប្រៀបដូចបុគ្គលដែលឃើញភ្នក់ភ្លើងកំពុងឆេះ ក៏យកទឹកចាក់ពន្លត់ភ្លើងឲ្យរលត់អស់កម្តៅភ្លាមៗយ៉ាងដូច្នោះ។ បុគ្គលមិនមានសតិប្បដ្ឋាន ទោះចេះចាំបរិយត្តិយ៉ាងណាក៏ដោយ តែនៅពេលមានចិត្តក្រោធកើតឡើង មិនមានសតិកើតឡើងទាន់ពេលដឹងចិត្តប្រកបដោយទោស បញ្ញាអប់រំចិត្តរម្ងត់បដិឃភ្លាមៗបានឡើយ ប្រៀបដូចបុគ្គលម្នាក់ឃើញភ្នក់ភ្លើងកំពុងឆេះ ក៏បណ្តោយឲ្យភ្លើងឆេះដល់រលត់ទៅឯងៗរហូតអស់កម្តៅយ៉ាងដូច្នោះ។

**+អានិសង្សនៃការចម្រើនសតិប្បដ្ឋាន:**

ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងអានិសង្សនៃការចម្រើនសតិបដ្ឋានជានិគមវចន ថាបុគ្គលចម្រើនសតិប្បដ្ឋានអស់រយៈពេល ៧ឆ្នាំ ៦ឆ្នាំ ៥ឆ្នាំ ៤ឆ្នាំ ៣ឆ្នាំ ២ឆ្នាំ ១ឆ្នាំ។ អស់រយៈពេល ៧ខែ ៦ខែ ៥ខែ ៤ខែ ៣ខែ ២ខែ ១ខែ អស់រយៈពេលកន្លះខែ ឬអស់រយៈពេល ៧ ថ្ងៃ គង់នឹងបានសម្រេចផលណាមួយ បណ្តាផលទាំង ២ យ៉ាងគឺ: អរហត្តផលក្នុងបច្ចុប្បន្ន(សម័យពុទ្ធកាល) ឬបើមានឧបាទានសល់នៅក៏នឹងបានជាព្រះអនាគាមី។ ហើយទ្រង់ត្រាស់សរុបថា៖ ផ្លូវនេះជាផ្លូវមូលតែមួយប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ដើម្បីកំចាត់បង់នូវសេចក្តីសោក និងសេចក្តីខ្សឹកខ្សួល ដើម្បីរម្ងត់ទុក្ខ និងទោមនស្ស ដើម្បីសម្រេចនូវញេយ្យធម៌(អរិយមគ្គ) ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន។ ផ្លូវនោះ គឺសតិបដ្ឋាន ៤ ប្រការ តថាគតអាស្រ័យផ្លូវនេះឯង ទើបពណ៌នាដូចពោលមកនេះ។ កាលព្រះសម្មាសម្ពុទ្ធត្រាស់សម្តែងចប់ហើយ ភិក្ខុទាំងនោះក៏មានចិត្តត្រេកអរ រីករាយ ចំពោះពុទ្ធភាសិតនេះក្រៃពេក៕

+**សម្មប្បធាន** គឺជាធម៌តាំងសេចក្តីព្យាយាមដោយប្រពៃ **មាន ៤ គឺ**:

១-សំវរប្បធាន: ព្យាយាមញ៉ាំងអកុសលធម៌ដែលមិនទាន់កើតកុំឲ្យកើតឡើង។

២-បហានប្បធាន: ព្យាយាមលះអកុសលធម៌ដែលកើតឡើងហើយ។

៣-ភាវនាបធាន: ព្យាយាមញ៉ាំងកុសលធម៌ឲ្យកើតឡើង។

៤-អនុរក្ខនាបធាន: ព្យាយាមរក្សាកុសលធម៌ដែលកើតឡើងហើយឲ្យរឹតតែថ្កូវផង់។

+**ឥទ្ធិបាទ** គឺគុណធម៌ញ៉ាំងបំណងឲ្យសម្រេច **មាន ៤ គឺ**:

១-ឆន្ទិទ្ធិបាទ: ធ្វើបំណងឲ្យសម្រេចដោយសេចក្តីពេញចិត្ត។

២-វីរិយិទ្ធិបាទ: ធ្វើបំណងឲ្យសម្រេចដោយសេចក្តីព្យាយាម។

៣-ចិត្តិទ្ធិបាទ: ធ្វើបំណងឲ្យសម្រេចដោយសេចក្តីយកចិត្តទុកដាក់។

៤-វីមំសិទ្ធិបាទ: ធ្វើបំណងឲ្យសម្រេចដោយឧស្សាហ៍ចារណា។

+**ឥន្ទ្រិយ** គឺធម៌ដែលជាធំសម្រាប់គ្រប់គ្រងកុសលធម៌ទាំងពួង **មាន ៥ គឺ**:

១-សទ្ធិន្ទ្រិយ: សទ្ធាជាធំដែលជឿជ្រះថ្លាចំពោះការត្រាស់ដឹងរបស់ព្រះពុទ្ធ។ ឥន្ទ្រិយជាធំអាចគ្របសង្កត់អស្សទ្ធិយ(មិនមានសទ្ធា គឺការមិនជឿ)។

២-វីរិយិន្ទ្រិយ: វីរិយជាធំដែលព្យាយាមតស៊ូបំពេញសម្មប្បធាន ៤។ ឥន្ទ្រិយជាធំអាចគ្របសង្កត់កោសជ្ជ(ភាពខ្ជិលច្រអូស)។

៣-សតិន្ទ្រិយ: សតិជាធំដែលប្រមូលអារម្មណ៍ទៅលើសតិប្បដ្ឋាន ៤។ ឥន្ទ្រិយជាធំអាចគ្របសង្កត់បមាទ(ការធ្វេសប្រហែស)។

៤-សមាធិន្ទ្រិយ: សមាធិជាធំដែលសម្រេចចតុត្ថជ្ឈាន។ ឥន្ទ្រិយជាធំអាចគ្របសង្កត់វិក្ខេប(ចិត្តរាយមាយ)។

៥-បញ្ញិន្ទ្រិយ: បញ្ញាជាធំដែលយល់ដឹងអំពីចតុរារិយសច្ច។ ឥន្ទ្រិយជាធំអាចគ្របសង្កត់សម្មោហ(ការវង្វេង)។

+**ពល** គឺជាធម៌ដែលមានកម្លាំងគ្របសង្កត់នូវកិលេស **មាន ៥ គឺ**:

១-សទ្ធាពល: កម្លាំងសទ្ធាដែលជឿជ្រះថ្លាចំពោះការត្រាស់ដឹងរបស់ព្រះពុទ្ធ។

២-វិរិយពល: កម្លាំងវិរិយដែលព្យាយាមតស៊ូបំពេញសម្មប្បធាន ៤។

៣-សតិពល: កម្លាំងសតិដែលប្រមូលអារម្មណ៍ទៅលើសតិប្បដ្ឋាន ៤។

៤-សមាធិពល: កម្លាំងសមាធិដែលសម្រេចចតុត្ថជ្ឈាន។

៥-បញ្ញាពល: កម្លាំងបញ្ញាដែលយល់ដឹងអំពីចតុរារិយសច្ច។

+**ពោជ្ឈង្គ** គឺធម៌ជាអង្គរបស់សេចក្តីត្រាស់ដឹង **មាន ៧ គឺ**:

១-សតិសម្ពោជ្ឈង្គ: សតិជាអង្គនៃធម៌នាំទៅរកការត្រាស់ដឹង។

២-ធម្មវិចយសម្ពោជ្ឈង្គ: ធម្មវិចយ(ការពិចារណាធម៌ បានដល់វិបស្សនាបញ្ញា)ជាអង្គនៃធម៌នាំទៅរកការត្រាស់ដឹង។

៣-វិរិយសម្ពោជ្ឈង្គ: វិរិយជាអង្គនៃធម៌នាំទៅរកការត្រាស់ដឹង។

៤-បីតិសម្ពោជ្ឈង្គ: ផរណាបីតិជាអង្គនៃធម៌នាំទៅរកការត្រាស់ដឹង។

៥-បស្សទ្ធិសម្ពោជ្ឈង្គ: បស្សទ្ធិជាអង្គនៃធម៌នាំទៅរកការត្រាស់ដឹង។

៦-សមាធិសម្ពោជ្ឈង្គ: សមាធិជាអង្គនៃធម៌នាំទៅរកការត្រាស់ដឹង។

៧-ឧបេក្ខាសម្ពោជ្ឈង្គ: គឺតត្រមជ្ឈត្តុបេក្ខាជាអង្គនៃធម៌នាំទៅរកការត្រាស់ដឹង។

+**អរិយអដ្ឋង្គិកមគ្គ** គឺជាផ្លូវដ៏ប្រសើរដែលជាហេតុនៃការសម្លាប់កិលេស និងចូលដល់ព្រះនិព្វាន **មានអង្គ ៨** (មើលទំព័រ ៥២)។

*__អាហាររបស់វិជ្ជា និងវិមុត្តិ__:

១-វិជ្ជា និងវិមុត្តិ: មានពោជ្ឈង្គ ៧ ជាអាហារ។

២-ពោជ្ឈង្គ ៧: មានសតិប្បដ្ឋាន ៤ ជាអាហារ។

៣-សតិប្បដ្ឋាន ៤: មានសុចរិត ៣ ជាអាហារ។

៤-សុចរិត ៣: មានការសង្រួមឥន្ទ្រិយជាអាហារ។

៥-ការសង្រួមឥន្ទ្រិយ: មានសតិ(សេចក្ដីរឭក)សម្បជញ្ញ(សេចក្ដីដឹងខ្លួន)ជាអាហារ។

៦-សតិសម្បជញ្ញៈ មានយោនិសោមនសិការជាអាហារ។

៧-យោនិសោមនសិការ: មានសទ្ធាជាអាហារ។

៨-សទ្ធា: មានសទ្ធម្មស្សវន(ការស្ដាប់ព្រះសទ្ធម្ម)។

៩-សទ្ធម្មស្សវនៈ មានសប្បុរិសសំសេវ(ការសេពគប់សប្បុរស)ជាអាហារ។

*អាហាររបស់អវិជ្ជា:

១-អវិជ្ជា: មាននីវរណធម៌ ៥ ជាអាហារ។

២-នីវរណធម៌ ៥: មានទុច្ចរិត ៣ ជាអាហារ។

៣-ទុច្ចរិត ៣: មានការមិនសង្រួមឥន្ទ្រិយជាអាហារ។

៤-ការមិនសង្រួមឥន្ទ្រិយ: មានការមិនមានសតិសម្បជញ្ញជាអាហារ។

៥-ការមិនមានសតិសម្បជញ្ញៈ មានអយោនិសោមនសិការជាអាហារ។

៦-អយោនិសោមនសិការ: មានអស្សទ្ធិយ(ការមិនមានសទ្ធា)ជាអាហារ។

៧-អស្សទ្ធិយ: មានអស្សទ្ធម្មស្សវនជាអាហារ។

៨-អស្សទ្ធម្មស្សវនៈ មានអសប្បុរិសសំសេវជាអាហារ។

*អាហាររបស់នីវរណធម៌:

១-ការធ្វើនូវអយោនិសោមនសិការឲ្យច្រើនក្នុងសុភនិមិត្តនោះ នេះធម៌ជាអាហាររបស់កាមច្ឆន្ទដែលមិនទាន់កើតឲ្យកើតឡើង ឬរបស់កាមច្ឆន្ទដែលកើតហើយឲ្យរឹងរឹតតែកើតច្រើនឡើង។

២-ការធ្វើនូវអយោនិសោមនសិការឲ្យច្រើនក្នុងបដិឃនិមិត្តនោះ នេះធម៌ជាអាហាររបស់ព្យាបាទដែលមិនទាន់កើតឲ្យកើតឡើង ឬរបស់ព្យាបាទដែលកើតហើយឲ្យ

រឹងរឹតតែកើតច្រើនឡើង។

៣-ការធ្វើនូវអយោនិសោមនសិការឲ្យច្រើនក្នុងសេចក្ដីធុញទ្រាន់ ខ្ជិល មិនពត់កាយពុលបាយ រួញរាចិត្តនោះ នេះធមិជាអាហាររបស់ថីនមិទ្ធដែលមិនទាន់កើតឲ្យកើតឡើង ឬរបស់ថីនមិទ្ធដែលកើតហើយឲ្យរឹងរឹតតែកើតច្រើនឡើង។

៤-ការធ្វើនូវអយោនិសោមនសិការឲ្យច្រើនក្នុងការមិនស្ងប់ចិត្តនោះ នេះធមិជាអាហាររបស់ឧទ្ធច្ចកុក្កុច្ចដែលមិនទាន់កើតឲ្យកើតឡើង ឬរបស់ឧទ្ធច្ចកុក្កុច្ចដែលកើតហើយឲ្យរឹងរឹតតែកើតច្រើនឡើង។

៥-ការធ្វើនូវអយោនិសោមនសិការឲ្យច្រើនក្នុងសេចក្ដីសង្ស័យក្នុងធមិ ៨ យ៉ាង(មានសម្ដែងក្នុងវិចិកិច្ឆាចេតសិក)នោះ នេះធមិជាអាហាររបស់វិចិកិច្ឆាដែលមិនទាន់កើតឲ្យកើតឡើង ឬរបស់វិចិកិច្ឆាដែលកើតហើយឲ្យរឹងរឹតតែកើតច្រើនឡើង។

*__នីវរណប្បហាន__(ធមិជាគ្រឿងលះនីវរណ):

១-កាមច្ឆន្ទ: លះកាមច្ឆន្ទដោយធ្វើយោនិសោមនសិការក្នុងអសុភនិមិត្ត។ ម្យ៉ាងទៀត លះដោយធមិ ៦ ប្រការគឺ:

-អសុភនិមិត្តស្ស ឧគ្គហោ: ការកាន់យកអសុភនិមិត្តជាអារម្មណ៍។

-អសុភភាវនានុយោគោ: ការប្រកបរឿយៗនូវអសុភភាវនា។

-ឥន្ទ្រិយេសុ គុត្តទ្វារតា: ការរក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ។

-ភោជនេ មត្តញ្ញុតា: សេចក្ដីស្គាល់ប្រមាណក្នុងភោជន។

-កល្យាណមិត្តា: សេពគប់កល្យាណមិត្តដែលជាអ្នកត្រេកអរក្នុងការចម្រើនអសុភ។

-សប្បាយកថា: និយាយតែរឿងដែលជាទីសប្បាយ(រឿងអសុភក្នុងឥរិយាបថ ៤)។

២-ព្យាបាទ: លះព្យាបាទដោយធ្វើយោនិសោមនសិការក្នុងមេត្តាចេតោវិមុត្តិ។ ម្យ៉ាងទៀត លះដោយធមិ ៦ ប្រការគឺ:

-មេត្តានិមិត្តស្ស ឧគ្គហោ: ការកំណត់និមិត្តក្នុងមេត្តាជាអារម្មណ៍។

-មេត្តាភាវនានុយោគោ: ការប្រកបរឿយៗនូវមេត្តាភាវនា។

-កម្មស្សកតាបច្ចវេក្ខណា: ការពិចារណាដល់សត្វមានកម្មជារបស់ខ្លួន។

-បដិសង្ខានពហុលតា: ការធ្វើឲ្យច្រើននូវការពិចារណា។

-កល្យាណមិត្តតា: សេពគប់កល្យាណមិត្តដែលជាអ្នកត្រេកអរក្នុងការចម្រើនមេត្តា។

-សប្បាយកថា: និយាយតែរឿងដែលជាទីសប្បាយ(រឿងមេត្តាក្នុងឥរិយាបថ ៤)។

៣-ថីនមិទ្ធ: លះថីនមិទ្ធដោយធ្វើយោនិសោមនសិការក្នុងសេចក្ដីព្យាយាម ៣ យ៉ាង គឺអារព្ភធាតុ(សេចក្ដីព្យាយាមផ្ដើមដំបូង) និក្កមធាតុ(សេចក្ដីព្យាយាមដែលមានកម្លាំងជាងអារព្ភធាតុ ព្រោះចេញទៅផុតពីសេចក្ដីខ្ជិលច្រអូស) បរក្កមធាតុ(សេចក្ដីព្យាយាមដែលមានកម្លាំងក្រៃលែងជាងនិក្កមធាតុ ព្រោះកន្លងឋានៈដទៃៗ)។ ម្យ៉ាងទៀត លះដោយធម៌ ៦ ប្រការគឺ:

-អតិភោជនេ និមិត្តគ្គាហោ: ការកំណត់សម្គាល់ក្នុងភោជនដែលលើស។

-ឥរិយាបថសម្បរិវត្តនតា: ការផ្លាស់ប្ដូរឥរិយាបថដែលកើតថីនមិទ្ធនោះចេញ។

-អាលោកសញ្ញាមនសិការោ: ការធ្វើទុកក្នុងចិត្តដល់អាលោកសញ្ញា គឺការសម្គាល់ថាភ្លឺ។

-អព្ភោកាសវាសោ: ការនៅកណ្ដាលវាល។

-កល្យាណមិត្តតា: សេពគប់កល្យាណមិត្តដែលជាអ្នកលះថីនមិទ្ធបាន។

-សប្បាយកថា: និយាយតែរឿងដែលជាទីសប្បាយ(រឿងធុតង្គក្នុងឥរិយាបថ ៤)។

៤-ឧទ្ធច្ចកុក្កុច្ច: លះឧទ្ធច្ចកុក្កុច្ចដោយធ្វើយោនិសោមនសិការក្នុងសេចក្ដីស្ងប់នៃចិត្ត គឺសមាធិ។ ម្យ៉ាងទៀត លះដោយធម៌ ៦ ប្រការគឺ:

-ពហុស្សុតតា: ការស្ដាប់(រៀន)ច្រើន។

-បរិបុច្ឆកតា: ការសាកសួរច្រើននូវវត្ថុដែលគួរ និងមិនគួរ។

-វិនយេបកតញ្ញុតា: មានភាពជំនាញក្នុងវិន័យ។

-វុឌ្ឍសេវិតា: ការគប់រកបុគ្គលដែលចម្រើន។

-កល្យាណមិត្តតា: សេពគប់កល្យាណមិត្តដែលជាអ្នកទ្រទ្រង់វិន័យ។

-សប្បាយកថា: និយាយតែរឿងដែលជាទីសប្បាយ(រឿងវត្ថុដែលគួរ និងមិនគួរក្នុងឥរិយាបថ ៤)។

៥-វិចិកិច្ឆា: លះវិចិកិច្ឆាដោយធ្វើយោនិសោមនសិការក្នុងធម៌ជាកុសល អកុសល ធម៌ដែលមានទោស មិនមានទោស ធម៌ដែលគួរសេព មិនគួរសេព ធម៌ដែលថោកទាប ប្រណីត ធម៌ដែលប្រៀបដោយរបស់ខ្មៅ ស។ ម្យ៉ាងទៀត លះដោយធម៌ ៦ ប្រការគឺ:

-ពហុស្សុតតា: ការស្តាប់(រៀន)ច្រើន។

-បរិបុច្ឆកតា: ការសាកសួរច្រើនដែលប្រារព្ធនូវព្រះរតនត្រៃ។

-វិនយេបកតញ្ញុតា: មានភាពជំនាញក្នុងវិន័យ។

-អធិមោក្ខពហុលតា: ការច្រើនដោយការបង្អោនចិត្តជឿ។

-កល្យាណមិត្តតា: សេពគប់កល្យាណមិត្តដែលជាអ្នកបង្អោនចិត្តទៅក្នុងសទ្ធា។

-សប្បាយកថា: និយាយតែរឿងដែលជាទីសប្បាយ(រឿងគុណរបស់ព្រះរតនត្រៃក្នុងឥរិយាបថ ៤)។

***បីតិ ៥ យ៉ាង**:

បីតិ កើតឡើងខណចិត្តស្ងប់ក្នុងកម្មដ្ឋានរម្ងាប់កាយសង្ខារ, សេចក្តីជ្រះថ្លារំភើបក្នុងកុសលធម៌ឆ្អែតចិត្ត, ចិត្តស្ងប់ពិចារណាធម៌ឃើញតាមសេចក្តីពិត។

-ខុទ្ទកាបីតិ: សេចក្តីជ្រះថ្លារំភើបឆ្អែតចិត្តព្រឺព្រួចកាយរោលស្បែកតិចតួច។

-ខណិកាបីតិ: សេចក្តីជ្រះថ្លារំភើបឆ្អែតចិត្តព្រឺព្រួចកាយខ្វាកមួយខណ:។

-ឱក្កន្តិកាបីតិ: សេចក្តីជ្រះថ្លារំភើបឆ្អែតចិត្តព្រឺព្រួចកាយខ្វាកៗ ២-៣-៤ ខណ:។

-ឧព្វេង្គាបីតិ: សេចក្តីជ្រះថ្លារំភើបឆ្អែតចិត្តព្រឺព្រួចកាយខ្វាកៗស្រាលខ្លួនផើតៗ បើ

បីតិនេះមានកម្លាំងខ្លាំងអាចញ៉ាំងកាយឲ្យអណ្តែតឡើងឰដ៏អាកាសបាន។

-ផរណាបីតិៈ សេចក្តីជ្រះថ្លារំភើបឆ្អែតចិត្តព្រឺព្រួចកាយខ្លាកៗ ធ្ងន់រឹងខ្លួនត្រជាក់សព្វសព៌ាង្គកាយ ផរណាបីតិនេះទើបរាប់ជាអង្គឈាន។

## -និមិត្តក្នុងសមាធិ:

១-និមិត្តក្នុងមិច្ឆាសមាធិៈ ការចម្រើនសមាធិដែលពុំប្រកបដោយសតិគ្រប់គ្រងចិត្តកុំឲ្យរវើរវាយ និងមិនមានបញ្ញាឃើញទោសរបស់ឆន្ទរាគ ក៏ប្រព្រឹត្តទៅតាមអំណាចរបស់កិលេសដែលចង់ឃើញអ្វីមួយ ឬចង់បានឫទ្ធិ ក៏ព្យាយាមប្រមូលអារម្មណ៍ធ្វើចិត្តឲ្យស្ងប់មូលនឹកចំពោះបំណងនោះ រហូតចិត្តស្ងប់ស្លុងក្នុងអារម្មណ៍យូរៗទៅ ជួនក៏ឃើញនិមិត្តតាមចិត្តដែលវង្វេង ជួនកាលអមនុស្សឲ្យនិមិត្តក៏មាន។

២-និមិត្តក្នុងកសិណភាវនាៈ បើចម្រើនលោហិតកសិណ គឺយកពណ៌ក្រហមធ្វើជាអារម្មណ៍របស់កម្មដ្ឋាន ត្រូវប្រមូលអារម្មណ៍ធ្វើចិត្តឲ្យស្ងប់មូលប្រកបដោយសតិ(ចិត្តចងជាប់នឹងកសិណ) និងញាណ(សម្គាល់លក្ខណនៃកសិណទុកក្នុងចិត្ត)នឹកសម្លឹងកសិណពណ៌ក្រហម សឹមបរិកម្មថា "ក្រហមៗ" រហូតចិត្តកំណត់អារម្មណ៍ទុកដោយប្រពៃ ហៅថាបរិកម្មនិមិត្ត។ ក្រោយពីចិត្តកំណត់អារម្មណ៍ទុកដោយប្រពៃយូរៗទៅ សតិក៏លះបង់បរិកម្មចោលតាំងស្ងប់នឹកសម្លឹងបរិកម្មនិមិត្ត ដែលជាអារម្មណ៍នៅត្រង់ថ្ងាសលើចន្លោះចិញ្ចើម រហូតវត្ថុធម៌ប្រាកដក្នុងមនោទ្វារឃើញដូចមើលដោយភ្នែក ហៅថា ឧគ្គហនិមិត្ត កាលមានឧគ្គហនិមិត្តហើយ ត្រូវនឹកសម្លឹងឧគ្គហនិមិត្តដែលជាអារម្មណ៍នៅត្រង់ថ្ងាសលើចន្លោះចិញ្ចើម រហូតបដិភាគនិមិត្តកើតឡើងមានលក្ខណប្រណិតខុសសភាពដើម។ កម្មដ្ឋានណាក្តីតែងកើតមាននិមិត្ត និមិត្តកើតឡើងតាមហេតុប្បច្ច័យ ដែលយោគាវចរធ្លាប់បានធ្វើអារម្មណ៍ទុកក្នុងចិត្ត ជួនឃើញជាអសុភនិមិត្ត៕

## *ត្រៃលក្ខណធម៌:

១-អនិច្ចលក្ខណៈ ការសម្គាល់ថារូបកើតរលត់មិនទៀង ប្រែប្រួលពីក្មេងទៅចាស់ ឈឺ ស្លាប់។ វេទនាកើតរលត់មិនទៀង ប្រែប្រួលម្តងសុខ ម្តងទុក្ខ ម្តងសោមនស្ស ម្តងទោមនស្ស ម្តងឧបេក្ខា, សញ្ញាកើតរលត់មិនទៀង ប្រែប្រួលម្តងចាំបានថានេះថា

នោះ ម្តងនឹកឃើញដោយស្រពេចស្រពិល ម្តងភ្លេចបាត់សូន្យឈឹង, សង្ខារកើតរលត់មិនទៀង ប្រែប្រួលម្តងតាក់តែងចិត្តជាកុសល ម្តងតាក់តែងចិត្តជាអកុសល, វិញ្ញាណកើតរលត់មិនទៀង អាស្រ័យវេទនា សញ្ញា និងសង្ខារប្រែប្រួលយ៉ាងណាក៏ដឹងយ៉ាងនោះ។

២-ទុក្ខលក្ខណៈ ការសម្គាល់ថាសភាវធម៌ណាមានកិរិយាកើតឡើងហើយវិនាសទៅវិញមិនទៀងនោះ ជាទុក្ខ គឺទុក្ខអរិយសច្ច។

៣-អនត្តលក្ខណៈ ការសម្គាស់ថាសភាវធម៌ណាជាទុក្ខ សភាវធម៌នោះជាអនត្តា ព្រោះជាបរមត្ថធម៌ដែលមិនតាំងនៅតាមការចង់បានគ្រប់គ្រងរបស់ខ្លួន៕

## ឈ-វិបស្សនាកម្មដ្ឋានៈ

វិបស្សនាកម្មដ្ឋាន ផ្នែកបញ្ញាវិមុត្តិ គឺរួចស្រឡះកិលេសដោយអំណាចបញ្ញា។ វិបស្សនាៈ ការឃើញច្បាស់សង្ខារធម៌តាមសភាវពិត។ វិបស្សនាកម្មដ្ឋានៈ ការអប់រំចិត្តចម្រើនសតិបញ្ញាឲ្យឃើញច្បាស់សង្ខារធម៌តាមសភាវពិត។ យោគាវចរបដិបត្តិវិបស្សនាកម្មដ្ឋានត្រូវលះបង់ទិដ្ឋិ"មានតួខ្លួនបដិបត្តិវិបស្សនាកម្មដ្ឋាន" ព្រោះការមានទិដ្ឋិបែបនេះពុំមែនជាវិបស្សនា តួវិបស្សនា គឺជាសតិ និងញាណដែលជាបរមត្ថធម៌ធ្វើកិច្ចរបស់ខ្លួនក្នុងកម្មដ្ឋាន។ វិបស្សនាកម្មដ្ឋាន មានអារម្មណ៍ ៧៣ គឺៈ ខន្ធ ៥, អាយតន ១២, ធាតុ ១៨, ឥន្ទ្រិយ ២២, អរិយសច្ច ៤, បដិច្ចសមុប្បាទ ១២។ បុគ្គលចម្រើនវិបស្សនាដែលមានខណិកសមាធិជាគ្រឿងទ្រ ហៅថា សុទ្ធវិបស្សនាយានិក បុគ្គលចម្រើនវិបស្សនាដែលមានឧបចារសមាធិ ឬអប្បនាសមាធិជាគ្រឿងទ្រ ហៅថា សមថយានិក។ ការបដិបត្តិវិបស្សនាកម្មដ្ឋាន គឺដើម្បីបានដល់វិបស្សនាញាណ (បញ្ញាដែលឃើញច្បាស់នាមរូបតាមសភាវពិត) ដែលប្រព្រឹត្តទៅជាអារម្មណ៍ផុតចាកតួខ្លួនជាអនត្តាក្នុងកម្មដ្ឋាន។ ពេលមានឧបចារសមាធិដែលជាចិត្តវិសុទ្ធិជាយានសម្រាប់ចម្រើនរូបកម្មដ្ឋានហើយ សមថយានិកត្រូវចូលឈាន គឺចម្រើនសមាធិរហូតចូលដល់ឧបចារសមាធិហើយ សឹមចេញចាកឈាន(ប្តូរពីអារម្មណ៍សមថមកជាអារម្មណ៍វិបស្សនា)ជ្រើសរើសយករូបណាមួយនៃអាការ ៣២ ដែលងាយនឹងធ្វើអារម្មណ៍ទុកក្នុងចិត្តមកពិចារណាជាបដិកូល។ ឧទាហរណ៍ៈ ជ្រើសរើសយកសក់មកចម្រើនរូបកម្មដ្ឋាន ត្រូវនឹកចំពោះសក់ធ្វើជាអារម្មណ៍ បរិកម្មថា៖"សក់ៗៗ"រហូត

ចិត្តមានសក់ជាបរិកម្មនិមិត្ត ទើបពិចារណាសក់ជារបស់បដិកូល គឺថាពេលសក់នៅជាប់នឹងក្បាលខំថៃសំអាត ស្រឡាញ់ពេញចិត្ត តែបើសក់ជ្រុះពីក្បាលហើយក៏អស់មានសារៈ បើជ្រុះចូលអាហារក៏ខ្ពើមរអើមចំពោះអាហារនោះ បន្ទាប់ទៀតត្រូវពិចារ-ណាថាសក់នេះរមែងដុះហើយជ្រុះ ប្រែប្រួលពីខ្មៅរលើបរលោង ទន់រស់រវើកជាទីសោមនស្ស ទៅជារឹងស្ងួត បែកចុង សស្កូវជាទីទោមនស្ស ត្រូវពិចារណារូបជាបដិកូលជាបរមត្ថធម៌ដែលកើតរលត់ប្រែប្រួលមិនទៀង ជាទុក្ខ មិនមែនរបស់ខ្លួន រហូតមានអារម្មណ៍ខ្ពើមរអើមចំពោះរូបបដិកូលកើតឡើងធ្វើទុកក្នុងចិត្ត ឲ្យចិត្តសេពអារម្មណ៍ឆ្អែតព្រឺព្រួចកាយហៅថាបីតិ(អាហារបំប៉នកុសលចិត្ត) បន្ទាប់ទៀតសមថ-យានិកនឹងមានអសុភនិមិត្តកើតឡើង ហើយត្រូវកាន់យកអសុភនិមិត្តមកពិចារណារហូតបញ្ញាឃើញទោសរបស់រូប ញ៉ាំងចិត្តនឿយណាយចំពោះរូប។ បន្ទាប់ទៀតត្រូវបន្តចម្រើនអរូប(វេទនា)កម្មដ្ឋាន គឺពិចារណាកាលសក់នៅល្អស្អាតក៏សោមនស្សពេលដែលសក់ប្រែប្រួលក៏ទោមនស្ស វេទនារមែងកើតរលត់មិនទៀង ម្តងសុខ ម្តងទុក្ខ ម្តងសោមនស្ស ម្តងទោមនស្ស ម្តងឧបេក្ខា វេទនាកើតឡើងអាស្រ័យអាយតនខាងក្នុងប៉ះខ្ទប់នឹងអាយតនខាងក្រៅ ហើយផស្សកើតឡើងប៉ះខ្ទប់នឹងអារម្មណ៍ កាលបើកុសលវិបាកចិត្តកើតឡើងតាមបញ្ចទ្វារក៏ដឹងឥដ្ឋារម្មណ៍ តែបើអកុសលវិបាកចិត្តកើតឡើងតាមបញ្ចទ្វារក៏ដឹងអនិដ្ឋារម្មណ៍ ការដឹងអារម្មណ៍ទាំងឡាយត្រឹមតែជាវិថីចិត្តប៉ុណ្ណោះ មិនមានតួខ្លួន សត្វ បុគ្គលណាឡើយ ត្រូវពិចារណារហូតបញ្ញាឃើញវេទនាជាបរមត្ថធម៌ដែលកើតរលត់ប្រែប្រួលមិនទៀង ជាទុក្ខ មិនមែនរបស់ខ្លួន ហើយត្រូវបង្អោនចិត្តចូលក្នុងអនត្តាភាវនា(នឹកចំពោះអារម្មណ៍មិនមែនតួខ្លួន) រហូតបីតិកើតឡើងញ៉ាំងចិត្តនឿយណាយចំពោះវេទនា ខណនោះចិត្តរឹតតែសង្វេគចំពោះសង្ខារធម៌ ហើយត្រូវធ្វើត្រៃលក្ខណធម៌ជាអារម្មណ៍ទុកក្នុងចិត្ត។ តទៅទៀតសមថយានិក នឹងមានបញ្ញាឃើញនាមរូបជាសភាវធម៌ពីរដាច់ដោយឡែកពីគ្នាហើយយកលក្ខណនាមរូបដែលដាច់ដោយឡែកពីគ្នាធ្វើជាអារម្មណ៍កម្មដ្ឋាន រហូតនិមិត្តកើតឡើងឃើញប្រចក្សនាមរូបជាសភាវធម៌ពីរតាមសេចក្តីពិត (បុគ្គលណាបានដល់នឹងដឹងដោយខ្លួនឯង) បានដល់វិបស្សនាញាណ៕

*សោឡសញ្ញាណ(វិបស្សនាញាណ ១៦):

១-នាមរូបបរិច្ឆេទញាណ: ញាណឃើញប្រចក្ស(ឃើញច្បាស់)នូវលក្ខណនាមដាច់ដោយឡែកពីរូប ក៏កើតមានសេចក្ដីសង្វេគលះសក្កាយទិដ្ឋិឲ្យស្ដើង។

២-បច្ចយបរិគ្គហញាណ: ញាណឃើញប្រចក្សនាមរូបកើតឡើងដោយអាស្រ័យបច្ចយ។ ក្នុងបដិសន្ធិកាល គឺអវិជ្ជា តណ្ហា ឧបាទាន កម្ម ក្នុងបវត្តិកាល រូបកើតឡើងដោយអំណាចនៃបច្ច័យ គឺកម្ម ចិត្ត ឧតុ និងអាហារ ចំណែកនាមកើតឡើងដោយអំណាចនៃបច្ច័យ មាននិស្សយប្បច្ចយ(អាស្រ័យនូវធម៌ទាំងឡាយមានរូបចិត្តចេតសិកជាគ្រឿងឧបត្ថម្ភគាំទ្រដល់គ្នានិងគ្នា) និងអារម្មណប្បច្ចយ(អារម្មណ៍ជាគ្រឿងឧបត្ថម្ភគាំទ្រ) មានចក្ខុ និងរូបជាដើម ដោយការផ្សេងគ្នា។

៣-សម្មសនញាណ: ញាណឃើញប្រចក្សត្រៃលក្ខណ(មើលទំព័រ ៧៨)នៃនាមរូប។

៤-ឧទយព្វយញាណ: ញាណឃើញប្រចក្សនូវការកើត និងការរលត់នៃនាមរូប។ ការកើតឡើងនៃរូប ព្រោះកើតឡើងនៃអវិជ្ជា តណ្ហា កម្ម អាហារ និព្វត្តិលក្ខណ(ការកើតឡើង) ការរលត់ទៅនៃរូប ព្រោះរលត់ទៅនៃអវិជ្ជា តណ្ហា កម្ម អាហារ វិបរិណាមលក្ខណ(ការប្រែប្រួលទៅ)។ ការកើតឡើងនៃវេទនា សញ្ញា សង្ខារ ព្រោះកើតឡើងនៃអវិជ្ជា តណ្ហា កម្ម ផស្ស និព្វត្តិលក្ខណ ការរលត់ទៅនៃវេទនា សញ្ញា សង្ខារ ព្រោះរលត់ទៅនៃអវិជ្ជា តណ្ហា កម្ម ផស្ស វិបរិណាមលក្ខណ។ ការកើតឡើងនៃវិញ្ញាណ ព្រោះកើតឡើងនៃអវិជ្ជា តណ្ហា កម្ម នាមរូប និព្វត្តិលក្ខណ ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់ទៅនៃអវិជ្ជា តណ្ហា កម្ម នាមរូប វិបរិណាមលក្ខណ ក្នុងញាណនេះកាន់យកការកើត។ វិបស្សនាញាណនេះចែកជា ២ គឺ: តរុណឧទយព្វយញាណ(ឧទយព្វយញាណយ៉ាងទន់ខ្ចី) និងពលវឧទយព្វយញាណ(ឧទយព្វយញាណមានកម្លាំង) ឧបកិលេស ១០ យ៉ាងហៅថា វិបស្សនូបកិលេសគឺ: ឱភាស: ពន្លឺរបស់វិបស្សនា, ញាណ: សេចក្ដីដឹងរបស់វិបស្សនា, បីតិ: បីតិក្នុងវិបស្សនា, បស្សទ្ធិ: សេចក្ដីស្ងប់ក្នុងវិបស្សនា, សុខ: សេចក្ដីសុខក្នុងវិបស្សនា, អធិមោក្ខ: សទ្ធា គឺការជឿស៊ប់, បគ្គាហ: វីរិយ គឺសេចក្ដីព្យាយាមមាំ, ឧបដ្ឋាន: ជាសតិសម្ពោជ្ឈង្គ, ឧបេក្ខា: ជាឧបេក្ខាសម្ពោជ្ឈង្គ, និកន្តិ: សេចក្ដីប្រាថ្នាដ៏ស្ងប់ស្អិតចំពោះធម៌មានឱភាសជាដើមក្នុងវិបស្សនា គឺសេចក្ដីត្រេកអរក្នុងរូបនិមិត្តដែលជាអានិសង្សនៃវិបស្សនាញាណ។

វិបស្សនូបកិលេសនេះកើតមានចំពោះអ្នកមានសេចក្ដីព្យាយាមខ្លាំងក្លាប៉ុណ្ណោះ មិនកើតមានដល់ព្រះអរិយបុគ្គលអ្នកដល់បដិវេធហើយ ១ យោគីអ្នកបដិបត្តិខុសផ្លូវវិបស្សនា ១ យោគីអ្នកខ្ជិលច្រអូសលះបង់កម្មដ្ឋាន ១។ ឧបកិលេសនេះ មិនមែនជាមគ្គ ព្រោះជាទីតាំងនៃតណ្ហា មានះ ទិដ្ឋិ កើតត្រង់តរុណឧទយព្វយញាណ ហើយជម្រះចិត្តឲ្យផុតចាកគាហ(សេចក្ដីប្រកាន់)ទាំង ៣ គឺ: សេចក្ដីប្រកាន់មាំដោយតណ្ហា មានះ ទិដ្ឋិក្នុងឧបកិលេសដោយពលវឧទយព្វយញាណ៕

៥-ភង្គញាណ: ញាណឃើញប្រចក្សសង្ខារធម៌រលត់ទៅ សូន្យទៅមិនមានសារៈ ហើយលះសេចក្ដីពេញចិត្តចំពោះនាមរូប។ ក្នុងញាណនេះកាន់យកការរលត់៕

៦-ភយញាណ: ញាណឃើញភ័យ(កើតមានអារម្មណ៍ភ័យ)ក្នុងនាមរូបដែលជាទុក្ខ ព្រោះឃើញប្រចក្សថា បើជាតិនៅមាន កំណើតជានរកក៏នៅមាន។

៧-អាទីនវញាណ: ញាណឃើញប្រចក្សទោសរបស់នាមរូបដែលជាទុក្ខ។

៨-និព្វិទាញាណ: ញាណនឿយណាយចំពោះនាមរូបដែលជាទុក្ខ។

៩-មុញ្ចិតុកម្យតាញាណ: ញាណប្រាថ្នាចាកចេញពីនាមរូបដែលជាទុក្ខ។

១០-បដិសង្ខារញាណ: ញាណប្រាថ្នាលះបង់ចោលនាមរូបដែលជាទុក្ខ។

១១-សង្ខារុបេក្ខាញាណ: ញាណព្រងើយចំពោះនាមរូប(អារម្មណ៍ស្ងប់ព្រងើយទៅៗចំពោះសង្ខារធម៌)។

១២-អនុលោមញាណ: ជាមហាកុសលញាណសម្បយុត្តចិត្ត ៣ ខណក្នុងមគ្គវិថី គឺ បរិកម្ម(តាក់តែងមគ្គឲ្យកើត) ១ ខណ, ឧបចារ(គ្រាច់ទៅជិតមគ្គ) ១ ខណ, អនុលោម(គាំទ្រដល់សច្ចទាំងខាងដើម និងខាងចុង) ១ ខណ។ វិបស្សនាញាណនេះអនុ-លោមតាមលំដាប់ពីឧទយព្វយញាណដល់អនុលោមញាណ រហូតដឹងច្បាស់អរិយ-សច្ចធម៌។ ពេលញាណឡើងកាន់មគ្គវិថីមានត្រៃលក្ខណធម៌ណាមួយជាអារម្មណ៍ ពិចារណាទោសរបស់លោភ ទោស និងមោហដែលជាទុក្ខ ហើយអនុលោមបន្តរហូតញាណលះបង់អារម្មណ៍ដែលជាសង្ខារធម៌នោះចោល៕

១៣-គោត្រភូញាណ: កាលអនុលោមញាណរលត់ទៅ គោត្រភូញាណក៏កើតឡើង

បង្អោនទៅមាននិព្វានជាអារម្មណ៍(ស្ងប់សុខត្រជាក់ទៅៗ)ខណៈដំបូង ជាអាសេវនប្បច្ច័យ(ធម៌ដែលជួយឧបការដោយភាវសេពញយៗ)នៃសោតាបត្តិមគ្គចិត្ត។

១៤-មគ្គញាណ: លោកុត្តរចិត្តកើតឡើងបន្តមាននិព្វានជាអារម្មណ៍លះសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសជាសមុច្ឆេទ ក៏ឆ្លងផុតភាពជាបុថុជ្ជនបានដល់ភាពជាព្រះអរិយបុគ្គលថ្នាក់សោតាបន្ន។

១៥-ផលញាណ: លោកុត្តរវិបាកចិត្តកើតឡើងបន្តមាននិព្វានជាអារម្មណ៍ធ្វើជវនកិច្ចហើយឃើញប្រចក្សអំពីព្រះនិព្វានដោយលោកុត្តរបញ្ញា។

១៦-បច្ចវេក្ខណញ្ញាណ: ញាណពិចារណាសភាវធម៌ដែលទើបនឹងឃើញប្រចក្សវារៈនីមួយៗ មានមគ្គចិត្ត វារៈ ១, ផលចិត្ត វារៈ ១, កិលេសបានលះរួច វារៈ ១, កិលេសនៅសល់ វារៈ ១, និព្វាន វារៈ ១៕

*វិសុទ្ធិទាំង ៧ គឺ:

១-សីលវិសុទ្ធិ: សេចក្តីបរិសុទ្ធិនៃសីល បានដល់សីល ៤ យ៉ាងរបស់ភិក្ខុ និងសូម្បីសីល ៥, សីល ៨, សីល ១០, ដែលបុគ្គលបានរក្សាដុសខាត់ស្អាតល្អហើយ ។

២-ចិត្តវិសុទ្ធិ: សេចក្តីបរិសុទ្ធិនៃចិត្ត បានដល់ឧបចារសមាធិ និងអប្បនាសមាធិ។

៣-ទិដ្ឋិវិសុទ្ធិ: សេចក្តីបរិសុទ្ធិនៃការឃើញ ជាញាណដែលកំណត់ដឹងរូបធម៌នាមធម៌បច្ចត្តលក្ខណ(ដឹងលក្ខណចំពោះខ្លួន គឺបឋវី មានលក្ខណរឹង, អាបោ មានលក្ខណជ្រាប, តេជោ មានលក្ខណក្តៅ ឬត្រជាក់, វាយោ មានលក្ខណតឹង កម្រើក ញ័រជាដើម) ចាត់ជានាមរូបបរិច្ឆេទញាណដែលជម្រះចិត្តឲ្យប្រាសចាកសក្កាយទិដ្ឋិ។

៤-កង្ខាវិតរណវិសុទ្ធិ: សេចក្តីបរិសុទ្ធិនៃការឃើញកន្លងសេចក្តីសង្ស័យ ៨ យ៉ាង (សម្តែងក្នុងវិចិកិច្ឆាចេតសិក មើលទំព័រ ៨) ញាណដែលកំណត់ដឹងហេតុនៃនាមរូបបច្ច័យឲ្យកើតនាមរូប ក្នុងបដិសន្ធិកាល បានដល់អវិជ្ជា តណ្ហា ឧបាទាន កម្ម ចាត់ជាបច្ចយបរិគ្គហញាណ(មើលទំព័រ ៧៧)។

៥-មគ្គាមគ្គញាណទស្សនវិសុទ្ធិ: សេចក្តីបរិសុទ្ធិនៃការឃើញថានេះជាមគ្គបដិបទានេះពុំមែនជាមគ្គបដិបទា ចាត់ជាសម្មសនញាណ និងឧទយព្វយញាណ។

៦-បដិបទាញាណទស្សនវិសុទ្ធិ: សេចក្តីបរិសុទ្ធិនៃការឃើញថាជាដំណើរទៅកាន់មគ្គបដិបទា ចាត់ជាវិបស្សនាញាណគឺ: ពលវឧទយព្វយញាណ, ភង្គញាណ, ភយ-ញាណ, អាទីនវញាណ, និព្វិទាញាណ, មុញ្ចិតុកម្យតាញាណ, បដិសង្ខារញាណ, សង្ខារុបេក្ខាញាណ, អនុលោមញាណ។ វិបស្សនាញាណទាំង ៩ នេះចាត់ជាបដិបទាញាណទស្សនវិសុទ្ធិ ព្រោះឆ្លងផុតពីវិបស្សនូបកិលេស និងជម្រះចិត្តឲ្យផុតចាកសេចក្តីចាំខុសទាំង ៣ គឺ: និច្ចសញ្ញា, សុខសញ្ញា, អត្តសញ្ញា។

៧-ញាណទស្សនវិសុទ្ធិ: សេចក្តីបរិសុទ្ធិនៃការឃើញអរិយសច្ច ជាលោកុត្តរបញ្ញាក្នុងមគ្គចិត្ត។ កាលអនុលោមញាណ ៣ ខណក្នុងមគ្គវិថីគឺ: បរិកម្ម ឧបចារ អនុលោមរលត់ហើយគោត្រភូញាណក៏កើតឡើង។ គោត្រភូញាណមិនមែនជាបដិបទាញាណទស្សនវិសុទ្ធិ ក៏មិនមែនជាញាណទស្សនវិសុទ្ធិ ព្រោះគោត្រភូញាណមានឋានៈដូចជាអាវជ្ជន(ការប៉ះខ្ទប់)នៃលោកុត្តរចិត្តរវាងបដិបទាញាណទស្សនវិសុទ្ធិ និងញាណ-ទស្សនវិសុទ្ធិ ប៉ុន្តែដែលរាប់ថាជាវិបស្សនាញាណ ព្រោះជាក្រសែនៃវិបស្សនា។ កាលណាគោត្រភូញាណរលត់ហើយ មគ្គចិត្តនឹងកើតជាញាណទស្សនវិសុទ្ធិ៕

*អនុបស្សនា ៧ គឺ:

១-អនិច្ចានុបស្សនា: ពិចារណាឃើញនូវភាពមិនទៀង រដោះចិត្តចាកនិច្ចសញ្ញា។

២-ទុក្ខានុបស្សនា: ពិចារណាឃើញថាជាទុក្ខ រដោះចិត្តចាកសុខសញ្ញា។

៣-អនត្តានុបស្សនា: ពិចារណាឃើញមិនមែនជាតួខ្លួន រដោះចិត្តចាកអត្តសញ្ញា។

៤-និព្វិទានុបស្សនា: ពិចារណាឃើញនូវការនឿយណាយ រដោះចិត្តចាកនន្ទិ(ការត្រេកត្រអាល គឺតណ្ហាប្រកបដោយបីតិ)។

៥-វិរាគានុបស្សនា: ពិចារណាឃើញនូវការប្រាសចាកតម្រេក រដោះចិត្តចាករាគ។

៦-និរោធានុបស្សនា: ពិចារណាឃើញនូវការរលត់ រដោះចិត្តចាកសមុទយ។

៧-បដិនិស្សគ្គានុបស្សនា: ពិចារណាឃើញនូវការរលាស់ចោល រដោះចិត្តចាកអាទាន(ការប្រកាន់មាំ)។

*ញាណ ៣ យ៉ាង:

ញាណ(ប្រាជ្ញាដឹងច្បាស់) ៣ យ៉ាងនេះ ប្រព្រឹត្តទៅក្នុងអរិយសច្ចទាំង ៤ គឺ:

១-សច្ចញាណ: ញាណដឹងសច្ចទាំង ៤ គឺដឹងថានេះទុក្ខ នេះហេតុឲ្យទុក្ខកើត នេះការរលត់ទុក្ខ នេះផ្លូវទៅកាន់ការរលត់ទុក្ខ។

២-កិច្ចញាណ: ញាណដឹងកិច្ចដែលត្រូវធ្វើក្នុងសច្ចទាំង ៤ គឺទុក្ខ មានកិច្ចដែលត្រូវកំណត់ដឹង សមុទយ មានកិច្ចដែលត្រូវលះបង់ និរោធ មានកិច្ចដែលត្រូវធ្វើឲ្យជាក់ច្បាស់ មគ្គ មានកិច្ចដែលត្រូវចម្រើន។

៣-កតញាណ: ញាណដឹងថាបានធ្វើស្រេចហើយក្នុងសច្ចទាំង ៤ គឺទុក្ខ បានកំណត់ដឹងហើយ សមុទយ បានលះបង់ហើយ និរោធ បានធ្វើឲ្យជាក់ច្បាស់ហើយ មគ្គ បានចម្រើនហើយ។

ញាណ ៣ នេះក្នុងអរិយសច្ច ហៅថា ញាណទស្សនវិលជុំទាំង ៣ ហៅថា បរិវដ្ដ គ្រប់សច្ចទាំង ៤ ត្រូវជា ១២ ហៅថាអាការៈ។

*សោឡសកិច្ច:

សោឡសកិច្ច គឺកិច្ច ១៦(ក្នុងកិច្ចញាណ) ដែលបុគ្គលត្រូវធ្វើ ដើម្បីឲ្យចិត្តបានរួចផុតចាកកិលេសដោយធ្វើកិច្ចទាំង ៤ ក្នុងអរិយសច្ចទាំង ៤ គឺ:

១-បរិញ្ញាតព្វកិច្ច: កិច្ចដែលត្រូវកំណត់ដឹងនូវទុក្ខ ដែលជាទុក្ខអរិយសច្ច។

២-បហាតព្វកិច្ច: កិច្ចដែលត្រូវលះបង់នូវតណ្ហា ដែលជាទុក្ខសមុទយអរិយសច្ច។

៣-សច្ឆិកាតព្វកិច្ច: កិច្ចដែលត្រូវធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលជាទុក្ខនិរោធ-អរិយសច្ច។

៤-ភាវេតព្វកិច្ច: កិច្ចត្រូវធ្វើមគ្គឲ្យកើតមានឡើង ឲ្យចម្រើនឡើង ដែលជាទុក្ខនិរោធ-គាមិនីបដិបទាអរិយសច្ច(មគ្គសច្ច)។

កិច្ចទាំង ៤ នេះ ប្រព្រឹត្តទៅក្នុងសោតាបត្តិមគ្គ សកទាគាមិមគ្គ អនាគាមិមគ្គ និងអរហត្តមគ្គ ក្នុងមគ្គនីមួយៗមានធ្វើកិច្ចទាំង ៤ នេះហៅថា សោឡសកិច្ច៕

*បរិញ្ញា ៣ យ៉ាង:

១-ញាតបរិញ្ញា: ការកំណត់ដឹងបាននូវនាមរូប ព្រមដោយបច្ច័យ សម្រេចបានជាបញ្ញាវិសុទ្ធិ ២ ខាងដើម គឺទិដ្ឋិវិសុទ្ធិ និងកង្ខាវិតរណវិសុទ្ធិ ចាក់ធ្លុះនូវបច្ចត្តលក្ខណ។

២-តីរណបរិញ្ញា: ការពិចារណាសង្ខារ ឃើញការកើតឡើង និងការរលត់ទៅវិញ សម្រេចបានជាបញ្ញាវិសុទ្ធិទី ៣ គឺមគ្គាមគ្គញាណទស្សនវិសុទ្ធិ ចាក់ធ្លុះនូវសាមញ្ញលក្ខណ(ត្រៃលក្ខណធម៌)។

៣-បហានបរិញ្ញា: ការពិចារណាសង្ខារ ឃើញការបែកធ្លាយដោយភង្គញ្ញាណជាដើមឡើងទៅ សម្រេចបានជាបញ្ញាវិសុទ្ធិ ២ ខាងចុង គឺបដិបទាញាណទស្សនវិសុទ្ធិ និងញាណទស្សនវិសុទ្ធិចាក់ធ្លុះនិរោធសច្ច មានញាណក្នុងសន្តិបទ(សេចក្តីស្ងប់ គឺព្រះនិព្វាន)រហូតមានព្រះនិព្វានជាអារម្មណ៍លះបង់កិលេសដោយសមុច្ឆេទប្បហាន។

*លោកុត្តរអប្បនាវិថី:

លោកុត្តរអប្បនាវិថី បានដល់វិថីចិត្តដែលជាលោកុត្តរឈាន ជាវិថីចិត្តរបស់ព្រះអរិយបុគ្គលដែលបានឈាន ចំណែកវិថីចិត្តរបស់ព្រះអរិយបុគ្គលដែលមិនបានឈាន ហៅថាលោកុត្តរវិថី។

-ភវង្គចលនៈ ជាវិបាកញាណសម្បយុត្តចិត្ត។

-ភវង្គុបច្ឆេទ: ជាវិបាកញាណសម្បយុត្តចិត្ត។

-មនោទ្វារាវជ្ជនៈ ចិត្តឡើងកាន់វិថីមគ្គ ធ្វើអាវជ្ជនកិច្ចពិចារណាត្រៃលក្ខណធម៌ជាអារម្មណ៍ ជាវិថីទី ១។

-បរិកម្ម ១ ខណៈ ជាមហាកុសលញាណសម្បយុត្តចិត្ត ជាបរិកម្មរបស់មគ្គ គឺតាក់តែងមគ្គឲ្យកើត មានត្រៃលក្ខណធម៌ជាអារម្មណ៍ ជាវិថីទី ២។

-ឧបចារ ១ ខណៈ ជាមហាកុសលញាណសម្បយុត្តចិត្ត គឺត្រាច់ទៅជិតមគ្គ មានត្រៃលក្ខណធម៌ជាអារម្មណ៍ ជាវិថីទី ៣។

-អនុលោម ១ ខណៈ ជាមហាកុសលញាណសម្បយុត្តចិត្ត គឺគាំទ្រដល់សច្ចទាំងខាង

ដើម និងខាងចុង មានត្រៃលក្ខណធម៌ជាអារម្មណ៍ ជាវិថីទី ៤។

-គោត្រភូ ១ ខណៈ ជាមហាកុសលញាណសម្បយុត្តចិត្ត គឺញាណគ្របសង្កត់គោត្រ បុថុជ្ជនឲ្យកើតលោកុត្តរគោត្រ មាននិព្វានជាអារម្មណ៍ខណៈដំបូង ជាវិថីទី ៥។

-មគ្គ ១ ខណៈ ជាលោកុត្តរកុសលចិត្ត កាលគោត្រភូរលត់ហើយ មគ្គចិត្ត ១ ដួងក៏ កើតឡើងដោយតោងយកព្រះនិព្វានជាអារម្មណ៍ ធ្វើកិច្ចក្នុងអរិយសច្ចទាំង ៤ ក្នុង ខណៈជាមួយគ្នា គឺកំណត់ដឹងទុក្ខ លះសមុទយ ធ្វើនិរោធឲ្យជាក់ច្បាស់ ញ៉ាំងមគ្គ ឲ្យកើត ទម្លាយអនុសយកិលេសដែលដេកត្រាំនៅក្នុងខន្ធសន្តានឲ្យអស់ទៅតាម កម្លាំងរបស់ខ្លួន សម្រេចជាព្រះសោតាបន្ន ជាវិថីទី ៦។

-ផល(២ខណៈ ៣ខណៈសម្រាប់បុគ្គលមិនមានបរិកម្ម): ជាលោកុត្តរវិបាកចិត្ត កាល មគ្គចិត្តនោះរលត់ហើយ ផលចិត្តកើតឡើងបន្តមានព្រះនិព្វានជាអារម្មណ៍សោយ លោកុត្តរផលមិនមានចន្លោះខណ្ឌ មានសេចក្ដីស្ងប់សុខត្រជាក់ ជាវិថីទី ៧។

-ភវង្គបាត: ចិត្តផុតវិថី គឺចិត្តប្រព្រឹត្តទៅក្នុងក្រសែនៃភវង្គ។

*បច្ចវេក្ខណវិថី ជាវិថីចិត្តធ្វើការពិចារណា មាន ៣ គឺ:

១-ការពិការណាធម៌របស់កល្យាណបុថុជ្ជន គឺបុគ្គលមានសទ្ធា, សីល(ការសង្រួម កាយវាចា), ហិរិ, ឱត្តប្ប, សុត, ចាគ, បញ្ញា, បុថុជ្ជនណាមានអរិយទ្រព្យ ៧ ប្រការ នេះ ហៅថា កល្យាណបុថុជ្ជន និងរាប់ដល់បុគ្គលមានអនុលោមញាណ)។

២-ការពិចារណាអង្គឈានរបស់អ្នកមានឈាន។

៣-ការពិចារណារបស់ព្រះអរិយ(បច្ចវេក្ខណញាណទាំងអស់មាន ១៩ វារៈ គឺបច្ច-វេក្ខណវិថី ១៥ វារៈរបស់ព្រះសេក្ខបុគ្គលដែលពិចារណាមគ្គ ផល និព្វាន កិលេស ដែលលះហើយ កិលេសដែលនៅសល់ និងរបស់ព្រះអរហន្តដែលពិចារណាមគ្គ ផល និព្វាន កិលេសដែលលះហើយ ជា ៤ វារៈ ព្រះអរហន្តមិនមានការពិចារណា កិលេសដែលនៅសល់ ព្រោះលោកលះកិលេសទាំងអស់បានហើយ)៕

*លោកិយបញ្ញា មាន ២ គឺ:

១-កម្មស្សកតាបញ្ញា: បញ្ញាឃើញថាសត្វទាំងឡាយមានកម្មជារបស់ខ្លួន ប្រព្រឹត្តទៅ

តាមកម្មរបស់ខ្លួន លោកហៅថា "ទសវត្ថុសម្មាទិដ្ឋិ"។ បញ្ញានេះរក្សាចិត្តជាឧបេក្ខា មិនឲ្យធ្លាក់ទៅក្នុងអកុសលធម៌ ដោយហេតុកុសលជាបច្ច័យដល់អកុសល ឬ អកុសលជាបច្ច័យដល់អកុសល៕

*កម្មស្សកតាបញ្ញា ១០ យ៉ាង:

-អត្ថិ ទិន្នំ យល់ថា ទានដែលគេឲ្យហើយ មានផល។

-អត្ថិ យិដ្ឋំ យល់ថា ការបូជាធំ មានផល។

-អត្ថិ ហុតំ យល់ថា ការបូជាតូច មានផល។

-អត្ថិ សុកតទុក្កតានំ កម្មានំ វិបាកោ យល់ថា ផលវិបាករបស់កម្មដែលគេធ្វើល្អ និង ធ្វើអាក្រក់ មាន។

-អត្ថិ អយំ លោកោ យល់ថា (សត្វដែលមកកើតក្នុង)លោកនេះ មាន។

-អត្ថិ បរោ លោកោ យល់ថា (សត្វដែលកើតក្នុង)លោកខាងមុខ មាន។

-អត្ថិ មាតា យល់ថា គុណមាតា មាន។

-អត្ថិ បិតា យល់ថា គុណបិតា មាន។

-អត្ថិ សត្តា ឱបបាតិកា យល់ថា ពួកសត្វជាឱបបាតិក:(ដែលកើតឡើងឯងដោយអំណាចកម្លាំងកម្ម ឥតមាតាបិតា ឥតមេបា ផ្នែកខាងកុសល មានទេវតាពួកខ្លះ ផ្នែកខាងអកុសល មានសត្វនរក និងប្រេតជាដើម)កំណើត មាន។

-អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យល់ថា ពួកសមណព្រាហ្មណ៍ក្នុងលោក ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិត្រឹមត្រូវ ដែលធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយសម្តែងបាន មាន។

២-សច្ចានុលោមិកញាណ(អនុលោមញាណ): បញ្ញាកំណត់ដឹងទុក្ខនៃបញ្ចខន្ធដែលអនុលោមតាមលំដាប់ពីញាណខាងដើមរហូតដឹងច្បាស់អរិយសច្ចធម៌។

### *លោកុត្តរបញ្ញា:

-លោកុត្តរបញ្ញា: បញ្ញាប្រព្រឹត្តទៅក្នុងមគ្គ និងផលដែលបានឃើញប្រចក្សអំពីព្រះនិព្វាន។

### *លក្ខណផ្សេងគ្នានៃការដឹងដោយចិត្ត សតិ បញ្ញា:

-ចិត្ត គឺជាសភាវធម៌ដែលដឹងនូវអារម្មណ៍។ ឧទាហរណ៍: ខណមានបដិឃ(សេចក្តីទោមនស្ស ថ្នាំងថ្នាក់ ក្រោធ)កើតឡើង ចិត្តដឹងអំពីអារម្មណ៍ដែលបដិឃ ថាខ្លួនជាអ្នកបដិឃ។

-សតិ គឺជាសភាវធម៌ដែលដឹងអំពីចិត្ត។ ឧទាហរណ៍: ខណចិត្តប្រកបដោយបដិឃកើតឡើង សតិក៏កើតឡើងដឹងអំពីចិត្តដែលប្រកបដោយបដិឃនោះពុំមែនជាភាវនៃខ្លួន។ ចិត្ត និងសតិកើតរួមគ្នាដឹងអារម្មណ៍តែមួយ។

-បញ្ញា គឺសភាវធម៌ដែលដឹងហេតុ និងផល ដឹងអរិយសច្ច ដឹងទូទៅដល់ធម៌ទាំងដែលជាកុសល អកុសល ធម៌ដែលគួរសេព ធម៌ដែលមិនគួរសេព ដឹងធម៌ដែលអាក្រក់ ធម៌ដែលប្រណិត ធម៌ដែលចូលគ្នាបាន ធម៌ដែលចូលគ្នាមិនបាន និងពិចារណាហេតុប្បច្ចយមានឧបាយអប់រំចិត្ត។ កាលសតិកើតឡើងដឹងអំពីចិត្តដែលប្រកបដោយបដិឃហើយ បញ្ញាក៏កើតឡើងពិចារណាហេតុប្បច្ចយ ឃើញទោសរបស់បដិឃ អប់រំចិត្តឲ្យលះអារម្មណ៍នោះចោល។ បដិឃជាអកុសលចិត្ត ចំណែកឯសតិ និងបញ្ញាជាកុសលចិត្ត ចិត្តទាំងពីរប្រភេទនេះមិនកើតរួមជាមួយគ្នាបានឡើយ គឺមួយកើតមុន មួយកើតក្រោយ តែដោយមានសញ្ញាចេតសិកសម្បយុត្តនឹងចិត្តគ្រប់ដួង ក៏មានការចងចាំនូវអារម្មណ៍។ សតិ និងបញ្ញារមែងជាធម៌គូនឹងគ្នា គឺសតិជាឧបការដល់បញ្ញា បុគ្គលបដិបត្តិកម្មដ្ឋានរមែងចម្រើនសតិ និងបញ្ញាបានប្រសើរជាងបុគ្គលផ្នែកបរិយត្តិ។ ចិត្ត សតិ និងបញ្ញាកើតរួមគ្នាដឹងអារម្មណ៍តែមួយ។

### *ធម៌ជំនួយស្មារតី:

ជាងដែកដែលចង់បានកាំបិតរឹងមាំមុតល្អ រមែងបង្កាត់ភ្លើងដុតដុំដែក ហើយប្រើញញួរដំយ៉ាងយកចិត្តទុកដាក់ដោយសេចក្តីព្យាយាម យ៉ាងណាមិញ បើនរជនឯណាចង់បានសទ្ធារឹងមាំមុតល្អ(តាំងមាំក្នុងកុសលធម៌) នរជននោះត្រូវព្យាយាមដូច

ជាជាងដែកដោយតាងសតិជាជាងដែក សទ្ធាជាកាំបិត តបធម៌ជាភ្លើង ចិត្តជាដុំដែក បញ្ញាជាញញួរដោយហេតុយ៉ាងដូច្នោះ។ អគ្គិមានកម្ដៅខ្លាំងយ៉ាងណាក៏មិនប្រសើរស្មើដោយតបធម៌ដែលអាចដុតរម្ងាប់កិលេសបាន អគ្គិមានរស្មីភ្លឺយ៉ាងណាក៏មិនប្រសើរស្មើដោយរស្មីបញ្ញាដែលអាចកម្ចាត់បង់អវិជ្ជាបាន ហេតុដូច្នេះ ចូរព្យាយាមសិក្សាព្រះធម៌ និងបដិបត្តិកម្មដ្ឋានអប់រំចិត្តចម្រើនសតិបញ្ញា កាន់យកហិរោត្តប្បវៀរចាកបាបទាំងពួង សទ្ធាចេតនាតាំងមាំសាងបុណ្យ រក្សាសីល ចម្រើនភាវនា កុសលជាយាននាំសត្វទៅកាន់សួគ៌ា បញ្ញាល្អជាឃើញព្រះនិព្វានជាបរមសុខ៕

## *គន្ថធុរ និង វិបស្សនាធុរ:

កិច្ចក្នុងព្រះពុទ្ធសាសនាមាន ២ គឺ: គន្ថធុរៈ ជាកិច្ចការរៀនសូត្រខាងបរិយត្តិធម៌ (តាមសមគួរដល់បញ្ញាចេះចាំ និងសម្ដែងបាន)។ វិបស្សនាធុរៈ ជាកិច្ចការបដិបត្តិធម៌កម្មដ្ឋាន។ ការរៀនបរិយត្តិធម៌ ដើម្បីប្រយោជន៍យល់អំពីបរមត្ថធម៌ បដិច្ចសមុប្បាទធម៌ និងចតុរារិយសច្ចធម៌ មើលឃើញត្រៃលក្ខណធម៌លះសេចក្ដីប្រកាន់ចំពោះខន្ធ-បញ្ចក និងមានសទ្ធាបដិបត្តិទាន សីល ភាវនា ម្យ៉ាងទៀតបរិយត្តិធម៌នេះជាឧបការដល់ការបដិបត្តិកម្មដ្ឋាន។ សម័យបច្ចុប្បន្ននេះ អាយុកប្បនៅត្រឹម ៧៥ ឆ្នាំ ជាកាលដែលសត្វលោកចម្រើនច្រើនដោយអកុសលកម្មបថ ព្រោះវត្ថុកាម(រូប សំឡេង ក្លិន រស ផោដ្ឋព្វ)សម្បូរបែបក្រៃលែងដែលជាទីតាំងកើតនៃកិលេសកាម(ឆន្ទរាគ គឺលោភចេតសិក) ធ្វើឲ្យកិលេសរឹងត្អឹងមិនងាយនឹងអាចចាក់ធ្លុះសច្ចធម៌បានដូចសម័យពុទ្ធកាលដែលជាកាលសម្បត្តិ។ កិលេសអាចរម្ងាប់ជាអនុសយបានដោយចិត្តវិសុទ្ធិ ដែលសម្រេចបានពីការបដិបត្តិសមថកម្មដ្ឋាន ចិត្តវិសុទ្ធិនេះជាបច្ច័យដល់វិបស្សនាញាណកើតឡើងលះកិលេសជាតទង្គប្បហាន រហូតមគ្គញាណកើតឡើងលះកិលេសជាសមុច្ឆេទប្បហានតាមលំដាប់នៃមគ្គចិត្តនោះៗ ហេតុដូច្នេះ ចូរបរិស័ទទាំងឡាយព្យាយាមធ្វើធុរៈទាំង ២ នេះដោយមិនមានសេចក្ដីប្រមាទ។ បរិយត្តិ បានដល់សុតាមយបញ្ញា និងចិន្តាមយបញ្ញា រីឯបដិបត្តិ និងបដិវេធ បានដល់ភាវនាមយបញ្ញា។ ចិន្តាមយបញ្ញា ពិចារណាធម៌ប្រព្រឹត្តទៅក្នុងអារម្មណ៍មានតួខ្លួន ឃើញធម៌តាមសេចក្ដីពិតដោយពុំបានទម្លុះអារម្មណ៍(ពាល់ត្រូវអារម្មណ៍ គឺថាពិចារណាធម៌ក្នុងកម្មដ្ឋានស្រាប់តែបញ្ញាផុសឡើងក្នុងចិត្ត) និងធ្វើយោនិសោមនសិការៈ(ធ្វើ

អារម្មណ៍ទុកក្នុងចិត្តដោយបញ្ញា) ក៏មានកម្លាំងមិនស្មើដោយភាវនាមយបញ្ញា។ ភាវនាមយបញ្ញា ពិចារណាធម៌ឃើញតាមសភាវពិតដោយទម្លុះអារម្មណ៍ ធ្វើយោនិសោមនសិការជាអារម្មណ៍មានកម្លាំង អារម្មណ៍ជាទីតាំងកើតនៃសតិ សតិជាឧបការដល់បញ្ញាដែលជាតួវិបស្សនាកើតឡើង ពិចារណាធម៌ប្រព្រឹត្តទៅក្នុងអារម្មណ៍មិនមានតួខ្លួនក្នុងកម្មដ្ឋាន ឃើញសភាវធម៌ដែលកំពុងប្រាកដតាមទ្វារទាំង ៦ នោះមានលក្ខណជាបរមត្ថធម៌សុទ្ធសាធ៕

## *ការកំណត់ដឹងដោយសតិ និងដោយទិដ្ឋិ:

ការកំណត់ដឹងខណបានឃើញ ឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វ មាន ២ យ៉ាង គឺកំណត់ដឹងដោយសតិ និងដោយទិដ្ឋិ។ សតិ គឺជាមហាកុសលញាណសម្បយុត្តចិត្ត ការកំណត់ដឹងដោយសតិ ខណមានអារម្មណ៍ណាមួយកើតឡើងមិនប្រក្រតី សតិក៏កើតឡើងដឹងនូវអាម្មណ៍នោះ ហើយបញ្ញាក៏កើតឡើងពិចារណាអំពីហេតុប្បច្ច័យ រួចក៏លះអារម្មណ៍នោះចោលដោយកំណត់យកត្រឹមបានឃើញ ឮ ដឹងក្លិន ដឹងរស់ ដឹងផោដ្ឋព្វ។ ទិដ្ឋិ ជាអកុសលចិត្ត ប្រព្រឹត្តទៅក្នុងអារម្មណ៍មានតួខ្លួន ការកំណត់ដឹងគ្រប់ខណត្រឹមពេលបានឃើញ ឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វបែបនេះអាចជាការកំណត់ដឹងដោយទិដ្ឋិ ព្រោះរូប សំឡេង ក្លិន រស ផោដ្ឋព្វកើតតាមបញ្ចទ្វារវិថី ហើយបន្តដល់មនោទ្វារវិថីទៀតទើបដឹងអត្ថន័យច្បាស់ វិថីចិត្តវារៈនីមួយៗកើតរលត់លឿងណាស់ យើងមិនអាចធ្វើការកំណត់ដឹងរូប សំឡេង ក្លិន រស ផោដ្ឋព្វត្រឹមខណបានឃើញ ឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វដូច្នេះឡើយ ព្រោះទម្រាំយើងបានដឹងរូប សំឡេង ក្លិន រស ផោដ្ឋព្វនោះវិថីចិត្តកើតរលត់ច្រើនវារៈមកហើយ។ បច្ចុប្បន្ននេះ សត្វលោកប្រព្រឹត្តក្នុងជីវិតប្រចាំថ្ងៃច្រើនដោយអកុសលចិត្តជាងកុសលចិត្ត បើបុគ្គលណាបានបដិបត្តិកម្មដ្ឋាន ឬចម្រើនសតិប្បដ្ឋានអាចកំណត់ដឹងរូប សំឡេង ក្លិន រស ផោដ្ឋព្វដោយសតិ ប៉ុន្តែចំពោះបុគ្គលមានបញ្ញាថ្នាក់ទាន សីលមិនបានអប់រំចិត្តទេ ការចូលទៅកំណត់ដឹងគ្រប់ខណត្រឹមពេលបានឃើញ ឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វ អាចជាការកំណត់ដឹងដោយទិដ្ឋិក៏ថាបាន បើទិដ្ឋិកើតឡើងហើយ មានះក៏រមែងកើតឡើងដែរ ព្រោះជាធម៌គូនឹងគ្នា។ សតិចម្រើនបានល្អដោយការបដិបត្តិសមថកម្មដ្ឋានដែលត្រឹមត្រូវតាមសម្មាបដិបទា បញ្ញាចម្រើនបានល្អដោយការ

បដិបត្តិវិបស្សនាកម្មដ្ឋានដែលមានចិត្តវិសុទ្ធិជាបាទ គឺគ្រឿងទ្រ។ ហេតុដូច្នេះ សូមបរិស័ទទាំងឡាយធ្វើការពិចារណា និងសន្និដ្ឋាននូវការបដិបត្តិរបស់ខ្លួនដែលចូលទៅកំណត់ដឹងគ្រប់ខណពេលបានឃើញឲ្យត្រឹមជាការឃើញ ឮឲ្យត្រឹមជាការឮ ដឹងក្លិនឲ្យត្រឹមជាការដឹងក្លិន ដឹងរសឲ្យត្រឹមជាការដឹងរស ដឹងផោដ្ឋព្វៈឲ្យត្រឹមជាការដឹងផោដ្ឋព្វៈនោះដោយសតិ ឬដោយទិដ្ឋិ។ វារៈចិត្តតាមបញ្ចទ្វារវិថីត្រូវបន្តដល់មនោទ្វារវិថី មនោទ្វារវិថីដែលកើតឡើងដឹងអារម្មណ៍រល់ទៅ អារម្មណ៍នោះជាទីតាំងកើតនៃសតិ សតិជាឧបការដល់បញ្ញាកើតឡើងពិចារណាហេតុប្បច្ចយអប់រំចិត្តលះបង់សេចក្ដីប្រកាន់(ឧបាទាន)តាំងនៅជាឧបេក្ខា ទើបកំណត់ដឹងត្រឹមបានឃើញ ឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វវិញ នេះសម្រាប់បុគ្គលមានសតិប្បដ្ឋានវិបស្សនា បើបុគ្គលមិនមានសតិប្បដ្ឋានវិបស្សនាទេ នឹងមិនមានសតិកើតឡើងដឹងទាន់ពេល ឃើញធម៌ដែលកំពុងប្រាកដតាមសភាវពិតបានឡើយ៕

## *ចេតនា និងអារម្មណ៍ជាធម៌ដែលត្រូវសម្លឹងមើល:

ត្រូវសម្លឹងមើលចេតនាជាប្រចាំមុននឹងប្រព្រឹត្តនូវកម្មអ្វីមួយ។ ឧទាហរណ៍: មុននឹងសម្ដែងធម៌ ត្រូវសម្លឹងមើលចេតនានោះជាកុសល ឬជាអកុសល បើចេតនាក្នុងការសម្ដែងធម៌នោះជាកុសល គឺប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដល់បរិស័ទ តែបើចេតនាក្នុងការសម្ដែងធម៌នោះជាអកុសល គឺប្រព្រឹត្តទៅដើម្បីលាភ យស សរសើរ សុខ។ កាលបើមើលឃើញចេតនាក្នុងការសម្ដែងធម៌នោះប្រព្រឹត្តទៅជាកុសល ត្រូវសម្ដែងដោយសេចក្ដីគោរពចំពោះធម៌ មិនសម្ដែងហួសធម៌ដែលខ្លួនចេះ ឬមិនត្រូវបញ្ចូលទិដ្ឋិរបស់ខ្លួនទាំងខ្លួនមិនទាន់បានទម្លុះបដិវេធ។ ម្យ៉ាងទៀត ត្រូវសម្លឹងមើលអារម្មណ៍ពេលកំពុងប្រព្រឹត្ត និងក្រោយពេលបានប្រព្រឹត្តកម្មរួច ព្រោះថាបុថុជ្ជនទាំងឡាយនៅមានសេចក្ដីញាប់ញ័រចំពោះលោកធម៌ ជួនក៏សោមនស្សដោយសេចក្ដីគាប់ចិត្តចំពោះកម្មដែលបានធ្វើ ព្រោះបាននូវលាភ យស សរសើរ សុខ ជួនក៏ទោមនស្សដោយសេចក្ដីមិនគាប់ចិត្តចំពោះកម្មដែលបានធ្វើ ព្រោះបាននូវអលាភ អយស និន្ទា ទុក្ខ។ សោមនស្សអាចជាកុសល និងជាអកុសល គឺថាបើសោមនស្សកើតឡើងព្រោះសេចក្ដីជ្រះថ្លាក្នុងធម៌ ឬជ្រះថ្លាចំពោះសទ្ធារបស់បរិស័ទ សោមនស្សនោះគឺជាកុសលដែលត្រូវរក្សាធ្វើឲ្យផូរផង់ តែបើសោមនស្សនោះកើតឡើង

ព្រោះលោកធម៌ សោមនស្សនោះគឺជាអកុសល ត្រូវលះបង់ចោល ហើយតម្រង់ទិដ្ឋិគឺអប់រំចិត្តពីការគិតមិនល្អមកគិតល្អវិញ៕

*ការកំណត់ដឹងទុក្ខ:

ការដែលមិនមានសតិប្បដ្ឋាន និងមិនបានសោយនូវសុខដែលកើតអំពីសេចក្ដីស្ងប់ព្រោះការរម្ងាប់នូវនីវរណធម៌ រមែងមើលមិនឃើញទោសរបស់កាមសុខ ក៏ប្រាថ្នាបាននូវសេចក្ដីសុខដែលជាកាមសុខ តែប្រាថ្នាកុំបាននូវសេចក្ដីទុក្ខ ពេលមានសេចក្ដីសុខកើតឡើងក៏សោមនស្សវង្វេងក្នុងអារម្មណ៍ដោយពុំបានដឹងថា កាមសុខនោះជាហេតុនាំឲ្យដល់នូវសេចក្ដីទុក្ខ ធ្វើឲ្យកើតមានបមាទធម៌ ប៉ុន្តែនៅពេលមានសេចក្ដីទុក្ខកើតឡើងក៏ទោមនស្សវង្វេងក្នុងអារម្មណ៍ ធ្វើឲ្យកើតមានបមាទធម៌ផងដែរ ព្រោះហេតុពុំបានយល់ដឹងអរិយសច្ច។ សេចក្ដីពិតគឺថា៖ សេចក្ដីសុខកើតឡើងព្រោះកុសលកម្មឲ្យផល រីឯសេចក្ដីទុក្ខកើតឡើង ព្រោះអកុសលកម្មឲ្យផល ហើយកម្មជាអ្នកតាក់តែងសត្វក្នុងត្រៃភពឲ្យសោយនូវសំសារទុក្ខ។ ហេតុដូច្នេះ ចូរបរិស័ទទាំងឡាយព្យាយាមសិក្សាព្រះបរិយត្តិយល់ដឹងបរមត្ថធម៌ បដិច្ចសមុប្បាទធម៌ ចតុរារិយសច្ចធម៌ ដើម្បីកើតមានសទ្ធាបញ្ញាឧបការដល់ការបដិបត្តិកម្មដ្ឋានចម្រើនសតិបញ្ញាកុំឲ្យវង្វេងក្នុងកាមសុខ និងពេលមានទុក្ខកើតឡើងអាចកំណត់ដឹងទុក្ខ(កំណត់ដឹងទុក្ខជាវេទនាដែលជាបរមត្ថធម៌) ពិចារណាហេតុប្បច្ច័យដែលនាំឲ្យកើតមានសេចក្ដីទុក្ខ ពិចារណារហូតសតិរឭកដឹងបញ្ចក្ខន្ធជាទុក្ខរឿយៗ មានអារម្មណ៍សង្វេគចំពោះអភិសង្ខារ(កម្ម)កើតឡើង អារម្មណ៍ដែលសង្វេគនោះជាភូមិឋានរបស់សតិ ឯសតិជាឧបការដល់បញ្ញាកើតឡើងពិចារណាហេតុប្បច្ច័យអប់រំចិត្តឲ្យលះឧបាទាន៕

*ខណៈមានទុក្ខត្រូវពិចារណា:

សេចក្ដីទុក្ខកើតឡើងព្រោះភាវគ្រាំគ្រាទ្រុឌទ្រោមនៃកាយ រូបកើតរលត់បន្តគ្នាជាក្រសែ អស់ទៅសូន្យទៅគ្រប់ខណៈជារៀងរាល់ថ្ងៃដរាបដល់បែកធ្លាយ ឯចិត្តក៏កើតរលត់បន្តគ្នាជាក្រសែ អស់ទៅសូន្យទៅជារៀងរាល់ថ្ងៃដរាបដល់ចុតិ ប្រៀបដូចជាក្រសែទឹកហូរដរាបដល់ទីបញ្ចប់។ ហេតុដូចនេះ គប្បីពិចារណាឃើញរូបធម៌ និងនាមធម៌ជាសភាវពីរដាច់ដោយឡែកពីគ្នា ប្រៀបដូចជាបញ្ញើក្អែក(ចិត្ត) និងដើមឈើ(រូប)អាស្រ័យគ្នាដរាបដល់អស់ជីវិត ធម៌ណាដែលមានបច្ច័យ(កម្ម)តាក់តែងឲ្យកើត

ឡើង រមែងប្រព្រឹត្តទៅដោយសាមញ្ញលក្ខណ(អនិច្ចំ ទុក្ខំ អនត្តា)។ ចូរសប្បុរសព្យាយាមចម្រើនសតិប្បដ្ឋានវិបស្សនា កំណត់ដឹងសភាវធម៌ដែលកំពុងប្រាកដជាបរមត្ថធម៌(សភាវធម៌មានពិតដែលពុំមែនជាសត្វ បុគ្គល តួខ្លួន) និងឃើញភ័យក្នុងសង្ខារធម៌ដែលជាទុក្ខ ហើយរៀនលះសក្កាយទិដ្ឋិឲ្យស្តើងជាបណ្តើរៗ៕

*បដិបទាប្រព្រឹត្តទៅលះឧបាទាន:

ការដែលបានសិក្សាយល់ដឹងអំពីបរមត្ថធម៌ បដិច្ចសមុប្បាទធម៌ ចតុរារិយសច្ចធម៌ ធ្វើយោនិសោមនសិការជារឿយៗ ចម្រើនសតិប្បដ្ឋានភាវនាជារឿយៗរហូតសតិចាស់ក្លា អារម្មណ៍ទាំងឡាយដែលកើតឡើងនឹងបានជាទីតាំងរបស់សតិរឭកដឹងដោជ្ឈព្វ វេទនា ចិត្ត ធម្មា កាលសតិជាឧបការដល់បញ្ញាដែលជាតួវិបស្សនាកើតឡើងពិចារណាហេតុប្បច្ចយ ឃើញទោសរបស់អវិជ្ជា តណ្ហា ឧបាទានប្រព្រឹត្តទៅជាអភិសង្ខារ វិលកើតវិលស្លាប់រងទុក្ខក្នុងសង្សារវដ្តដ៏ក្រៃលែងប្រមាណមិនបាន បញ្ញាក៏អប់រំចិត្តលះឧបាទានឲ្យស្តើងជាបណ្តើរៗ៕

*បញ្ញាកាត់ផ្តាច់វដ្ត:

បញ្ញាដែលពិចារណាឃើញការអស់ទៅនៃកម្មជាសុខ ហើយធ្វើអារម្មណ៍នោះទុកក្នុងចិត្តជារឿយៗ ចិត្តនឹងមានការអស់ទៅនៃកម្មជាសុខមកជាអារម្មណ៍របស់វិបស្សនា ប្រព្រឹត្តក្នុងវិបស្សនាញាណរហូតមាននិព្វានជាអារម្មណ៍ ញុំាងមគ្គឲ្យកើតឡើងរហូតដល់អរហត្តមគ្គ លះសំយោជនកិលេសអស់ជាសមុច្ឆេទប្បហានកាត់ផ្តាច់កិលេសវដ្ត កម្មវដ្ត វិបាកវដ្ត។

*កម្មមាន បុគ្គលអ្នកធ្វើកម្ម និងទទួលផលរបស់កម្មមិនមាន:

ផ្នែកខាងកម្មជាកុសលធ្វើដោយសទ្ធា សតិ បញ្ញា អលោភ អទោស មុទិតា ករុណា តត្រមជ្ឈត្តតា មនសិការ វីរិយ ចេតនា ឆន្ទ ដែលជាសោភណចេតសិកសម្បយុត្តមហាកុសលចិត្ត។ រីឯផ្នែកខាងកម្មជាអកុសលវិញធ្វើដោយអវិជ្ជា(មោហ) តណ្ហា(លោភ) ឧបាទាន(លោភ+ទិដ្ឋិ) មានះ អហិរិក អនោត្តប្ប ទោស វិចិកិច្ឆា មនសិការ វីរិយ ចេតនា ឆន្ទ ដែលជាអកុសលចេតសិកសម្បយុត្តអកុសលចិត្ត។ វិបាកចិត្ត ជាអ្នកធ្វើកិច្ចចុតិបដិសន្ធិសោយនូវភពសម្បត្តិដែលជាផលរបស់កុសល

កម្ម ឬអកុសលកម្មនោះៗ។ ចិត្តប្រៀបដូចជាទឹក សោភណចេតសិកប្រៀបដូចជាស្ករ កាលបើដាក់ស្ករចូលក្នុងទឹក ស្ករក៏រលាយទៅជាទឹកស្ករ ចំណែកអកុសលចេតសិកប្រៀបដូចជាអំបិល កាលបើដាក់អំបិលចូលក្នុងទឹក អំបិលក៏រលាយទៅជាទឹកអំបិល។ ចិត្ត និងចេតសិកកើតរលត់រួមគ្នាគ្រប់ខណៈ តែឲ្យចិត្តជាប្រធាននៃចេតសិក ចិត្តមានរូបជាទីអាស្រ័យនៅ ប្រៀបដូចជាបញ្ញើក្អែក(ចិត្ត)អាស្រ័យនៅនឹងដើមឈើ(រូប)។ រូប ចិត្ត ចេតសិក សុទ្ធតែជាបរមត្ថធម៌ ហេតុដូច្នេះ ចូរបរិស័ទព្យាយាមសិក្សាយល់ដឹងបរមត្ថធម៌ បដិច្ចសមុប្បាទធម៌ ចតុរារិយសច្ចធម៌ ហើយកុំនៅត្រឹមនេះ ព្រោះការរៀនសូត្យចេះចាំយល់ដឹងផ្នែកបរិយត្តិបានត្រឹមសុតាមយបញ្ញា ឬចិន្តាមយបញ្ញាប៉ុណ្ណោះ បញ្ញាកម្រិតនេះអាចអប់រំចិត្តបានជាបច្ច័យដល់អនាគតជាតិ តែបើបានចិន្តាមយបញ្ញាហើយបន្តបដិបត្តិសមថវិបស្សនាកម្មដ្ឋានទៅទៀត អាចនឹងបានដល់ភាវនាមយបញ្ញាទម្លុះបដិវេធលោកិយ(អប្បនាសមាធិ ឬក៏លោកិយបញ្ញា គឺនាមរូបបរិច្ឆេទញាណដល់អនុលោមញាណដែលអាចលះកិលេសជាតទង្គប្បហាន គឺលះកិលេសដោយខណៈៗ) ហើយអាចនឹងទម្លុះបដិវេធលោកុត្តរបានដល់មគ្គញាណ លះកិលេសជាសមុច្ឆេទប្បហានតាមកម្លាំងនៃមគ្គនោះៗ ឃើញព្រះនិព្វានដោយលោកុត្តរបញ្ញា ឬអាចចូលផលសមាបត្តិពាល់ត្រូវសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ ឬមានបារមីខ្ពស់ជាងនេះទៀត អាចចូលនិរោធសមាបត្តិរម្លត់វេទនាសញ្ញា(ចិត្ត) និងអស្សាសប្បស្សាស៕

## *វដ្តគាមិនីកុសល និង វិវដ្តគាមិនីកុសល:

ការបានដឹងនូវធម៌អ្វីប្រសើរស្មើដោយការបានដឹងនូវធម៌អនិច្ចំ ទុក្ខំ អនត្តាពុំមាន ការបានឃើញនូវធម៌អ្វីប្រសើរស្មើដោយការបានឃើញនូវធម៌អរិយសច្ចពុំមាន ការបាននូវសម្បត្តិអ្វីប្រសើរស្មើដោយការបាននូវសម្បត្តិព្រះនិព្វានពុំមាន។ បុគ្គលដែលត្រូវអវិជ្ជាបិទបាំង រមែងសម្គាល់ឃើញសម្បត្តិមនុស្ស សម្បត្តិទេវតា ក៏នឹកស្មានថាសម្បត្តិទាំងនោះជារបស់វិសេស ត្រជាក់ត្រជុំថ្លៃថ្លា ប្រកបដោយសេចក្តីសុខ ថាជារបស់ទៀងទាត់ មិនវិបល្លាសប្រែប្រួល ម្ល៉ោះហើយក៏នាំគ្នាបំពេញកុសលផ្សេងៗចំពោះតែខាងវដ្តគាមិនីកុសល(កុសលដែលធ្វើដំណើរវិលវល់ក្នុងភព) ឯសម្បត្តិទាំងនោះឯងរមែងចងក្រៀកបុគ្គលជាម្ចាស់ឲ្យវិលកើតវិលស្លាប់ក្នុងភព ឆេះពោល

រាលដោយគំនរភ្លើងរាគ និងទោស រងទុក្ខក្នុងវដ្តសង្សារវៀយៗរកទីបំផុតគ្មាន។ ការបំពេញកុសលព្រោះឃើញនូវអមតធម៌ គឺជាវិវដ្តគាមិនីកុសល(កុសលដែលប្រព្រឹត្តទៅដើម្បីដល់នូវព្រះនិព្វាន) ព្រមដោយការបដិបត្តិសីល សមាធិ បញ្ញានឹងចេញចាកសំសារទុក្ខបាន៕

*ចក្ខុ ២ ប្រភេទ:

១-មំសចក្ខុ បានដល់ភ្នែកសាច់ មាន ២ យ៉ាង។ ចំណែកប្រកបៈ មានរូប ១០ គឺ: មហាភូតរូប ៤ វណ្ណរូប គន្ធរូប រសរូប ឱជារូប សម្ភវ គឺការកើតឡើង សណ្ឋាន គឺការតាំងនៅដោយប្រពៃ (រូបទាំង ១០ នេះកើតដោយសមុដ្ឋាន ៤) និងសសម្ភារចក្ខុ(ដុំសាច់ដែលនៅក្នុងគ្រាប់ភ្នែក) គឺជីវិតរូប ភាវរូប កាយប្រសាទរូប ចក្ខុប្រសាទរូប(រូបទាំង ៤ នេះមានកម្មជាសមុដ្ឋានតែម្យ៉ាង)។ ចក្ខុបសាទរូប គឺជាកែវភ្នែកថ្លាដូចកញ្ចក់ដែលអាស្រ័យមហាភូតរូប ៤ នៅក្នុងសាម្ភារចក្ខុ៕

២-បញ្ញាចក្ខុ បានដល់ភ្នែក គឺបញ្ញា មាន ៥ យ៉ាង:

-ពុទ្ធចក្ខុ ព្រះនេត្ររបស់ព្រះពុទ្ធ ដែលជ្រាបនិស្ស័យបារមីយរបស់សត្វ បានដល់អាសយានុសយញ្ញាណ និងឥន្ទ្រិយបរោបរិយត្តិញ្ញាណ គឺមហាកិរិយាញ្ញាណសម្បយុត្តចិត្ត ៤។

-សមន្តចក្ខុ ព្រះនេត្រដែលដឹងធម៌ដោយជុំវិញ បានដល់សព្វញ្ញុតញ្ញាណ ជាបញ្ញាដែលដឹងធម៌ទាំងពួង ទាំងបញ្ញត្តិ និងបរមត្ថ គឺមហាកិរិយាញ្ញាណសម្បយុត្តចិត្ត ៤។

-ញាណចក្ខុ ព្រះនេត្រដែលជាប្រាជ្ញាត្រាស់ដឹងធម៌ បានដល់បញ្ញាក្នុងអរហត្តមគ្គចិត្ត។

-ទិព្វចក្ខុ ព្រះនេត្រទិព្វដែលអាចមើលឃើញបានឆ្ងាយ និងក្នុងទីកំបាំង គឺអភិញ្ញាចិត្ត ២។

-ធម្មចក្ខុ ព្រះនេត្រឃើញធម៌ដែលជាត្រៃលក្ខណ គឺបញ្ញាក្នុងមគ្គ ៣ ខាងក្រោម។

ញ-អប្បនាសមាធិ(រូបជ្ឈាន ៤ និង អរូបជ្ឈាន ៤)

ឈាន គឺជាធម្មជាតិដែលសម្លឹងអារម្មណ៍ដុតបំផ្លាញបដិបក្ខធម៌(នីវរណធម៌)។

-រូបជ្ឈាន:

រូបជ្ឈាន ជាចិត្តស្ងប់ថ្លានឹងស្មើក្នុងភាវនា ព្រោះអង្គឈានរម្ងាប់នូវនីវរណធម៌។ ឈានលាភីចម្រើនសមាធិប្រកបដោយវិតក្ក(នឹកសម្លឹងអារម្មណ៍កម្មដ្ឋាន) ថីនមិទ្ធ(សេចក្តីធុញទ្រាន់ច្រអូសងុយងោក)រមែងមិនកើតមាន, វិចារ(ពិចារណាអារម្មណ៍កម្មដ្ឋាន) វិចិកិច្ឆា(សេចក្តីសង្ស័យ)រមែងមិនកើតមាន, បីតិ(ផរណាបីតិ) ព្យាបាទ(សេចក្តីគុំកួនធ្វើឲ្យអ្នកដទៃវិនាស)រមែងមិនកើតមាន, សុខ(សុខកាយ និងសុខចិត្ត) ឧទ្ធច្ចកុក្កុច្ច(សេចក្តីរាយមាយសោកស្តាយក្រហាយចិត្ត)រមែងមិនកើតមាន, ឯកគ្គតា(ចិត្តស្ងប់ស៊ប់ក្នុងអារម្មណ៍តែមួយ) កាមឆន្ទ(សេចក្តីពេញចិត្តក្នុងវត្ថុកាម)រមែងមិនកើតមាន។ ព្រះដ៏មានព្រះភាគទ្រង់សរសើរនូវឈានដែលស្ងប់ចាកកាម ស្ងប់ចាកអកុសលធម៌ទាំងឡាយដែលប្រកបដោយអង្គឈាន ព្រះអង្គទ្រង់មិនសរសើរនូវឈានដែលមានចិត្តត្រូវនីវរណរួបរឹតគ្របសង្កត់ហើយ ក៏មិនដឹងច្បាស់តាមសេចក្តីពិតនូវធម៌ជាគ្រឿងរលាស់ចោលនីវរណដែលកើតឡើង បុគ្គលនោះធ្វើនូវនីវរណឲ្យបិតក្នុងចិត្តហើយក៏ស្ងួតស្ងប់ ជ្រប់ សញ្ជប់សញ្ជឹង។ ឈានមាន ២ ប្រភេទគឺ: លក្ខណូបនិជ្ឈាន: បានដល់វិបស្សនា: សម្លឹងពិនិត្យត្រៃលក្ខណ, មគ្គ: កិលេសដែលវិបស្សនាកំចាត់ហើយ, ផល: សម្លឹងលក្ខណដែលជានិរោធសច្ច។ អារម្មណូបនិជ្ឈាន: កសិណភាវនាដែលសម្លឹងអារម្មណ៍ដុតបំផ្លាញបដិបក្ខធម៌ បានដល់សមាបត្តិ ៨(រូបជ្ឈាន ៤ និងអរូបជ្ឈាន ៤) ឈានក្នុងទីនេះគឺសំដៅយកអារម្មណូបនិជ្ឈាន។ ក្នុងបឋមជ្ឈាន ឈានលាភីត្រូវឡើងកាន់អង្គវិតក្ក នឹកសម្លឹងអារម្មណ៍កម្មដ្ឋាន បន្ទាប់ត្រូវឡើងកាន់អង្គវិចារ ពិចារណាអារម្មណ៍ (បើមាននីវរណធម៌ ត្រូវពិចារណាទោសរបស់នីវរណនោះហើយតម្រង់ទិដ្ឋិលះចោល) ចិត្តក៏ស្ងប់ បន្ទាប់ត្រូវឡើងកាន់អង្គបីតិ: បន្ទាប់ពីចិត្តស្ងប់បីតិក៏កើតឡើង ឬបង្អោនចិត្តជ្រះថ្លារំភើបឆ្អែតអារម្មណ៍ព្រឺព្រួចកាយបានដល់ផរណាបីតិ បន្ទាប់ត្រូវឡើងកាន់អង្គសុខ ធ្វើចិត្តឲ្យសោមនស្សញ៉ាំងសុខកើតឡើងបានដល់ កាយិកសុខ(សុខកាយ) គឺមានធាតុ ឬធាតុត្រជាក់ស្រោបសព៌ាង្គកាយសុខស្រួលក្នុងឈានក្រៃលែង និងចេតសិកសុខ(សុខចិត្ត) គឺចិត្តស្ងប់

សុខក្នុងឈានក្រៃលែង បន្ទាប់ត្រូវឡើងកាន់អង្គឯកគ្គតាៈ តាំងចិត្តស្ងប់ស៊ប់ក្នុងអារម្មណ៍រហូតឈានចិត្តមានកម្លាំងឡើងកាន់ទុតិយជ្ឈាន។ ក្នុងទុតិយជ្ឈានត្រូវលះវិតក្ក និងវិចារដោយពិចារណាទោសរបស់អង្គឈានទាំង ២ ដែលគ្រោតគ្រាតនៅជិតកៀកនឹងកាមារម្មណ៍ ឬចម្រើនយូរៗទៅក៏លះអង្គឈាននីមួយៗដោយចិត្តឡើងកាន់ឈានថ្នាក់លើៗ ធ្វើឲ្យបីតិ សុខ និងឯកគ្គតារឹតតែប្រណិត ឈានចិត្តមានកម្លាំងឡើងកាន់តតិយជ្ឈាន។ ក្នុងតតិយជ្ឈានត្រូវលះបីតិដោយពិចារណាទោសរបស់បីតិនៅជិតកៀកនឹងវិតក្ក និងវិចារដែលគ្រោតគ្រាត ធ្វើឲ្យសុខ និងឯកគ្គតារឹតតែប្រណិត ឈានចិត្តមានកម្លាំងឡើងកាន់ចតុត្ថជ្ឈាន។ ក្នុងចតុត្ថជ្ឈានត្រូវលះសុខដោយពិចារណាទោសរបស់សុខនៅគ្រោតគ្រាតជាងឧបេក្ខា ធ្វើឲ្យឯកគ្គតារឹតតែប្រណិតប្រកបដោយសតិដ៏បរិសុទ្ធ បានដល់បារិសុទ្ធុបេក្ខាចិត្ត ក្នុងការចម្រើនរូបជ្ឈាននៅមានរូបសញ្ញាជាអារម្មណ៍៕

*វសី ៥ គឺ:

១-អាវជ្ជនវសី: ជំនាញក្នុងការនឹក គឺនឹកយ៉ាងណា ឈានទើបនឹងកើតបានរហ័ស។

២-សមាបជ្ជនវសី: ជំនាញក្នុងការចូលឈាន គឺចូលឈានរឿយៗ។

៣-អធិដ្ឋានវសី: ជំនាញក្នុងការតាំងមាំ គឺនឹងឲ្យឈានតាំងនៅតាមត្រូវការ។

៤-វុដ្ឋានវសី: ជំនាញក្នុងការចេញចាកឈាន គឺចេញចាកឈានវេលាណាក៏បាន។

៥-បច្ចវេក្ខណវសី: ជំនាញក្នុងការពិចារណាអង្គឈាន គឺពិចារណាលះអង្គឈានដែលគ្រោតគ្រាតចេញ ដើម្បីធ្វើឲ្យអប្បនាសមាធិរឹងមាំក្រៃលែងឡើង។

*អប្បនាវិថី:

លោកិយអប្បនាវិថី បានដល់វិថីដែលមានមហគ្គតចិត្ត ១៨ គឺមហគ្គតកុសលចិត្ត ៩(រូបាវចរកុសលចិត្ត ៥ និងអរូបាវចរកុសលចិត្ត ៤) និងមហគ្គតកិរិយាចិត្ត ៩(រូបាវ-ចរកិរិយាចិត្ត ៥ និងអរូបាវចរកិរិយាចិត្ត ៤) ដែលកើតក្នុងអប្បនាវិថី។

-ភវង្គចលន ១ ខណៈ ជាមហាវិបាកញាណសម្បយុត្តចិត្ត។

-ភវង្គុបច្ឆេទ ១ ខណៈ ជាមហាវិបាកញាណសម្បយុត្តចិត្ត។

-មនោទ្វារាវជ្ជន ១ ខណៈ ចិត្តកើតឡើងធ្វើអាវជ្ជនកិច្ច តពីនោះ ចិត្ត ៨ គឺមហាកុសលចិត្ត ៤ មហាកិរិយាចិត្ត ៤ ដែលជាញាណសម្បយុត្តណាមួយ ធ្វើកាមជវន ៤ ឬ ៣ ខណៈ តាមសមគួរដល់បុគ្គលនោះ ជាវិថីទី ១។

-បរិកម្ម ១ ខណៈ ជាមហាកុសលញាណសម្បយុត្តចិត្ត គឺជាភាវនាធ្វើដោយជុំវិញរបស់អប្បនា ព្រោះតាក់តែងអប្បនា បានដល់មហាកុសលចិត្ត ៤ ដួង និងមហាកិរិយាចិត្ត ៤ ដួង ជាវិថីទី ២។

-ឧបចារ ១ ខណៈ ជាមហាកុសលញាណសម្បយុត្តចិត្ត គឺត្រាច់ទៅជិតអប្បនា ជាវិថីទី ៣។

-អនុលោម ១ ខណៈ ជាមហាកុសលញាណសម្បយុត្តចិត្ត គឺគាំទ្រដល់បរិកម្មក្នុងកាលខាងដើម និងដល់អប្បនាខាងលើ ជាវិថីទី ៤។

-គោត្រភូ ១ ខណៈ ជាមហាកុសលញាណសម្បយុត្តចិត្ត គឺគ្របសង្កត់បរិត្តគោត្រ (គោត្រកាម) និងញ៉ាំងមហគ្គតគោត្រឲ្យកើតឡើង ជាវិថីទី ៥។

-ឈាន ១ ខណៈ ពេលគោត្រភូរលត់ហើយ រូបាវចរបឋមជ្ឈានកុសលចិត្តក៏កើតឡើង សោយរសអារម្មណ៍ត្រឹមតែ ១ ខណៈ ជាវិថីទី ៦។ ហើយក៏ប្រព្រឹត្តទៅក្នុងក្រសែនៃភវង្គ(ភវង្គបាត) ពេលក្រោយមកមានការស្ទាត់ជំនាញឡើងហើយ ឈានចិត្តទើបអាចកើតរលត់បន្តថែមឡើងៗបាន ដោយមិនមានភវង្គចិត្តកើតជ្រែកខណ្ឌឡើយ។

-**អរូបជ្ឈាន**:

អរូបជ្ឈាន ជាឈានកន្លងអារម្មណ៍ គឺអាកាសានញ្ចាយតនជ្ឈាន កន្លងអារម្មណ៍ក្នុងកសិណ ៩ (បានចតុត្ថជ្ឈានក្នុងកសិណ ៩) ខាងដើមហើយ ទើបសម្រេចបានអរូបជ្ឈានខាងលើ ក៏កន្លងអារម្មណ៍ឈានក្រោមតាមលំដាប់។ ឈានលាភីដែលបានចតុត្ថជ្ឈានហើយមានបំណងចម្រើននូវអរូបជ្ឈាន ហាត់តាមគម្ពីរវិសុទ្ធិមគ្គ ឬហាត់តាមឧបនិស្ស័យ គឺសម្លឹងអាកាសកំណត់ទុកក្នុងចិត្តជាអារម្មណ៍(មិនគិតពិចា-

វណាអំពីអាកាស) រហូតចូលដល់អរូបាវចរភូមិ ពេលនោះអស្សាសប្បស្សាសរលត់តាំងនៅជាសូន្យ រហូតពោះប្រឹងកោងខ្នងដើម្បីច្របាច់ខ្យល់ក្នុងពោះឡើងមកធ្វើជាខ្យល់ដង្ហើម ពេលដែលសួតទ្រទ្រង់លែងបានក៏ដកដង្ហើមយកខ្យល់ចូល តែខណនោះបំពង់កក៏បិទដោយធម្មជាតិធ្វើឲ្យសួតយកខ្យល់ចូលមិនបាន ក៏ដាច់ខ្យល់ដង្ហើម ស្រាប់តែក្នុងខណនោះ មានធាតុមូលប៉ុនមាត់ចានចង្កឹះកើតក្នុងពោះទ្រទ្រង់ជីវិតឆ្លងផុតមរណ ពេលដែលដាច់ខ្យល់ដង្ហើមប្រហែល ២ នាទី ធាតុនោះក៏ចលនាឡើងចុះក្នុងខ្លួន ហើយក៏ឱនខ្លួនបញ្ចេញខ្យល់តាមមាត់រួចដកដង្ហើមចូលតាមច្រមុះធម្មជាតិវិញ ក្រោយមកធាតុនោះ ក៏វិវឌ្ឍដូចជាសសរមួយដើមទល់ពីបាតដល់លលាដ៍ក្បាល បន្ទាប់មកក៏តាំងនៅតឹងណែនក្នុងទ្រូងស្រូបទាញធាតុពីខាងក្រៅមកប៉ះចំត្រង់ចន្លោះចិញ្ចើម និងផ្ទៃបរិវេណភ្នែកទាំងគូព្រាកៗ ហើយក៏ចូលក្នុងប្រស្រីភ្នែក និងចន្លោះចិញ្ចើមមកតាំងនៅក្នុងទ្រូង ព្រមទាំងស្រោបក្តោបសព៌ាង្គកាយ។ ពេលធាតុចម្រើនឡើងក៏កើតអាកាសនិមិត្ត(បាតុភូត)ក្នុងក្បាល ធ្វើឲ្យមានអារម្មណ៍ថាក្នុងក្បាលទទេ មានតែអាកាសគ្មានទីបំផុត បានដល់អាកាសានញ្ចាយតនជ្ឈាន។ ពេលចម្រើនឈានក្រោយទៀត ក៏ពិចារណាអំពីអាកាសរហូតកំណត់ដឹងថា ការគិតអំពីអាកាសដល់ទីណា ការដឹងក៏ដល់ទីនោះ គឺថាបើពិចារណាអំពីចក្រវាលមួយ ក៏ដឹងទំហំអាកាសមួយចក្រវាល ពិចារណាឱកាសលោកជាអនន្តចក្រវាល ក៏ដឹងទំហំអាកាសមិនមានទីបំផុត ហើយក៏កើតអារម្មណ៍ក្នុងក្បាលមានចក្រវាលជាអនន្តស្មើនឹងអាកាសមិនមានទីបំផុត បានដល់វិញ្ញាណញ្ចាយតនជ្ឈាន។ ក្រោយពីបានដល់វិញ្ញាណញ្ចាយតនជ្ឈានហើយបន្តចម្រើនឈានទៅទៀត ចិត្តតាំងនៅជាស្ងប់សុខរហូតមានបាតុភូតកើតក្នុងទ្រូង ធ្វើឲ្យមានអារម្មណ៍ថាក្នុងទ្រូងទទេ មានតែចិត្តមានភាពទទេ ឃើញចិត្តដែលមានភាពទទេនោះថ្លៃថ្លាជាងចិត្តដែលមានអ្វីៗគ្រប់យ៉ាង បានដល់អាកិញ្ចញ្ញាយតនជ្ឈាន។ បន្ទាប់ពីបានដល់អាកិញ្ចញ្ញាយតនជ្ឈានហើយបន្តចម្រើនឈានទៅទៀត ចិត្តតាំងនៅជាស្ងប់សុខរហូតវិមុត្តិកើតឡើងប្រាកដ ដឹងច្បាស់ថា៖ "អាត្មាអញអស់មានបច្ច័យតាក់តែងនៅឋានមនុស្ស អាត្មានឹងបដិសន្ធិនៅព្រហ្មលោកយ៉ាងប្រាកដ" គឺបានដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន ក្នុងការចម្រើនអរូបជ្ឈានមិនមានរូបសញ្ញាជាអារម្មណ៍ឡើយ៕

## *និរោធសមាបត្តិ:

និរោធសមាបត្តិ គឺជាសមាបត្តិដែលរម្លត់សញ្ញាវេទនា(ចិត្ត) កាលចិត្តរលត់ខ្យល់ដង្ហើមក៏រលត់តាំងនៅបានរយៈពេលប្រាំពីរថ្ងៃ និរោធសមាបត្តិមិនមែនជាលោកិយ ឬលោកុត្តរ អ្នកចូលសមាបត្តិនេះបាន ប្រកបដោយគុណធម៌ ៤ គឺ ១-ជាព្រះអនាគាមី ឬព្រះអរហន្ត, ២-ជាអ្នកមានឈានសមាបត្តិ ៨, ៣-មានវសី ៥ ដែលស្ទាត់ និងជំនាញក្នុងសម្បទា ៤ (១.ជំនាញក្នុងសមថពល និងវិបស្សនាពល, ២.ជំនាញក្នុងការរម្ងាប់កាយសង្ខារ គឺអស្សាសប្បស្សាសដែលតាក់តែងនូវកាយ វចីសង្ខារ គឺវិតក្កនិងវិចារដែលតាក់តែងនូវវាចា ចិត្តសង្ខារ គឺសញ្ញា និងវេទនាដែលតាក់តែងនូវចិត្ត, ៣.ជំនាញក្នុងចរិយា ១៦ គឺអនិច្ចានុបស្សនា ទុក្ខានុបស្សនា អនត្តានុបស្សនា និព្វិទានុបស្សនា វិរាគានុបស្សនា និរោធានុបស្សនា បដិនិស្សគ្គានុបស្សនា វិវដ្ដានុបស្សនា សោតាបត្តិមគ្គ សោតាបត្តិផលសមាបត្តិ សកទាគាមិមគ្គ សកទាគាមិផលសមាបត្តិ អនាគាមិមគ្គ អនាគាមិផលសមាបត្តិ អរហត្តមគ្គ អរហត្តផលសមាបត្តិ, ៤.ជំនាញក្នុងសមាធិចរិយា ៩ គឺឧបចារសមាធិរបស់ឈាន និងបឋមជ្ឈានដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន), ៤-ព្រះអរិយបុគ្គលក្នុងបញ្ចវោការភូមិ(ភូមិដែលមានខន្ធ ៥)ប៉ុណ្ណោះចូលនិរោធសមាបត្តិបាន ចំណែកចតុវោការភូមិនោះចូលនិរោធសមាបត្តិមិនបានទេ ព្រោះមិនមានរូបសមាបត្តិ មានបឋមជ្ឈានជាដើម ជាអនុបុព្វនិរោធ នឹងការរម្លត់សង្ខារដោយលំដាប់ ជាអនុបុព្វសមាបត្តិ។ ភិក្ខុក្នុងសាសនានេះមានការនឿយនាយក្នុងការប្រព្រឹត្តទៅ និងការបែកធ្លាយនៃសង្ខារទាំងឡាយ ទើបគិតថា៖"យើងនឹងជាអ្នកមិនមានចិត្ត សម្រេចការរម្លត់ដូចព្រះនិព្វាន នៅជាសុខក្នុងបច្ចុប្បន្នជាតិនេះ" ដូច្នេះទើបចូលនិរោធសមាបត្តិ លោកចូលបឋមជ្ឈានដោយកម្លាំងនៃសមថ ចេញចាកបឋមជ្ឈាន ហើយពិចារណាសង្ខារទាំងឡាយក្នុងឈានដោយសេចក្តីអនិច្ចំ ទុក្ខំ អនត្តាដោយកម្លាំងនៃវិបស្សនា(ពិចារណាយ៉ាងនេះរហូតដល់អាកិញ្ចញ្ញាយតនជ្ឈាន) ពេលចេញចាកអាកិញ្ចញ្ញាយតនជ្ឈានផ្លាស់មកជាអធិដ្ឋានធ្វើបុព្វកិច្ច បើមិនធ្វើបុព្វកិច្ចមុន ចូលនេវសញ្ញានាសញ្ញាយតនជ្ឈាន រមែងមិនអាចនឹងរម្លត់សញ្ញាវេទនា និងឈានដែលចូលនោះ ក៏នឹងថយត្រឡប់មកតាំងនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈានដូចដើម។ ហេតុដូច្នេះ ទើបត្រូវធ្វើបុព្វកិច្ច ៤ យ៉ាង (១.នានាពទ្ធអវិកោបនំ សូមមិនឲ្យវត្ថុផ្សេងៗ ដែលជាប់ដោយភិក្ខុវិនាស, ២.សង្ឃ-

បដិមាននំ ការរងចាំរបស់សង្ឃ នឹងចេញភ្លាម, ៣.សត្ថុបក្កោសនំ ការទទួលតម្រាស់ហៅរករបស់ព្រះសាស្តា, ៤.អទ្ធានបរិច្ឆេទោ កំណត់កាលវេលា គឺកំណត់កាលវេលារបស់ជីវិតថា នឹងប្រព្រឹត្តទៅរហូតបាន ៧ ថ្ងៃឬទេ បើមិនប្រព្រឹត្តទៅមិនចូល បើប្រព្រឹត្តទៅក៏នឹងចូល ព្រោះនិរោធមិនអាចហាមការស្លាប់បាន និងក្នុងនិរោធនេះ ក៏មិនមានចិត្តធ្វើចុតិកិច្ច កាលវេលាអស់អាយុហើយ និរោធនេះ ក៏នឹងចេញទៅក្នុងចន្លោះដោយកម្លាំងនៃកម្ម កាលជ្រាបវត្ថុដែលគួរ ហើយទើបចូលនិរោធសមាបត្តិដោយកំណត់វេលាចេញ។ កាលធ្វើបុព្វកិច្ចហើយ ទើបចូលនេវសញ្ញានាសញ្ញាយត-នជ្ឈាន កាលឈានចិត្តនេះកើតឡើង ១ ឬ ២ ខណចិត្តហើយរលត់ទៅ និរោធក៏ប្រព្រឹត្តទៅ ៧ ថ្ងៃ ជាអ្នកមិនមានចិត្ត សម្ពស្ស(ពាល់ត្រូវ)និរោធ កាលចេញចាកនិរោធ ផលចិត្តរមែងកើតឡើង ១ ខណ ហើយជាភវង្គ)។ បន្ទាប់ពីបានសមាបត្តិ ៨ ហើយ បដិបត្តិតទៅទៀត នៅក្នុងនិរោធសមាបត្តិ នឹងបានពាល់ត្រូវបាតុភូត គឺធាតុដូចជាមានៈ ឧណ្ហតេជោធាតុ (តេជោធាតុក្តៅ) និងសីតតេជោធាតុ (តេជោធាតុត្រជាក់)កើតក្នុងទ្រូង អាចញ៉ាំងឧណ្ហតេជោធាតុកើតឡើងបាននៅពេលកាយសង្ខាររម្ងាប់ ខ្ទប់ដង្ហើមឲ្យជាប់ហើយប្រឹងដកដង្ហើមចេញសន្សឹមៗ ញ៉ាំងសីតតេជោធាតុកើតឡើងបាននៅពេលកាយសង្ខាររម្ងាប់ ខ្ទប់ដង្ហើមឲ្យជាប់ហើយប្រឹងដកដង្ហើមចូលសន្សឹមៗ ដើម្បីសម្របខ្លួនទៅនឹងសីតុណ្ហភាពខាងក្រៅ, ធាតុស្រោចស្រោបសព៌ាង្គកាយខ្ទងពីលើកណ្តាលក្បាលចូលក្នុងកាយស្រឹបៗ ព្រឺព្រួចស្រួលខ្លួន, ធាតុត្រជាក់ស្រោចស្រោបជ្រាបសព៌ាង្គកាយស្រឹបៗ ព្រឺព្រួចស្រួលខ្លួន, ធាតុត្រជាក់ផុសចេញពីកណ្តាលទ្រូងផ្សាយសព្វសព៌ាង្គកាយស្រឹបៗ ព្រឺព្រួចស្រួលខ្លួន, កលាបកើតរលត់ញ័ររោលរាលពេញសព៌ាង្គកាយសង្កៀរស្រួលខ្លួន, សព្វសព៌ាង្គកាយស្រួបធាតុចូលស្រឹបៗ ព្រឺព្រួចស្រួលខ្លួន។ ធាតុទាំងនេះអាចជួយសម្រួលដល់ធាតុទាំង ៤ ក្នុងកាយ ហើយអាចព្យាបាលអវយវៈណារាងខ្សោយសមត្ថភាពបានបន្តិចបន្តួច និងព្យាបាលជំងឺសើស្បែកបានខ្លះៗ។ ធាតុនោះជាឧបការទ្រទ្រង់ជីវិតនៅពេលរម្ងាប់កាយសង្ខារឲ្យរលត់សូន្យ ធាតុក៏ដំណើរការក្នុងទ្រូងស្រឹបៗយ៉ាងស្រាលជំនួសឲ្យខ្យល់ដង្ហើមប្រហែលមួយនាទី សញ្ញាវេទនាក៏រលត់ បានដល់សុញ្ញតវិមោក្ខ គឺតាំងនៅសូន្យចាកសង្ខារមិនដឹងអារម្មណ៍ទាំង ៦ រហូតស្ងួតទ្រទ្រង់ជិតលែងបាន សតិក៏កើតឡើងដឹងអំពីបញ្ញក្ខន្ធនឹកដល់ខ្យល់ដង្ហើម ទើបស្ងួតដំណើរការឡើងវិញ។

ម៉្យាងទៀតធាតុនោះក៏ជាឧបការដល់អភិញ្ញា ៥ គឺ: ឥទ្ធិវិធ(សម្ដែងឫទ្ធិបាន រីឯមនោ-មយិទ្ធិ គឺឫទ្ធិកើតដោយចិត្តអធិដ្ឋាន ក៏សង្គ្រោះចូលឥទ្ធិវិធ) ទិព្វសោត(ស្ដាប់សំឡេងនៅទីឆ្ងាយ និងសំឡេងក្នុងទីកំបាំងបាន) ចេតោបរិយញាណ(កំណត់ដឹងចិត្តអ្នកដទៃដោយចិត្តរបស់ខ្លួន) បុព្វេនិវាសានុស្សតិញាណ(រឭកឃើញនូវជាតិមុនៗបាន) ទិព្វចក្ខុ(ឃើញនូវសត្វទាំងឡាយដែលកំពុងច្យុត និងកំពុងកើត ព្រមទាំងមើលឃើញវត្ថុនៅទីឆ្ងាយ និងវត្ថុក្នុងទីកំបាំងបាន)។ បុថុជ្ជនដែលកសាងបារមីសន្សំមកច្រើន ជាប់ជំពាក់នូវសេចក្ដីប្រាថ្នាត្រាស់ដឹងជាព្រះពុទ្ធ គឺមានទាំងសមាបត្តិ ៨ និងសង្ខារុបេក្ខាញាណ ក៏ចម្រើនឈានក្នុងនិរោធសមាបត្តិនេះ រម្លត់សញ្ញាវេទនាបានមួយខណ មួយភ្លែតៗផងដែរ ព្រោះជាទីតាំងកើតនៃអភិញ្ញា ដើម្បីសន្សំឧបនិស្ស័យកសាងបារមីតទៅទៀត។ ក្នុងបច្ចេកពុទ្ធាបទាន(បិដក ៧២ ទំព័រ ១៦)សម្ដែងថា៖ "ពួកជនជាអ្នកប្រាជ្ញណាចម្រើននូវសុញ្ញតវិមោក្ខ(ព្រះនិព្វាន ជាសភាពសូន្យចាកសង្ខារទាំងពួង ស្ងប់ចាកកិលេសទាំងឡាយ) អនិមិត្តវិមោក្ខ(ព្រះនិព្វាន ជាសភាពមិនមាននិមិត្ត គឺសង្ខារទាំងពួងដែលជាទីកើតនៃកិលេសទាំងឡាយ) និងអប្បណិ-ហិតវិមោក្ខ(ព្រះនិព្វាន ជាសភាពមិនមានទីតាំង គឺសង្ខារទាំងពួងដែលជាទីតាំងនៃតណ្ហា) ក្នុងសាសនានៃព្រះជិនស្រីហើយ តែមិនសម្រេចនូវភាពជាសាវកទេ ពួកជនជាអ្នកប្រាជ្ញនោះ គង់បានជាព្រះបច្ចេកពុទ្ធត្រាស់ដឹងឯង"៕

*វិមោក្ខ ៣ យ៉ាង:

វិមោក្ខ គឺការរួចផុតដោយល្អអំពីធម៌ជាសត្រូវ និងអារម្មណ៍ទាំងឡាយ។

១-អនិមិត្តវិមោក្ខ: ព្រះនិព្វាន ជាសភាពមិនមាននិមិត្ត គឺសង្ខារទាំងពួងដែលជាទីកើតនៃកិលេសទាំងឡាយ ព្រោះចម្រើនវិបស្សនាឃើញត្រៃលក្ខណដោយអនិច្ចានុ-បស្សនាជាប្រធាន។

២-អប្បណិហិតវិមោក្ខ: ព្រះនិព្វាន ជាសភាពមិនមានទីតាំង គឺសង្ខារទាំងពួងដែលជាទីតាំងនៃតណ្ហា ព្រោះចម្រើនវិបស្សនាឃើញត្រៃលក្ខណដោយទុក្ខានុបស្សនាជាប្រធាន។

៣-សុញ្ញតវិមោក្ខ: ព្រះនិព្វាន ជាសភាពសូន្យចាកសង្ខារទាំងពួង ស្ងប់ចាកកិលេស

ទាំងឡាយ ព្រោះចម្រើនវិបស្សនាឃើញត្រៃលក្ខណដោយអនុត្តានុបស្សនាជាប្រធាន។

## *វិមោក្ខ ៨ ប្រការ:

១-រូបី រូបានិ បស្សតិ អយំ បឋមោ វិមោក្ខោ បាននូវរូបជ្ឈាន ឃើញរូបទាំងឡាយ (មាននីលកសិណជាដើម) នេះជាវិមោក្ខទី ១។ ការបរិកម្មនូវអាការ ៣២ ជារូបខាងក្នុង ដូចជាសក់កំណាត់ពណ៌ខៀវទុកក្នុងចិត្ត ធ្មេញកំណាត់ពណ៌សទុកក្នុងចិត្ត រហូតបដិភាគនិមិត្តកើតឡើងប្រាកដក្នុងមនោទ្វារបាននូវរូបជ្ឈាន(សំដៅរូបជ្ឈាន ៤)៕

២-អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ អយំ ទុតិយោ វិមោក្ខោ មិនមានសេចក្តីសំគាល់នូវរូបជ្ឈានខាងក្នុង ឃើញរូបទាំងឡាយខាងក្រៅ(មាននីលកសិណជាដើម) នេះជាវិមោក្ខទី ២។ មិនអាស្រ័យការបរិកម្មនូវរូបខាងក្នុង គឺសម្លឹងមើលកសិណខាងក្រៅដោយបរិកម្មធ្វើពណ៌ខៀវទុកក្នុងចិត្ត រហូតបដិភាគនិមិត្តពណ៌ខៀវកើតឡើងប្រាកដក្នុងមនោទ្វារបាននូវរូបជ្ឈាន ៤៕

៣-សុភន្តេវ អធិមុត្តោ ហោតិ អយំ តតិយោ វិមោក្ខោ។ ចិត្តចុះស៊ប់កាន់ឈាន ក្នុងវណ្ណកសិណដ៏បរិសុទ្ធ នេះជាវិមោក្ខទី ៣។

៤-សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ ចតុត្ថោ វិមោក្ខោ។ កន្លងនូវពួករូបសញ្ញា(សេចក្តីសម្គាល់ក្នុងរូប រូបក្នុងទីនេះ សំដៅយករូបាវចរជ្ឈានផង អារម្មណ៍របស់រូបាវចរជ្ឈាននោះផង) ដោយប្រការទាំងពួង ព្រោះរម្ងាប់នូវពួកបដិឃសញ្ញា(សេចក្តីសម្គាល់កើតឡើងដោយការប៉ះខ្ទប់ គឺចក្ខុប៉ះនឹងរូបជាដើម) ព្រោះមិនធ្វើទុកក្នុងចិត្តនូវពួកនានត្តសញ្ញា(សញ្ញាផ្សេងៗគ្នាមាន ៤៤ គឺកាមាវចរកុសលសញ្ញា ៨ អកុសលសញ្ញា ១២ កាមាវចរកុសលវិបាកសញ្ញា ១១ អកុសលវិបាកសញ្ញា ២ កាមាវចរកិរិយាសញ្ញា ១១) ក៏ចូលដល់អាកាសានញ្ចាយតនៈ ដោយបរិកម្មថា អាកាសមិនមានទីបំផុត ដូច្នេះ នេះជាវិមោក្ខទី ៤។

៥-សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ បញ្ចមោ វិមោក្ខោ។ កន្លងអាកាសានញ្ចាយតនៈ ដោយ

ប្រការទាំងពួង ក៏ចូលដល់វិញ្ញាណញ្ចាយតនៈ ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត នេះជាវិមោក្ខទី ៥។

៦-សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ ឆដ្ឋោ វិមោក្ខោ។ កន្លងវិញ្ញាណញ្ចាយតនៈ ដោយប្រការទាំងពួង ក៏ចូលដល់អាកិញ្ចញ្ញាយតនៈ ដោយបរិកម្មថា វត្ថុតិចតួចមិនមាន នេះជាវិមោក្ខទី ៦។

៧-សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ សត្តមោ វិមោក្ខោ។ កន្លងនូវអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ក៏ចូលដល់នេវសញ្ញានាសញ្ញាយតនៈ នេះជាវិមោក្ខទី ៧។

៨-សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ អយំ អដ្ឋមោ វិមោក្ខោ។ កន្លងនេវសញ្ញានាសញ្ញាយតនៈ ដោយប្រការទាំងពួង ក៏ចូលដល់សញ្ញាវេទយិតនិរោធ(និរោធសមាបត្តិ) នេះជាវិមោក្ខទី ៨។ សាវ័កទាំងឡាយរបស់ព្រះតថាគតជាច្រើន ក៏បានដល់នូវបារមីញាណ ជាទីបំផុតនៃអភិញ្ញា ក្នុងវិមោក្ខទាំង ៨ នោះ៕

*សមាបត្តិ (ជាឈ្មោះរបស់ឈាន) ៣ យ៉ាង:

១-ឈានសមាបត្តិ: គឺជាឈានវិថីចិត្តកើតបន្តគ្នាច្រើនខណតាមផ្លូវមនោទ្វារដោយមិនមានភវង្គចិត្តកើតខ័ណ្ឌ ដើម្បីសោយសេចក្តីសុខស្ងប់កើតអំពីឈានដែលខ្លួនបានហើយនោះ។

២-ផលសមាបត្តិ: គឺជាលោកុត្តរឈានវិថីចិត្តរបស់ព្រះអរិយដែលចូលតាមលំដាប់ថ្នាក់នៃលោកុត្តរផលចិត្ត មានលោកុត្តរបឋមជ្ឈានផលចិត្តជាដើម ដោយអំណាចវិបស្សនាញាណ ៩ មានឧទយព្វយញាណជាដើម ក្នុងលំដាប់នៃវោទាន(ចិត្តបរិសុទ្ធិដែលកើតមុនមគ្គថ្នាក់លើ គឺគោត្រភូ)ដែលមានសង្ខារធម៌ជាអារម្មណ៍ ចិត្តរបស់ព្រះអរិយសាវ័កអ្នកមានវិបស្សនាញាណ ដែលប្រព្រឹត្តទៅដោយលំដាប់នោះ ក៏ដល់និរោធ គឺពាល់ត្រូវព្រះនិព្វានណាមួយក្នុងចំណោម ៣ មានអនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ និងសុញ្ញតវិមោក្ខដោយអំណាចនៃផលសមាបត្តិ ដើម្បីនៅជាសុខក្នុងបច្ចុប្បន្នភាពនេះប៉ុណ្ណោះ។

៣-និរោធសមាបត្តិ: ជាវិធីសមាបត្តិដែលរំលត់សញ្ញាវេទនា(មិនមានចិត្តកើត)របស់ព្រះអនាគាមី និងព្រះអរហន្តដែលបានឈានសមាបត្តិ ៨ ប្រព្រឹត្តទៅបានត្រឹម ៧ ថ្ងៃ ឬតាមដែលប្រាថ្នា។ និរោធសមាបត្តិនេះមិនគួរពោលថា "ជាសង្ខត ឬអសង្ខត ជាលោកិយ ឬលោកុត្តរ" និរោធសមាបត្តិនេះពុំមែនជាលោកុត្តរនិព្វានក៏ពិត តែអ្នកដែលអាចចូលសមាបត្តិនេះបាន រមែងមានសេចក្ដីសុខស្ងប់ដែលប្រណីតក្រៃលែងដូចនិព្វាន ទើបលោកហៅសមាបត្តិនេះថា និព្វានក្នុងបច្ចុប្បន្នជាតិនេះ៕

*ការសន្សំឧបនិស្ស័យជាកន្សែស្រារពេជ្រ:

បុគ្គលដែលប្រាថ្នានូវកន្សែស្រារពេជ្រពោធិញ្ញាណ ត្រូវសិក្សាយល់ដឹងបរមត្ថធម៌ បដិច្ចសមុប្បាទធម៌ និងចតុរារិយសច្ចធម៌ ពិចារណាធម៌រឿយៗ ធ្វើយោនិសោ-មនសិការក្នុងការរួមសុខទុក្ខដ៏ក្រៃលែងជាមួយព្រះពោធិសត្វរឿយៗ មានសតិរឭកដឹងនូវសេចក្ដីប្រាថ្នារឿយៗ អប់រំចិត្តឲ្យជ្រះថ្លាក្នុងការធ្វើប្រយោជន៍ដល់សព្វសត្វរឿយៗ តាំងអធិដ្ឋានរឿយៗថា៖ ខ្ញុំករុណាសោមនស្សនឹងបូជាសម្បត្តិទាំងឡាយ បុត្តធីតា អវយវៈទាំងឡាយ និងអាយុជីវិតដល់ព្រះពោធិសត្វក្នុងការបំពេញបារមី ត្រូវមានសតិកំណត់ដឹងទុក្ខរបស់ខ្លួន និងទុក្ខរបស់សត្វដទៃមកជាអារម្មណ៍ ចម្រើននូវព្រហ្មវិហារបង្អោនចិត្តសង្គ្រោះសព្វសត្វ ញ៉ាំងចិត្តឲ្យធ្ងន់ទៅក្នុងកន្សែស្រារពេជ្របដិបទាមានឆន្ទមោះមុត ត្រូវចម្រើនសតិប្បដ្ឋានរឿយៗ និងបដិបត្តិនូវទាន សីល ភាវនា តែមិនបង្អោនចិត្តទៅក្នុងមគ្គផលព្រះនិព្វានក្នុងពេលបច្ចុប្បន្ន។ បដិបទានេះព្រះពោធិសត្វនឹងកន្សែស្រារពេជ្រត្រូវកសាងបុញ្ញកម្មរួមគ្នា ដោយព្រះពោធិសត្វតាំងក្នុងចេតនា(៣)ត្រាស់សម្មាសម្ពោធិញ្ញាណតែម្យ៉ាង ចំណែកកន្សែស្រារពេជ្រតាំងក្នុងចេតនា(៣)ជួយព្រះពោធិសត្វបំពេញបារមីដរាបបានត្រាស់ជាព្រះពុទ្ធតែម្យ៉ាង ព្រះពោធិសត្វនឹងកន្សែស្រារពេជ្រធ្លាប់បានសាងហេតុរួមគ្នាផង ធ្លាប់បានប្រាថ្នាចំពោះមុខគ្នាផង ចំពោះព្រះពុទ្ធរូបផង ព្រះចេតិយផង ពោធិព្រឹក្សផង ចំពោះព្រះអរិយផង ចំពោះព្រះភ័ក្ត្រព្រះបច្ចេកពុទ្ធទាំងឡាយផង និងចំពោះព្រះភ័ក្ត្រនៃព្រះសម្មាសម្ពុទ្ធទាំងឡាយរាប់មិនអស់ផង ច្រើនជាតិរាប់មិនអស់ទើបទៀងទាត់ប្រាកដបាន ព្រោះមានចិត្តប្រកបដោយប្រយោជន៍ដល់សព្វសត្វជាមួយគ្នា៕

## *មាគ៌ាជីវិតនៃព្រះពោធិសត្វ:

### +ព្រះពោធិសត្វ និងពោធិចិត្ត:

ព្រះពោធិសត្វ ជាបុគ្គលម្នាក់ដែលតាំងចិត្តប្រាថ្នាឲ្យបានត្រាស់ដឹងជាព្រះពុទ្ធ ដោយការខិតខំព្យាយាមសាងបុណ្យបារមីយ៉ាងស្វិតស្វាញជាទីបំផុត។ ពាក្យថា "ពោធិសត្វ" សំដៅយកបុគ្គល និងមហាសត្វទាំងឡាយដែលប្រកបដោយចិត្តបុណ្យដ៏ទូលំទូលាយព្រមទាំងមានបញ្ញាដ៏ជ្រាលជ្រៅ។ ពោធិ ជាពាក្យបាលីមានន័យថា បញ្ញាជាគ្រឿងត្រាស់ដឹង។ សត្ត ពាក្យបាលី ឬសត្វ ពាក្យសំស្រ្កឹតមានន័យថា បុគ្គលដែលជាប់ជំពាក់ក្នុងអារម្មណ៍ ឬបំណងណាមួយ។ ដូច្នេះ ពាក្យថា "ពោធិសត្វ" មានន័យថា បុគ្គលដែលមានចិត្តជាប់ជំពាក់ក្នុងការត្រាស់ដឹង ឬជាបុគ្គលដែលសាងចិត្តដើម្បីត្រាស់ដឹង។ ក្នុងន័យនេះ "គម្ពីរមហាវគ្គដីកាទីឃនិកាយ" សម្តែងថា៖ បញ្ញាណាចាក់ធ្លុះនូវធម៌ដែលគួរដឹងតាមសភាពពិតហេតុនោះ ឈ្មោះថា "ពោធិ"។ បុគ្គលនោះឯងឈ្មោះថា "ព្រះពោធិសត្វ" ព្រោះជាអ្នកអនុគ្រោះនូវសត្វ។ ហេតុនោះ ទើបលោកហៅថាបណ្ឌិតសត្វ ពុជ្ឈនកសត្វ គឺជាអ្នកប្រកបដោយ "ពោធិចិត្ត"។ តើអ្វីទៅដែលហៅថា ពោធិចិត្ត? ពោធិចិត្ត មានន័យថាសន្តានចិត្តនៃបុគ្គលដែលមានករុណា និងឆន្ទះខ្ជាប់ខ្ជួនតែមួយគត់ហើយធំជាងគេប្រចាំជិវិត គឺសេចក្តីប្រាថ្នាឲ្យបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ ឬព្រះពុទ្ធដើម្បីឲ្យបានរួចផុតចាកទុក្ខក្នុងសង្សារវដ្តផង និងដើម្បីជួយសង្រ្គោះដល់សត្វលោកទាំងពួងឲ្យរួចផុតចាកទុក្ខផងដែរ៕

### +តើបុគ្គលបែបណាទើបអាចសាងខ្លួនជាពោធិសត្វបាន?

មនុស្ស សត្វ បុរស ស្រ្តីទូទៅក្នុងលោកសុទ្ធតែជាអ្នកមានភ័ព្វវាសនាសាងខ្លួនជាពោធិសត្វបានដោយការកសាងពុទ្ធការកធម៌(ធម៌ធ្វើឲ្យបានត្រាស់ជាព្រះពុទ្ធ, ស្ត្រីក៏អាចប្រាថ្នាជាព្រះពោធិសត្វបានដែរ ប៉ុន្តែនិយតពោធិសត្វត្រូវស្ថិតនៅក្នុងភាពជាបុរស) ហើយអាចចាក់ធ្លុះសព្វញ្ញុតញ្ញាណជាព្រះពុទ្ធនាអនាគតកាលបាន ឲ្យតែបុគ្គលនោះមានឆន្ទៈ(បំណង ឬការប៉ងប្រាថ្នា)យ៉ាងមុតមាំក្នុងគោលដៅជិវិត។ ជនណាក៏ដោយក៏អាចប្រាថ្នា និងសាងខ្លួនជាពោធិសត្វបានដូចគ្នា ព្រោះមនុស្សម្នាក់ៗដែលកើតមកតែងតែមានសភាវៈពីរនៅក្នុងខ្លួនគឺ: សភាវៈល្អ និងសភាវៈអាក្រក់។ សភាវៈល្អនេះហើយដែលមានពូជធម្មជាតិរបស់ព្រះពុទ្ធ ហើយអាចរីកដុះដាលឲ្យ

មានបំណងដើម្បីបានត្រាស់ដឹងជាព្រះពុទ្ធ។ ក្នុងចំណុចនេះ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងថា៖ ការត្រឡប់បានអត្តភាពជាមនុស្សបានដោយកម្រ។ ការរស់របស់សត្វទាំងឡាយបានដោយកម្រ។ ការស្តាប់ធម៌របស់សប្បុរសបានដោយកម្រ។ ការកើតឡើងនៃព្រះពុទ្ធទាំងឡាយបានដោយកម្រ។ ទោះបីមនុស្សសត្វបានជួបប្រទះនូវការក្រទាំងបួនប្រការនេះក្តី ក៏ការបានចាប់កំណើតជាមនុស្សចាត់ទុកជាភ័ព្វវាសនាដ៏ខ្ពង់ខ្ពស់ណាស់ ព្រោះភពនៃមនុស្សយើងនេះជាកន្លែងនៃព្រះពុទ្ធគ្រប់ៗព្រះអង្គបានឧប្បត្តិឡើង ដើម្បីសាងបារមីឆ្ពោះទៅកាន់ "ពុទ្ធភូមិ"។ ព្រះពោធិសត្វអាចមានច្រើនអង្គនៅក្នុងរយៈពេលជាមួយគ្នា តែកម្រិតនៃការសាងបារមីខុសៗគ្នា។ ដូច្នេះហើយបានជាពោធិសត្វទាំងអស់នោះ ពុំអាចត្រាស់ជាព្រះពុទ្ធក្នុងពេលដំណាលគ្នាឡើយ។ ព្រះពោធិសត្វគ្រប់ៗជាតិតែងតែមានឆន្ទៈយ៉ាងមាំមួនក្នុងពោធិចិត្ត គឺចិត្តដែលជាប់ជំពាក់ក្នុងការត្រាស់ដឹង(មានបំណងត្រាស់ដឹងជាព្រះពុទ្ធ) និងតែងតែអនុវត្តយ៉ាងហ្មត់ចត់ជាទីបំផុតគ្រប់ៗជាតិនូវសីលធម៌ និងក្រឹត្យវិន័យប្រចាំជីវិតដែលហៅថា ពុទ្ធការកធម៌ ឬហៅថា បារមីធម៌។ និយមន័យ បារមី គឺជាពាក្យបាលីមកពីពាក្យ{បារ}មានន័យថា ត្រើយម្ខាង ឬត្រើយខាងមុខ និងពាក្យ{មី}មានន័យថាគុណជាតិដ៏ប្រសើរដែលគួរបំពេញ ឬផ្លូវដ៏ខ្ពង់ខ្ពស់ដែលគួរដើរដូចក្នុងគម្ពីរ "នមក្ការដីកាខែ" ថា គុណជាតិដែលនាំឲ្យដល់ត្រើយនៃព្រះនិព្វាន ឬញ៉ាំងសត្វឲ្យបានដល់ត្រើយនៃព្រះនិព្វាន ឈ្មោះថា "បារមី" (និយមតាមស័ព្ទពាក្យថា "បារមី" មកពីពាក្យៈ បរម + ល្ង = បារមី)។ ដូច្នេះ "បារមី" មានន័យថា គុណជាតិដ៏ប្រសើរដែលបុគ្គលត្រូវបំពេញ ឬជាគ្រឿងសម្រាប់ញ៉ាំងសត្វឲ្យដល់ត្រើយបរមសុខ គឺព្រះនិព្វាន។ តាមពាក្យសាមញ្ញ ការសាងបារមី គឺការអប់រំខ្លួនឲ្យបានបរិសុទ្ធទាំងផ្លូវកាយ វាចា ចិត្ត សតិ និងបញ្ញាដើម្បីធ្វើខ្លួនឲ្យមានគុណធម៌យ៉ាងល្អប្រសើរប្រចាំជីវិត៕

+**ការកសាងពោធិចិត្ត**:

បុគ្គលដែលបានប្រាថ្នានូវសម្មាសម្ពោធិញ្ញាណ តាំងចិត្តត្រាស់ដឹងអស់កាលច្រើនមហាកប្បមកហើយ នៅពេលបានសិក្សាព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធយល់ដឹងអំពីបរមត្ថធម៌ បដិច្ចសមុប្បាទធម៌ ចតុរាអរិយសច្ចធម៌ ឃើញសង្ខារជាទុក្ខដ៏ធំក្រៃលែងរកទីបំផុតគ្មាន ឃើញការរលត់ទុក្ខជាបរមសុខ ក៏កើតសេចក្តីសង្វេគចំពោះ

ខ្លួន ករុណាដល់អ្នកមានគុណ និងពពួកញាតិព្រមទាំងសព្វសត្វ ក៏លះបង់ការងារ ដើម្បីយកពេលវេលាមកធ្វើតបធម៌ ចម្រើនពោធិចិត្តក្នុងឈាន បរិកម្មថាៈ ពុទ្ធោៗ (សម្លឹងរូបព្រះពុទ្ធជាកសិណ បិទភ្នែកនឹកដល់ព្រះអង្គត្រាស់ដឹងអរិយសច្ចហើយ ញ៉ាំងព្រះអរិយទាំងឡាយឲ្យត្រាស់ដឹងផង មានពុទ្ធនិមិត្តក្នុងចិត្តជាអារម្មណ៍ ជ្រះថ្លាក្នុងពុទ្ធគុណ កើតបីតិ) បរិកម្មថាៈ អាត្មាជាពោធិសត្វត្រូវញ៉ាំងអារម្មណ៍ករុណា(អារម្មណ៍អាណិតសត្វកើតឡើង កើតបីតិ) ឧបេក្ខា(អារម្មណ៍ចំពោះសត្វស្មើៗគ្នា កើតបីតិ) មុទិតា(អារម្មណ៍ត្រេកអរក្នុងសត្វបានសុខចម្រើន កើតបីតិ)ចំពោះសព្វសត្វក្នុងអនន្តចក្កវាឡឲ្យចម្រើនឡើង ព្រោះសត្វលោកអវិជ្ជា(បង្អោនចិត្តអាណិតសព្វសត្វ) បរិកម្មថាៈ អាត្មាជាពោធិសត្វសោមនស្សលះបង់សេចក្ដីសុខរបស់ខ្លួនធ្វើប្រយោជន៍ដល់សព្វសត្វក្នុងអនន្តចក្កវាឡ(បង្អោនចិត្តនឹកលះបង់សេចក្ដីសុខជាលោកិយ និងលោកុត្តររបស់ខ្លួន ធ្វើប្រយោជន៍ដល់សព្វសត្វក្នុងអនន្តចក្កវាឡ កើតបីតិ) ព្រោះសត្វលោកអវិជ្ជា បរិកម្មថាៈ អាត្មាជាពោធិសត្វត្រូវញ៉ាំងឆន្ទវីរិយ ធ្វើប្រយោជន៍ដល់សព្វសត្វក្នុងអនន្តចក្កវាឡឲ្យចម្រើនឡើង (តាំងចិត្តប្ដេជ្ញាព្យាយាមធ្វើប្រយោជន៍ដល់សព្វសត្វក្នុងអនន្តចក្កវាឡ កើតបីតិ) ព្រោះសត្វលោកអវិជ្ជា បរិកម្មថាៈ អាត្មាជាពោធិសត្វសោមនស្សនឹងពុះដើមទ្រូងកាត់យកថ្លើម(នឹកកាត់ថ្លើម ព្រឹថ្លើម) ប្រមាត់(នឹកកាត់ប្រមាត់ ព្រឹប្រមាត់) បេះដូង(នឹកកាត់បេះដូង ព្រឹបេះដូង) និងកាត់សីសៈ(នឹកកាត់ក្បាល ព្រឹក្បាល) បូជាអង្គព្រះអរិយមេត្តេយ្យសម្មាសម្ពុទ្ធព្រមទាំងព្រះពុទ្ធទាំងឡាយនាកាលអនាគត (បង្អោនចិត្តនឹកបូជាព្រះអរិយមេត្តេយ្យព្រមទាំងព្រះពុទ្ធទាំងឡាយមានពុទ្ធនិមិត្តក្នុងចិត្ត កើតបីតិ) ដើម្បីប្រយោជន៍ដល់សព្វសត្វ បរិកម្មថាៈ អាត្មាជាពោធិសត្វសោមនស្សក្នុងការកសាងទសបារមី (បង្អោនចិត្តនឹកបរិច្ចាគសម្បត្តិទាំងឡាយ និងសម្បត្តិស្ដេចចក្កពត្តិរតនប្រាំពីរប្រការព្រមទាំងដើមកប្បព្រឹក្ស ធ្វើប្រយោជន៍ដល់សព្វសត្វក្នុងអនន្តចក្កវាឡដោយក្ដីមេត្តា កើតបីតិ) ទសឧបបារមី (បង្អោនចិត្តនឹកបរិច្ចាគអវយវៈទាំងឡាយ មានថ្លើម ប្រមាត់ បេះដូង តម្រងនោម ដៃ ជើង សាច់ ឈាម ឆ្អឹង ភ្នែក ធ្វើប្រយោជន៍ដល់សព្វសត្វក្នុងអនន្តចក្កវាឡដោយក្ដីមេត្តា កើតបីតិ) ទសបរមត្ថបារមី(បង្អោនចិត្តនឹកបរិច្ចាគជីវិតដូចសោមបណ្ឌិតព្រះបរមពោធិសត្វ ធ្វើប្រយោជន៍ដល់សព្វសត្វក្នុងអនន្តចក្កវាឡដោយក្ដីមេត្តា កើតបីតិ) និងមហាបរិច្ចាគ(បង្អោនចិត្តនឹកបរិច្ចាគភរិយា បុត្តធីតាជាទីស្រឡាញ់ ធ្វើប្រយោជន៍

ដល់សព្វសត្វក្នុងអនន្តចក្កវាឡដោយក្ដីមេត្តា កើតបីតិ) បរិកម្មថា៖ អាត្មាជាពោធិ-សត្វសោមនស្សនឹងត្រាស់សម្មាសម្ពោធិញ្ញាណជាព្រះពុទ្ធព្រះនាម **"មុនី រតនរង្សី"** (កើតបីតិ) មានអាយុមួយសែនឆ្នាំ(កើតបីតិ) កម្ពស់កៅសិបហត្ថ(កើតបីតិ) មានផ្កាឈូកផុសទ្រព្រះបាទាគ្រប់ជំហាន(និមិត្តក្នុងចិត្តមានផ្កាឈូកផុសទ្រព្រះបាទា) សូមឲ្យផែនដីក្នុងកប្បដែលអាត្មាត្រាស់ដឹងធំជាងផែនដីបច្ចុប្បន្នដប់ដង ដើម្បីសត្វលោករស់នៅបានច្រើនទូលំទូលាយ អាត្មាចេញបព្វជ្ជាដោយយានប្រាសាទ(ចេតិយវត្តគល់ទទឹងជានិមិត្តក្នុងចិត្ត សមាធិក្នុងប្រាសាទៗអណ្ដែតឡើងឰដ៏អាកាសហោះទៅកាន់ដើមកប្បព្រឹក្សដែលជាដើមឈើត្រាស់ដឹងនៅទិសខាងកើត) បំពេញព្យាយាម ៧ ថ្ងៃត្រាស់ជាព្រះពុទ្ធលើរតនបល្ល័ង្កផ្កាឈូកក្រោមដើមកប្បព្រឹក្ស (និមិត្តក្នុងចិត្តត្រាស់ជាព្រះពុទ្ធលើរតនបល្ល័ង្កផ្កាឈូកក្រោមដើមកប្បព្រឹក្ស) មានត្បូងកែវមណីប្រាសាទ ដើមកប្បព្រឹក្សជាទីប្រាថ្នានូវគ្រឿងឧបភោគ និងគ្រឿងបរិភោគរបស់សត្វលោក សត្វលោកបរិភោគស្រូវសាលីដែលកើតអំពីពុទ្ធានុភាព សូមឲ្យសត្វលោកក្នុងសម័យនោះបរិបូណ៌ដោយពុទ្ធានុស្សតិ ពុំមានរោគអ្វីក្រៅអំពីទុក្ខពេលឃ្លាន ទុក្ខពេលឈឺបន្ទោបង់ ទុក្ខពេលធ្វើមរណកាល សូមឲ្យឆព្វណ្ណរង្សីនៃព្រះតថាគតអង្គនោះ ផ្សាយចេញទៅគ្របដណ្ដប់ទាំងមួយសែនកោដិចក្កវាឡទាំងថ្ងៃទាំងយប់ (និមិត្តក្នុងចិត្តខ្លួនជាព្រះពុទ្ធផ្សាយឆព្វណ្ណរង្សី ចេញទៅគ្របដណ្ដប់ទាំងមួយសែនកោដិចក្កវាឡ កើតបីតិ) ដោយសេចក្ដីមេត្តាអនុគ្រោះដល់សព្វសត្វ បរិកម្មថា៖ អាត្មាជាពោធិសត្វមេត្តា (បង្អោនចិត្តនឹកចង់ឲ្យសត្វបាននូវសេចក្ដីសុខមិនមានពៀរនឹងគ្នា កើតបីតិ) ខន្តិ(បង្អោនចិត្តនឹកអត់ធន់ចំពោះតណ្ហា ទុក្ខទោមនស្ស សេចក្ដីខឹងក្រោធ កើតបីតិ) អភយទាន(បង្អោនចិត្តនឹកអនុគ្រោះឲ្យអភ័យដល់សព្វសត្វ កើតបីតិ) សម្មាសម្ពោធិញ្ញាណ(បង្អោនចិត្តនឹកត្រាស់ជាព្រះពុទ្ធ និមិត្តក្នុងចិត្តខ្លួនជាព្រះពុទ្ធ កើតបីតិ) ដើម្បីប្រយោជន៍ដល់សព្វសត្វ បរិកម្មថា៖ អាត្មាជាពោធិសត្វត្រូវចម្រើនពុទ្ធានុស្សតិ(នឹកដល់ព្រះពុទ្ធគុណធំធេងដូចសាគរ បរិសុទ្ធពុំមានបុគ្គលស្មើ បង្អោនចិត្តជ្រះថ្លាក្នុងព្រះពុទ្ធគុណ មានពុទ្ធនិមិត្តក្នុងចិត្ត កើតបីតិ) ព្រមទាំងទុក្ខរបស់សត្វ (បង្អោនចិត្តនឹកដល់ជាតិជាទុក្ខ ជរាជាទុក្ខ ព្យាធិជាទុក្ខ មរណជាទុក្ខមានដល់សព្វសត្វជាអារម្មណ៍ កើតបីតិ)មកជាអារម្មណ៍ក្នុងជីវិតប្រចាំថ្ងៃ ដើម្បីប្រយោជន៍ដល់សព្វសត្វ អធិដ្ឋានថា៖ ដោយគុណានុភាពនៃបុញ្ញកម្មទាំងឡាយ(នឹកដល់បុញ្ញកិរិយា

វត្ថុ ១០ និងបារមី ៣០ កើតបីតិ)ដែលអាត្មាធ្វើទុកក្នុងសង្សារវដ្ត មានទាំងនេក្ខម្មជាភិក្ខុសង្ឃ(និមិត្តក្នុងចិត្តខ្លួនធ្លាប់ជាភិក្ខុសិក្សាធម្មវិនយ សម្លឹងភ្លើងទៀនហាត់តេជោកសិណក្នុងរូងភ្នំ) និងនេក្ខម្មជាតាបស(និមិត្តក្នុងចិត្តខ្លួនធ្លាប់ជាតាបសអង្គុយមាត់សមុទ្ទសម្លឹងជើងមេឃហាត់អាកាសកសិណ)មានឫទ្ធិអភិញ្ញា សូមបានជាបច្ច័យត្រាស់សម្មាសម្ពោធិញ្ញាណជាព្រះពុទ្ធព្រះនាម "**មុនី រតនវង្សី**" (និមិត្តក្នុងចិត្តខ្លួនជាព្រះពុទ្ធ កើតបីតិ) មានអាយុមួយសែនឆ្នាំ(កើតបីតិ) កម្ពស់កៅសិបហត្ថ(កើតបីតិ) ដើម្បីប្រយោជន៍ដល់សព្វសត្វតែមួយយ៉ាង។ ការបរិកម្មថា៖ "អាត្មាជាពោធិសត្វសោមនស្ស" គឺជាឧបាយអប់រំចិត្តឲ្យប្រារព្ធខ្លួនជាពោធិសត្វ ពេញចិត្តក្នុងការចម្រើនពោធិចិត្តញ៉ាំងបំណងឲ្យសម្រេច ឈ្មោះថា ឆន្ទិទ្ធិបាទ ព្យាយាមក្នុងការចម្រើនពោធិចិត្តញ៉ាំងបំណងឲ្យសម្រេច ឈ្មោះថា វីរិយិទ្ធិបាទ យកចិត្តទុកដាក់ក្នុងការចម្រើនពោធិចិត្តញ៉ាំងបំណងឲ្យសម្រេច ឈ្មោះថា ចិត្តិទ្ធិបាទ ពិចារណាអំពីពុទ្ធការកធម៌រឿយៗញ៉ាំងបំណងឲ្យសម្រេច ឈ្មោះថា វិមំសិទ្ធិបាទ ឥទ្ធិបាទ គឺជាគុណធម៌ញ៉ាំងបំណងឲ្យសម្រេច ហេតុដូច្នេះ ត្រូវចម្រើនពោធិចិត្តក្នុងសមាធិប្រកបឥទ្ធិបាទ។ ការបរិកម្មថា៖ "ដើម្បីប្រយោជន៍ដល់សព្វសត្វ" គឺជាការអប់រំចិត្តឲ្យប្រាសចាកតណ្ហា ទិដ្ឋិ មានះ ការបរិកម្មទាំងឡាយ គឺជាការធ្វើយោនិសោមនសិការញ៉ាំងសទ្ធា សតិ បញ្ញា វីរិយ ឆន្ទឲ្យរឹងរិតតែរឹងមាំមោះមុត ចិត្តតាំងនៅក្នុងអារម្មណ៍ត្រាស់ដឹង កុសលចេតនាដែលធ្វើទុកក្នុងចិត្ត គឺជាគ្រាប់ពូជដែលដាក់ដាំនឹងលូតលាស់មានផ្កាផ្លែ។ អនិយតពោធិសត្វ(បុគ្គលមិនទាន់បានទទួលការព្យាករណ៍)ទាំងឡាយ ដែលមានពោធិចិត្តចាស់ក្លា រមែងបានកសាងបារមីសន្សំមកច្រើនជាងព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមីទៀតផង លោកជាបុគ្គលមានទាំងកម្លាំងឈាន និងកម្លាំងវិបស្សនាដែលអាចសម្រេចមគ្គផលក្នុងបច្ចុប្បន្នជាតិបាន ប៉ុន្តែដោយសេចក្តីករុណាចំពោះសត្វដែលលោកបានសន្សំក្នុងសន្តាន លោកមានសតិរឭកដឹងនូវសេចក្តីប្រាថ្នាចម្លងសត្វឲ្យរួចផុតចាកទុក្ខជានិច្ច លោកបានដឹងច្បាស់ទាំងមគ្គបដិបទា និងពោធិសត្វបដិបទា លោកបដិបត្តិកម្មដ្ឋានអប់រំចិត្តមិនឲ្យទោមនស្សចំពោះទុក្ខ ព្រោះសេចក្តីទោមនស្សចំពោះទុក្ខ នឹងញ៉ាំងចិត្តឲ្យនឿយណាយចំពោះបញ្ចក្ខន្ធ កាលបើចិត្តនឿយណាយចំពោះបញ្ចក្ខន្ធ ខណនោះបើសតិមិនបានរឭកដឹងសេចក្តីប្រាថ្នាចិត្តនឹងឡើងកាន់មគ្គវិថី ចាប់យកនិព្វានជាអារម្មណ៍សម្រេចមគ្គផលមិនបានដល់

ព្យាករ។ ហេតុដូច្នេះ ត្រូវធ្វើសម្មាសម្ពោធិញ្ញាណជាអារម្មណ៍ទុកក្នុងចិត្តរឿយៗឲ្យមានកម្លាំង ជាឧបការដល់សតិរឭកដឹងនូវសេចក្តីប្រាថ្នា មិនឲ្យចិត្តឡើងកាន់មគ្គវិថីពេលចម្រើនសមថវិបស្សនាកម្មដ្ឋាន ដើម្បីព្យាយាមបដិបត្តិពោធិសត្វបដិបទាតទៅទៀត។ លោកចម្រើនសតិឲ្យកំណត់ដឹងទុក្ខរបស់ខ្លួន និងទុក្ខរបស់សត្វដទៃធ្វើជាអារម្មណ៍ទុកក្នុងចិត្ត មកចម្រើនចិត្តដែលករុណាចំពោះសព្វសត្វឲ្យមានកម្លាំង ព្រមទទួលនូវសេចក្តីទុក្ខដ៏ក្រៃលែង ព្រោះការបំពេញបារមីត្រាស់សម្មាសម្ពោធិញ្ញាណត្រូវរងទុក្ខព្រមទាំងលះបង់ធំធេងក្រៃណាស់។ លោកក៏បានចម្រើនសតិប្បដ្ឋានជារឿយៗ ពិចារណាមើលធម៌ដែលខ្លួនមិនមានជារឿយៗ តម្រង់ទិដ្ឋិជារឿយៗ ដើម្បីសន្សំឧបនិស្ស័យចម្រើនសតិឲ្យរឹងមាំក្នុងការរឭកដឹងនូវសេចក្តីប្រាថ្នា បញ្ញាភ្លឺថ្លាក្នុងការពិចារណាអំពីពុទ្ធការកធម៌ សទ្ធាមោះមុតក្នុងការកសាងបារមីនាកាលអនាគតតទៅទៀត៕

### +តើចាប់ពីពេលណាទៅដែលបុគ្គលអាចសន្មតខ្លួនថាជាព្រះពោធិសត្វបាន?

គេអាចចាត់ទុកមនុស្សម្នាក់ ឬសត្វណាមួយជាព្រះពោធិសត្វបាន គឺនៅពេលដែលសតិរបស់មនុស្សនោះ ឬសត្វនោះឈានទៅដល់កម្រិតមួយដ៏ខ្ពស់ដែលពុំអាចដកទឹកចិត្តចេញពីឆន្ទពោធិចិត្តបាន គឺជាសេចក្តីប្រាថ្នាតែមួយក្នុងបំណងត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ។

### +ការសាងខ្លួនជាព្រះពោធិសត្វត្រូវឆ្លងកាត់បីដំណាក់កាលដ៏សំខាន់ៗដូចតទៅ៖

**-ដំណាក់កាលទី ១** បុគ្គលចិញ្ចឹមចិត្តឲ្យក្លាយជាពោធិចិត្តហើយតែនៅពុំអាចហ្វឹកហ្វឺនចិត្តឲ្យជាព្រះពោធិសត្វបាន ហាក់ដូចជាបុគ្គលម្នាក់ព្យាយាមយកគ្រាប់ពូជល្ហុមកផ្សាំក្នុងសួន តែពុំទាន់បានដុះជាដើមល្ហុ បុគ្គលនោះនៅតែខំព្យាយាមបន្តកប់គ្រាប់ល្ហុនៅក្នុងសួននោះទៀត (អាចប្រៀបបាននឹងរយៈពេលដែលព្រះពោធិសត្វតាំងមនោបណិធាន បញ្ញាធិក ៧ អសង្ខេយ្យ, សទ្ធាធិក ១៤ អសង្ខេយ្យ, វីរិយធិក ២៨ អសង្ខេយ្យ)។

**-ដំណាក់កាលទី ២** ក្រោយពីការតាំងពោធិចិត្តបានជាច្រើនម៉ឺនសែនជាតិហើយ សតិរបស់បុគ្គលនោះចាប់ផ្តើមប្រារព្ធចិត្តជាព្រះពោធិសត្វ ហើយចិត្តរបស់បុគ្គល

នោះតែងតែរិះគិតជានិច្ចចង់ត្រាស់ជាព្រះពុទ្ធ រហូតដល់មានកម្រិតខ្ពស់បំផុតដោយដកចិត្តចេញវិញលែងបានដូចដើមល្វមានពន្លកដុះចេញជាដើម ទង ស្លឹកទន់ខ្ចី។

អនិយតពោធិសត្វដែលបានសាងបារមីសន្សំឧបនិស្ស័យច្រើន ចម្រើនពោធិចិត្តប្រកបដោយមេត្តា ខន្តិ អភយទាន សម្មាសម្ពោធិញ្ញាណជាអារម្មណ៍ មានឥន្ទ្រិយចាស់ក្លា មានទាំងកម្លាំងឈាន(សមាបត្តិ ៨) និងកម្លាំងវិបស្សនា(បដិបទាញាណទស្សនវិសុទ្ធិ) មើលឃើញអវិជ្ជាជាធម្មជាតិញ៉ាំងសត្វឲ្យងងឹត តណ្ហាជាធម្មជាតិចងសត្វទុកក្នុងវដ្ត ឧបាទានជាធម្មជាតិញ៉ាំងសត្វឲ្យប្រកាន់មាំក្នុងអារម្មណ៍ អភិសង្ខារ(កម្ម)ជាធម្មជាតិកាត់តែងភពដល់សត្វ ទោះបីលោកបានឃើញទោសរបស់បញ្ចក្ខន្ធជាទុក្ខដ៏ក្រៃលែងប្រមាណមិនបាន ឃើញនិព្វានជាបរមសុខក្តី តែរាល់ពេលលោកចម្រើនសមថវិបស្សនាកម្មដ្ឋានឡើងដល់សង្ខារុបេក្ខាញាណ (អារម្មណ៍ស្ងប់ព្រងើយទៅៗចំពោះសង្ខារធម៌) ក៏រមែងលះបង់សេចក្តីព្យាយាម ព្រោះសតិដឹងជាក់ច្បាស់ថាបើបន្តទៅទៀតនឹងសម្រេចមគ្គផល ហើយក៏ប្តូរអារម្មណ៍មកចម្រើនពោធិចិត្តដើម្បីនាំសត្វចេញចាកសំសារទុក្ខដោយសេចក្តីករុណា។ (អាចប្រៀបបាននឹងរយៈពេលដែលព្រះពោធិសត្វតាំងវចីបណិធាន បញ្ញាធិក ៩ អសង្ខេយ្យ, សទ្ធាធិក ១៨ អសង្ខេយ្យ, វីរិយធិក ៣៦ អសង្ខេយ្យ ក្នុងដំណាក់កាល ទី ១ និងទី ២ នេះជាអនិយតពោធិសត្វ៕

**-ដំណាក់កាលទី ៣** លុះបានប្រារព្ធចិត្តជាព្រះពោធិសត្វច្រើនមហាកប្បហើយ ជាបុគ្គលដែលប្រកបដោយអដ្ឋសមោធាន គឺសម្បត្តិ ៨ ប្រការៈ

១-មនុស្សត្តំៈ បានដល់អត្តភាពរបស់មនុស្ស ព្រោះសេចក្តីប្រាថ្នារមែងសម្រេចដល់អ្នកដែលតាំងនៅក្នុងអត្តភាពរបស់មនុស្សតែប៉ុណ្ណោះ ហើយដែលការប្រាថ្នានោះ គឺប្រាថ្នាជាព្រះសម្មាសម្ពុទ្ធ។ រមែងមិនសម្រេចដល់អ្នកដែលតាំងនៅក្នុងជាតិផ្សេងមាននាគ និងគ្រុឌជាដើមឡើយ។ ព្រោះមនុស្សសមគួរដល់ភាពជាព្រះពុទ្ធ៕

២-លិង្គសម្បត្តិៈ សូម្បីតាំងនៅក្នុងអត្តភាពជាមនុស្សហើយ តែសេចក្តីប្រាថ្នារមែងសម្រេចបានចំពោះតែមនុស្សប្រុសប៉ុណ្ណោះ។ រមែងមិនសម្រេចដល់ស្ត្រី ឬខ្ទើយ ឬមនុស្សដែលមានភេទពីរឡើយ។ ព្រោះភេទប្រុសសមគួរដល់ភាពជាព្រះពុទ្ធ និងព្រោះមានភាពបរិបូណ៌នៃលក្ខណៈ។ សប្បុរសដែលប្រាថ្នានូវសម្មាសម្ពោធិញ្ញាណ

ត្រូវពិចារណាយ៉ាងនេះថា៖ បុរសមិនសូវជាប់ជំពាក់ច្រើននឹងភរិយាដូចស្ត្រីជាប់ជំ-ពាក់នឹងស្វាមី មិនសូវជាប់ជំពាក់ច្រើននឹងបុត្តធីតាដូចស្ត្រីជាប់ជំពាក់នឹងបុត្តធីតា មិនសូវរវល់ក្នុងកិច្ចការផ្ទះដូចស្ត្រីរវល់ក្នុងកិច្ចការផ្ទះ មិនមានទុក្ខព្រោះរដូវដូចស្ត្រី មិនពិបាកក្នុងការពផ្ទៃដូចស្ត្រី ចាកចេញពីផ្ទះ(បំពេញនេក្ខម្ម)មិនមានការបៀតបៀន ដោយកាមគុណដូចស្ត្រី មានចិត្តអង់អាចជាងស្ត្រី ព្រះពុទ្ធព្យាករណ៍បានចំពោះតែ បុរសភេទ(លិង្គសម្បត្តិ) ត្រាស់ដឹងជាព្រះពុទ្ធបានចំពោះតែបុរសភេទ លុះពិចារណា ឃើញតម្លៃនៃបុរិសភាវរូបដូច្នេះហើយ នឹងកើតមានអារម្មណ៍ភាពជាបុរសតាំងនៅ ក្នុងចិត្ត អារម្មណ៍នោះនឹងជាបច្ច័យដល់ចុតិចិត្ត និងបដិសន្ធិចិត្ត ហើយអនាគតនឹង មិនងាយផ្លាស់ប្តូរភេទនោះឡើយ៕

៣-ហេតុ: គឺដល់ព្រមដោយឧបនិស្ស័យ ពិតណាស់ សេចក្តីប្រាថ្នារមែងសម្រេចដល់ មនុស្សប្រុសដែលសម្បូណ៌ដោយឧបនិស្ស័យ បើមិនប្រាថ្នាជាព្រះពុទ្ធទេ អាចបាន ជាព្រះអរហន្តក្នុងជាតិនេះ ព្រោះហេតុសម្បត្តិ។ ក្រៅអំពីនេះ គឺមិនអាចសម្រេចបាន ឡើយ។ បុគ្គលដែលប្រាថ្នាសម្មាសម្ពោធិញ្ញាណគប្បីពិចារណាមើលថា៖ តើខ្លួន មានសង្ខារុបេក្ខាញាណដែលជាកំពូលនៃលោកិយបញ្ញា អាចសម្រេចមគ្គផលក្នុង បច្ចុប្បន្នជាតិហើយឬនៅ? បើនៅគួររួសរាន់បដិបត្តិសមថវិបស្សនាកម្មដ្ឋាន៕

៤-សត្ថារទស្សនំ: គឺការដែលមានព្រះសាស្តានៅចំពោះមុខ ព្រោះសេចក្តីប្រាថ្នា រមែងសម្រេចដល់បុគ្គលណា ដែលប្រាថ្នាក្នុងសំណាក់នៃព្រះសម្មាសម្ពុទ្ធទ្រង់គង់ ព្រះជន្មនៅឡើយ។ កាលបើព្រះដ៏មានព្រះភាគទ្រង់បរិនិព្វានហើយ សេចក្តីប្រាថ្នា រមែងមិនសម្រេចក្នុងមុខព្រះចេតិយ ឬគល់ព្រះពោធិព្រឹក្ស ទីព្រះបដិមា ឬសំណាក់ នៃព្រះបច្ចេកពុទ្ធ និងសាវ័ករបស់ព្រះសម្មាសម្ពុទ្ធឡើយ ព្រោះមិនមានអធិការ ព្រោះ ការពេញចិត្តដ៏មានកម្លាំងក្នុងការធ្វើដ៏ក្រៃលែង៕

៥-បព្វជ្ជា: គឺសេចក្តីប្រាថ្នារមែងសម្រេចដល់អ្នកប្រាថ្នាក្នុងសំណាក់របស់ព្រះដ៏មាន ព្រះភាគ ត្រូវតែជាអ្នកបួស ជាតាបស ឬបួសក្នុងសំណាក់ភិក្ខុទាំងឡាយ និងជាអ្នក ជឿកម្ម និងផលរបស់កម្ម។ មិនសម្រេចដល់អ្នកដែលតាំងនៅក្នុងភេទជាគ្រហស្ថ ឡើយ។ ព្រោះគ្រហស្ថមិនសមគួរជាព្រះសម្មាសម្ពុទ្ធ។ មានតែបព្វជិតតែប៉ុណ្ណោះ ជាព្រះមហាពោធិសត្វហើយបានសម្រេចនូវព្រះសម្មាសម្ពោធិញ្ញាណ ព្រោះដូច្នោះ

ក្នុងពេលតាំងប្រណិធានគួរដល់ភេទបព្វជិតតែប៉ុណ្ណោះ ជាការអធិដ្ឋានដោយគុណសម្បត្តិដ៏យ៉ាងពិតប្រាកដ៕

៦-គុណសម្បត្តិ: គឺដល់ព្រមដោយគុណ មានអភិញ្ញាជាដើម។ សេចក្តីប្រាថ្នារមែងសម្រេចដល់បព្វជិតដែលមានសមាបត្តិ ៨ និងអភិញ្ញា ៥ ព្រោះអាចស្រាវជ្រាវរកបារមីធម៌ឃើញបាន។ រមែងមិនសម្រេចដល់អ្នកដែលប្រាសចាកនូវគុណសម្បត្តិទាំងនេះឡើយ។ ព្រះមហាបុរសបំពេញអភិនីហារ(ការអប់រំបន្ទុំបារមី)ជាអ្នកអាចស្រាវជ្រាវរកឃើញនូវបារមីដោយខ្លួនឯង ជាអ្នកប្រកបដោយឧបនិស្ស័យសម្បត្តិ ឬអភិញ្ញាសម្បត្តិ។ បុគ្គលដែលប្រាថ្នាសម្មាសម្ពោធិញ្ញាណគប្បីពិចារណាមើលថា៖ តើខ្លួនមានសមាបត្តិ ៨ សម្រាប់ហាត់អភិញ្ញាក្នុងបច្ចុប្បន្នជាតិហើយឬនៅ? បើនៅគួររួសរាន់បដិបត្តិសមថកម្មដ្ឋាន៕

៧-អធិការោ: គឺមានឧបការដ៏ក្រៃលែង។ ពិតណាស់ បុគ្គលណាដល់ព្រមដោយគុណសម្បត្តិតាមដែលបានពោលហើយ ទោះបីជីវិតរបស់ខ្លួនក៏ហ៊ានលះបង់បូជាចំពោះដល់ព្រះសម្មាសម្ពុទ្ធដែរ រមែងធ្វើនូវឧបការដ៏យ៉ាងក្រៃលែងក្នុងកាលនោះ អភិនីហាររមែងសម្រេចដល់បុគ្គលនោះឯង រមែងមិនសម្រេចដល់បុគ្គលក្រៅអំពីនេះឡើយ។ បុគ្គលដែលប្រាថ្នាសម្មាសម្ពោធិញ្ញាណគប្បីពិចារណាមើលថា៖ តើខ្លួនបានអធិដ្ឋាន បូជាជីវិតថ្វាយព្រះសម្មាសម្ពុទ្ធមានអារម្មណ៍ប្រាកដកើតបីតិ ញុំាងឆន្ទឲ្យមុតមាំធ្វើយោនិសោមនសិការជារឿយៗហើយឬនៅ៕

៨-ឆន្ទតា: គឺពេញចិត្តក្នុងកុសលដែលបំណងប្រាថ្នានឹងធ្វើ។ សេចក្តីប្រាថ្នារមែងសម្រេចដល់អ្នកដែលប្រកបដោយធម៌តាមដែលបានពោលហើយ មានការពេញចិត្តខ្លាំង បំណងនឹងធ្វើដ៏ក្រៃលែង ដើម្បីប្រយោជន៍ដល់ធម៌ដែលធ្វើឲ្យបានសម្រេចជាព្រះសម្មាសម្ពុទ្ធតែប៉ុណ្ណោះ។ បុគ្គលដែលប្រាថ្នាសម្មាសម្ពោធិញ្ញាណគប្បីពិចារណាមើលថា៖ តើខ្លួនបានចម្រើនពោធិចិត្ត ញុំាងឆន្ទឲ្យមុតមាំធ្វើយោនិសោមនសិការជារឿយៗហើយឬនៅ?៕

ក៏ធ្វើសច្ចាប្រណិធានដោយប្តេជ្ញាចំពោះព្រះភ័ក្ត្រនៃព្រះសម្មាសម្ពុទ្ធថា៖ ដោយអំណាចបុញ្ញកម្មដែលខ្ញុំព្រះអង្គបានបំពេញមានប្រមាណប៉ុណ្ណោះ សូមឲ្យខ្ញុំព្រះអង្គបានត្រាស់ជាព្រះពុទ្ធមួយអង្គក្នុងអនាគតកាល។ ដំណាក់កាលទី ៣ នេះហាក់ដូច

ជាដើមល្វរឹងមាំជារុក្ខជាតិតែពុំទាន់មានផ្លែផ្កា (អាចប្រៀបបាននឹងរយៈពេលដែលព្រះពោធិសត្វបំពេញបារមីបន្តរហូតបានត្រាស់ បន្ទាប់ពីបានទទួលការព្យាករណ៍ពីព្រះសម្មាសម្ពុទ្ធរួចហើយ បញ្ញាធិក ៤ អសង្ខេយ្យ នឹង ១ សែនមហាកប្ប, សទ្ធាធិក ៨ អសង្ខេយ្យ នឹង ១ សែនមហាកប្ប, វីរិយធិក ១៦ អសង្ខេយ្យ នឹង ១ សែនមហាកប្ប)។ កាលណាព្រះសម្មាសម្ពុទ្ធទ្រង់ព្យាករបុគ្គលណាមួយថានឹងបានត្រាស់ជាព្រះពុទ្ធ ពេលនោះហើយបុគ្គលនោះមានឈ្មោះថា "និយតពោធិសត្វ" គឺជាបុគ្គលទៀងនឹងបានត្រាស់ជាព្រះពុទ្ធ។ ព្រះនិយតពោធិសត្វគ្រប់ៗជាតិតែងតែធ្វើសច្ចា-ប្រណិធាន ដើម្បីនឹងបានត្រាស់ជាព្រះពុទ្ធដោយព្យាយាមបំពេញពុទ្ធការកធម៌គឺ "ទសបារមី" ហេតុដូចនេះហើយ ព្រះគុណទាំង ៣ របស់ព្រះសម្មាសម្ពុទ្ធ គឺព្រះបញ្ញាគុណ ព្រះវិសុទ្ធិគុណ និងព្រះករុណាគុណ ដែលពុំមានបុគ្គលណាប្រៀបផ្ទឹមបានឡើយ សូមអនុមោទនា...!!! សាធុ... សាធុ... សាធុដោយសេចក្ដីជ្រះថ្លា...!!!៕

ផ្ដើមកសាង ភ្នំពេញ.ថ្ងៃអាទិត្យទី ១៥ កើត ពេញបូណ៌មី ខែ វិសាខ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី ២៩ ខែ មេសា គ.ស ឆ្នាំ ២០១៨។

បោះពុម្ពនៅថ្ងៃទី ខែ ឆ្នាំ

លេខទូរសព្ទ:

០១៦ ៧៧ ៨៦ ៨៧

០៨៩ ៩៣ ៥៦ ៦៥



**ទសពិធរាជធម៌ នាំឲ្យរាស្ត្រមានបញ្ញា ជាតិរុងរឿង សាសនាថ្កើងថ្កាន...!!!**

១-ទានៈ ការធ្វើអំណោយ។ ២-សីលៈ ការរក្សាសីល ៥ ជានិច្ច ឬរក្សាសីល ១០ មួយដងមួយកាល។

៣-បរិច្ចាគៈ ការចំណាយព្រះរាជទ្រព្យទំនុកបម្រុងប្រទេសជាតិ។ ៤-អាជ្ជវៈ មានសេចក្តីត្រង់។

៥-មទ្ទវៈ មានសេចក្តីទន់ភ្លន់ស្លូតសុភាពរាបសា។ ៦-តបៈ ការកាន់ឧបោសថសីលតាមកាលកំណត់ម្តងៗ។

៧-អក្កោធនៈ មិនកម្ដៅក្រហាយអ្នកដទៃ។ ៨-អវិហឹសា មិនបៀតបៀនអ្នកដទៃ។

៩-ខន្តិ មានសេចក្តីអត់ធន់។ ១០-អវិរោធនៈ មិនបំពានលើធម៌លើច្បាប់។